

# មូលដ្ឋានគ្រឹះនៃជំនឿ

# FUNDAMENTALS OF THE FAITH

*«យើងបាននិពន្ធសៀវភៅ មូលដ្ឋានគ្រឹះនៃជំនឿ ដោយសារយើងជឿថា
សេចក្តីពិតអំពីព្រះជាម្ចាស់ អំពីមនុស្សលោក និងអំពីព្រះគ្រីស្ទ
គឺជាខ្លឹមសារនៃជំនឿរបស់គ្រីស្ទបរិស័ទ។»*

— លោកគ្រូ ចន មែកខធ័រ (John MacArthur)

តើលោកអ្នកមានបំណងចិត្តចង់ឲ្យខ្លួនឯង និងក្រុមជំនុំឈរលើថ្មដានៃការបង្រៀនខាងទេវវិទ្យាដ៏មាំមួនដែរឬទេ? តើលោកអ្នកមានបំណងចង់ឃើញអ្នកជឿថ្មីៗលូតលាស់ខាងឯវិញ្ញាណយ៉ាងលឿនដែរឬទេ? តើលោកអ្នករំពឹងចង់ឃើញមានគ្រីស្ទបរិស័ទជាច្រើនទៀតពេញវ័យខាងឯវិញ្ញាណដែលមានចិត្តចង់ផ្សាយដំណឹងល្អ និងបង្កើតសិស្សដែរឬទេ? តើលោកអ្នកមានបំណងចិត្តចង់ឃើញក្រុមជំនុំរបស់លោកអ្នកមានការរួបរួមគ្នាដែលផ្អែកទៅលើការយល់ដឹងពីសេចក្តីពិតរបស់ព្រះជាម្ចាស់ជាមូលដ្ឋានដែរឬទេ?

បើដូច្នោះមែន សៀវភៅ **មូលដ្ឋានគ្រឹះនៃជំនឿ** ជាសៀវភៅដ៏ល្អសម្រាប់លោកអ្នកហើយ! សៀវភៅដ៏ល្អ និងងាយស្រួលអនុវត្តតាមមួយក្បាលនេះ គឺជាធនធានសម្រាប់អ្នកជឿថ្មីៗ និងអ្នកជឿយូរឆ្នាំមកដែរ។ ដូចគ្នាផងដែរ សៀវភៅនេះក៏បានទទួលការកែសម្រួលដោយ ចាស់ទុំ គ្រូបង្រៀន និងគ្រូគង្វាលនៅក្រុមជំនុំ ហ្គ្រេស ខមូនីតធី (Grace Community Church)។ តាមការដឹកនាំរបស់លោកគ្រូ ចន មែកខធ័រ (John MacArthur) យើងបានប្រើប្រាស់សៀវភៅនេះក្នុងការបង្រៀន ហើយយើងឃើញថាវាមានប្រសិទ្ធភាពល្អណាស់លើជីវិតអ្នកដែលបានសិក្សា។

តាមរយៈមេរៀនទាំង១៣នៃសៀវភៅនេះ លោកអ្នកនឹងសិក្សាលើមូលដ្ឋានគ្រឹះនៃជំនឿដែលអ្នកជឿគ្រប់រូបត្រូវយល់ដឹង៖

- សេចក្តីផ្តើមអំពីព្រះគម្ពីរ
- វិធីយល់ដឹងដើម្បីស្គាល់ព្រះគម្ពីរ
- ព្រះជាម្ចាស់៖ ចរិតលក្ខណៈ និងលក្ខណសម្បត្តិរបស់ទ្រង់
- បុគ្គលភាពរបស់ព្រះយេស៊ូវគ្រីស្ទ
- ព័ន្ធកិច្ចរបស់ព្រះគ្រីស្ទ
- សេចក្តីសង្គ្រោះ
- បុគ្គលភាព និងព័ន្ធកិច្ចរបស់ព្រះវិញ្ញាណបរិសុទ្ធ
- ការអធិស្ឋាន និងអ្នកជឿ
- ក្រុមជំនុំ៖ ការប្រកប និងការថ្វាយបង្គំ
- អំណោយទានខាងឯវិញ្ញាណ
- ការប្រកាសដំណឹងល្អ និងអ្នកជឿ
- ការស្តាប់បង្គាប់
- ការដឹកនាំ និងបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់

គ្រប់មេរៀននីមួយៗមាន សំណួរពិភាក្សា ខគម្ពីរចងចាំ និងការអនុវត្តជាក់ស្តែង ដើម្បីជួយឲ្យលោកអ្នកគ្រាប់តាមព្រះគម្ពីរ។ សៀវភៅ **មូលដ្ឋានគ្រឹះនៃជំនឿ** គឺជាលទ្ធផលដែលបានមកពីការរៀបចំ ការបង្រៀន និងការអនុវត្តរបស់ក្រុមជំនុំយើងខ្ញុំអស់ជាច្រើនឆ្នាំមកហើយ។ អំណាចនៃសៀវភៅនេះគឺមិនអាស្រ័យទៅលើការរៀបចំរចនាអត្ថបទនោះទេ តែវាអាស្រ័យទៅលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលជាមូលដ្ឋានគ្រឹះនៃសៀវភៅនេះ។

*«យើងដឹងថា នៅពេលដែលព្រះវិញ្ញាណបរិសុទ្ធប្រើព្រះបន្ទូលរបស់ព្រះជាម្ចាស់
នៅក្នុងដួងចិត្តមនុស្ស នោះជីវិតរបស់ពួកគេនឹងទទួលបានការផ្លាស់ប្រែពីទ្រង់។»*

— លោកគ្រូ ចន មែកខធ័រ (John MacArthur)

**ជីវិតលោកអ្នកក៏អាចទទួលការផ្លាស់ប្រែផងដែរ!**

ACTION CAMBODIA
www.actioncambodia.org

ការបង្កើតសិស្ស - ការបង្រៀន
ISBN 978-0-9890481-8-7
9 780989 048187

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

សេចក្តីផ្តើមដោយ លោកគ្រូ ចន ម៉ែកខធ័រ
INTRODUCTION BY JOHN MACARTHUR

# មូលដ្ឋានគ្រឹះនៃជំនឿ
# FUNDAMENTALS OF THE FAITH

មេរៀនទាំង១៣៖ ដើម្បីរីកចម្រើន
ខាងឯព្រះគុណ និងប្រាជ្ញារបស់ផងព្រះយេស៊ូវគ្រីស្ទ

បកប្រែដោយៈ សកម្មភាពកម្ពុជា

Translated by: ACTION Cambodia — http://www.actioncambodia.org

រក្សាសិទ្ធិគ្រប់យ៉ាង © ១៩៩៥, ២០០៧, ២០១៤ ដោយ ក្រុមជំនុំ ហ្គ្រេស ខម្មូនីតធី

Copyright © 1995, 2007, 2014 by Grace Community Church

Grace Community Church
13248 Roscoe Blvd.
Sun Valley, CA 91352 USA
(800) 472-2315

All rights reserved.
No part of this material may be reproduced or copied in any form or by any means—graphic, electronic, or mechanical, including photocopying, taping, or information storage and retrieval systems—without written permission of the copyright owner, except for brief excerpts quoted in critical reviews.

តើលោកអ្នកបានទទួលអត្ថប្រយោជន៍ពីសៀវភៅនេះដែរឬទេ?

សូមផ្ដល់ជាមតិយោបល់ដល់យើងខ្ញុំ តាមរយៈអ៊ីមែល resources@actioncambodia.org

ប្រសិនបើលោកអ្នកឃើញមានកំហុសលើអក្ខរាវិរុទ្ធ វេយ្យាករណ៍ ឬឃ្លាប្រយោគ

សូមជួយផ្ដល់ជាដំណឹងដល់យើងខ្ញុំ តាមរយៈអ៊ីមែល resources@actioncambodia.org

ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រៈ

For information on how to purchase additional copies of this book, please visit:
http://www.cambodianchristianresources.com/fundamentalsofthefaith/

ពិនិត្យផ្ទៀងផ្ទាត់ដោយៈ លោក ជួប ប៊ុនហាក់ និងសកម្មភាពកម្ពុជា

យើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ឆ្នាំ១៩៥៤ ក៏ដូចជាអសាធារណនាមមួយចំនួន ប៉ុន្តែ
សំណេរនៅក្នុងអត្ថបទទាំងមូល យើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់
សម្ដេចសង្ឃរាជ ជួន ណាត។

ព្រមជាមួយនឹងការប្រើប្រាស់កម្មវិធីត្រួតពិនិត្យអក្ខរាវិរុទ្ធ
និងវេយ្យាករណ៍ យូនីកូដខ្មែរ របស់ ស.ស.ឈ.ន.ក.

Edited using the SBBIC Unicode Khmer Spelling Checker
and Grammar Checker — http://www.sbbic.org

សូមថ្លែងអំណរអរគុណដល់ៈ លោក គឹម សីហា, លោកគ្រូ ហុង សុភក្តិ, លោកគ្រូ ជឿន ជីវិចន្ទា, លោក ម៉ែន ជំនោ, និងលោក ឈាង ប៉ូវ៉ា
ដែលមានចំណែកក្នុងការអភិវឌ្ឍសៀវភៅនេះ។

អត្ថបទគម្ពីរ © រក្សាសិទ្ធិដោយសមាគមព្រះគម្ពីរសកល
ដកស្រង់ដោយមានការអនុញ្ញាត

English Edition ISBN: 1-883973-01-5

Khmer Edition ISBN: 978-0-9890481-8-7

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

# សេចក្តីផ្តើម

សៀវភៅ **មូលដ្ឋានគ្រឹះនៃជំនឿ** អាចជារឿងមានតម្លៃដ៏ខ្ពស់បំផុតដែលមានរក្សាទុកនៅក្នុងក្រុមជំនុំ ហ្គ្រេស ខម្មូនីតធី (Grace Community Church)។

យើងបាននិពន្ធសៀវភៅនេះដោយអំណរជាយូរឆ្នាំមកហើយ ដើម្បីបំពេញតម្រូវការរបស់ក្រុមជំនុំយើង តាំងពីខ្ញុំជាគ្រូគង្វាលវ័យក្មេងម្នាក់ ហើយពេលនោះក្រុមជំនុំរបស់ខ្ញុំក៏មិនសូវមានមនុស្សច្រើនទេ។ ទន្ទឹមនឹងនោះដែរ ក្រុមជំនុំរបស់យើងក៏កំពុងរីកចម្រើនឡើង។ មានក្រុមគ្រួសារ និងអ្នកនៅលីវជាច្រើននាក់បានចាប់ផ្តើមមកចូលរួមនៅក្នុងក្រុមជំនុំយើង មានអ្នកខ្លះទើបតែនឹងជឿ ហើយខ្លះទៀតជាអ្នកជឿដែលទើបតែនឹងផ្លាស់ទីលំនៅមកនៅជិតក្រុមជំនុំយើង។ ដូច្នេះហើយបានជាមានអ្នកចូលរួមថ្មីៗជាច្រើនដែលមានប្រវត្តិផ្សេងៗគ្នា។ ហេតុដូច្នេះហើយ យើងគិតថា ត្រូវការពង្រឹងលើមូលដ្ឋានគ្រឹះនៃជំនឿដល់អ្នកនៅក្នុងក្រុមជំនុំយើង។

សៀវភៅ **មូលដ្ឋានគ្រឹះនៃជំនឿ**នេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឲ្យក្រុមជំនុំយើងពេញវ័យខាងឯវិញ្ញាណចាប់តាំងពីពេលនោះមក។ សៀវភៅនេះបានផ្តល់ជាមូលដ្ឋានគ្រឹះនៃទេវវិទ្យាដ៏រឹងមាំមួយដល់អ្នកជឿថ្មីៗ និងជួយដុសខាត់លើការយល់ដឹងពីសេចក្តីបង្រៀនដ៏សំខាន់ៗក្នុងព្រះគម្ពីរ ព្រមទាំងប្រដាប់ពួកគេក្នុងការផ្សាយដំណឹងល្អ និងការបង្កើតសិស្សផង។ សៀវភៅនេះជួយចម្រើនលើភាពរួបរួមគ្នាដ៏ពិតប្រាកដនៅក្នុងក្រុមជំនុំ គឺជាភាពរួបរួមគ្នាដែលឈរលើការយល់ដឹងពីសេចក្តីពិតនៃព្រះជាម្ចាស់។

ទោះបីជាសៀវភៅនេះមានសារៈសំខាន់ចំពោះ ក្រុមជំនុំ ហ្គ្រេស ខម្មូនីតធី (Grace Community Church) ក៏ដោយ ក៏មិនសូវមានក្រុមជំនុំផ្សេងទៀតប្រើប្រាស់សៀវភៅនេះដែរ។

ប៉ុន្តែឥឡូវមិនដូចពីមុនទៀតទេ។ ដោយព្រះគុណរបស់ព្រះជាម្ចាស់ ពេលនេះយើងមានឱកាសដើម្បីចែកចាយសៀវភៅដ៏ល្អនេះដល់ក្រុមជំនុំផ្សេងៗនៅសហរដ្ឋអាមេរិក [និងប្រទេសផ្សេងៗនៅលើពិភពលោកផងដែរ]។ សៀវភៅដែលលោកអ្នកកំពុងតែកាន់នេះបានទទួលការកែសម្រួលជាច្រើនលើកច្រើនសាររួចមកហើយ។ ហើយវាគឺជាលទ្ធផលដែលបានមកពីការរៀបចំ ការបង្រៀន និងការអនុវត្តអស់ជាច្រើនឆ្នាំមកដែរ។ យើងបានប្រើប្រាស់សៀវភៅនេះក្នុងការបង្រៀន ហើយយើងឃើញថា វាមានប្រសិទ្ធភាពល្អណាស់លើជីវិតអ្នកដែលបានសិក្សា។

យើងបានដឹងច្បាស់ហើយថា អំណាចនៃសៀវភៅនេះគឺមិនអាស្រ័យទៅលើការរៀបចំរចនាអត្ថបទនោះទេ តែវាអាស្រ័យទៅលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលជាមូលដ្ឋានគ្រឹះនៃសៀវភៅនេះទៅវិញទេ។ យើងដឹងថា នៅពេលដែលព្រះវិញ្ញាណបរិសុទ្ធប្រើព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងដួងចិត្តមនុស្ស នោះជីវិតរបស់ពួកគេនឹងទទួលបានការផ្លាស់ប្រែពីទ្រង់។ នោះហើយជាមូលហេតុដែលខ្ញុំមានក្តីរំភើបយ៉ាងខ្លាំង ដោយដឹងថាលោកអ្នកបានរកសៀវភៅនេះឃើញ។ យើងបានប្រើប្រាស់សៀវភៅនេះ

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

ដើម្បីទទួលស្វាគមន៍មនុស្សរាប់ពាន់នាក់ឲ្យចូលទៅក្នុងក្រុមជំនុំ និងក្នុងគ្រួសារនៃព្រះគ្រីស្ទ។ វាបានជួយអ្នកជឿជាច្រើនចាក់គ្រឹះខាងវិញ្ញាណឲ្យមាំមួន។

ខ្ញុំជឿថា សៀវភៅនេះនឹងផ្ដល់ផលប្រយោជន៍ដល់លោកអ្នក និងក្រុមជំនុំរបស់លោកអ្នក ដូចដែលក្រុមជំនុំរបស់ខ្ញុំបានទទួលផលប្រយោជន៍ពីសៀវភៅនេះផងដែរ។



គ្រូគង្វាល នៅ ក្រុមជំនុំ ហ្គ្រេស ខមូនីតធី (Grace Community Church)
ទីក្រុង សាន់ វ៉ាលី (Sun Valley) រដ្ឋ កាលីហ្វញ៉ា សហរដ្ឋអាមេរិក

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

# របៀបក្នុងការប្រើកិច្ចការមេរៀន

១. មុនពេលបំពេញមេរៀននីមួយៗ សូមត្រៀមខ្លួនឲ្យបានរួចជាស្រេចដោយអធិស្ឋានទូលសូមព្រះជាម្ចាស់ជួយលោកអ្នកក្នុងការសិក្សាព្រះបន្ទូលរបស់ទ្រង់។ ខណៈពេលដែលលោកអ្នកបំពេញចម្លើយនៅក្នុងសៀវភៅនេះ សូមកត់ចំណាំ ហើយសម្គាល់លើសំណួរដែលលោកអ្នកនៅមានចម្ងល់។ លោកអ្នកចាំបាច់ត្រូវមានព្រះគម្ពីរ ដើម្បីបំពេញមេរៀននីមួយៗ និងនៅពេលដែលលោកអ្នកជួបជុំគ្នាពិភាក្សាមេរៀន។

២. ការជួបជុំគ្នាពិភាក្សាមេរៀនមិនមែនជាពេលដែលត្រូវបំពេញចម្លើយនោះទេ។ ប៉ុន្តែគឺជាពេលដែលត្រូវពន្យល់ និងពិភាក្សាលើប្រធានបទស្នូល ហើយក៏ជាពេលដែលត្រូវឆ្លើយសំណួរទាក់ទងទៅនឹងមេរៀនវិញ។

៣. ប្រសិនបើលោកអ្នកយកចិត្តទុកដាក់ទៅលើការបំពេញមេរៀន នោះលោកអ្នកនឹងទទួលបានអត្ថប្រយោជន៍ពីការពិភាក្សា ព្រមទាំងអាចមានសមត្ថភាពក្នុងការពិភាក្សាជាមួយក្រុមផងដែរ។

៤. នៅពេលដែលលោកអ្នកជួបជុំគ្នាពិភាក្សាមេរៀន លោកអ្នកត្រូវមានចិត្តក្លាហានក្នុងការចែកចាយ និងទទួលយកការចែកចាយពីអ្នកដទៃផងដែរ។

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

# មាតិកា


មេរៀនទី១ សេចក្តីផ្តើមអំពីព្រះគម្ពីរ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៩

មេរៀនទី២ វិធីយល់ដឹងដើម្បីស្គាល់ព្រះគម្ពីរ. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១៩

មេរៀនទី៣ ព្រះជាម្ចាស់៖ ចរិតលក្ខណៈ និងលក្ខណសម្បត្តិរបស់ទ្រង់ . . . . . . . . . . . . . . . . . . .៣១

មេរៀនទី៤ បុគ្គលភាពរបស់ព្រះយេស៊ូវ. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៤៣

មេរៀនទី៥ ព័ន្ធកិច្ចរបស់ព្រះគ្រីស្ទ. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៤៩

មេរៀនទី៦ សេចក្តីសង្គ្រោះ. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៥៧

មេរៀនទី៧ បុគ្គលភាព និងព័ន្ធកិច្ចរបស់ព្រះវិញ្ញាណបរិសុទ្ធ . . . . . . . . . . . . . . . . . . . . . . .៦៥

មេរៀនទី៨ ការអធិស្ឋាន និងអ្នកជឿ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៧១

មេរៀនទី៩ ក្រុមជំនុំ៖ ការប្រកបគ្នា និងការថ្វាយបង្គំ . . . . . . . . . . . . . . . . . . . . . . . . . . . .៧៩

មេរៀនទី១០ អំណោយទានខាងឯវិញ្ញាណ. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៨៩

មេរៀនទី១១ ការផ្សាយដំណឹងល្អ និងអ្នកជឿ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៩៧

មេរៀនទី១២ ការស្តាប់បង្គាប់. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១០៣

មេរៀនទី១៣ ព្រះហឫទ័យ និងការដឹកនាំរបស់ព្រះជាម្ចាស់. . . . . . . . . . . . . . . . . . . . . . . . .១១១

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

មេរៀនទី១

# សេចក្តីផ្តើមអំពីព្រះគម្ពីរ

**ខគម្ពីរចងចាំ៖ ២ធីម៉ូថេ ៣:១៦**
គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្តាលឲ្យតែងទេ ក៏មានប្រយោជន៍សំរាប់ការបង្រៀន ការរំឭកឲ្យដឹងខ្លួន ការប្រដៅដំរង់ នឹងការបង្ហាត់ខាងឯសេចក្តីសុចរិត។

**ព្រះគម្ពីរគឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់** ដែលអះអាងថាជាសេចក្តីពិត ជាព្រះរាជសារមកពីព្រះជាម្ចាស់ដល់មនុស្ស។ ២ពេត្រុស ១:២១ ចែងថា “...គឺជាមនុស្សបរិសុទ្ធរបស់ព្រះ ដែលបានទាយដោយសារព្រះវិញ្ញាណបរិសុទ្ធទ្រង់បណ្តាលវិញ”។

- មានមនុស្សប្រមាណជា៤០នាក់ខុសៗគ្នា ដែលបានសរសេរបទគម្ពីរទាំងនេះឡើង
- ពួកគេរស់នៅក្នុងប្រទេសខុសៗគ្នា
- ពួកគេរស់នៅក្នុងសម័យកាលផ្សេងៗគ្នា (១៤០០ មុន គ.ស-៩០ នៃគ.ស)
- ពួកគេបានសរសេរជាបីភាសា៖ ហេព្រើរ អារ៉ាម និងក្រិក

តែទោះបីជាមានភាពខុសគ្នាដ៏ធំយ៉ាងនោះក៏ដោយ ក៏ព្រះជាម្ចាស់បានបណ្តាលឲ្យពួកអ្នកនិពន្ធទាំងនោះ ផ្តោតសំខាន់ទៅលើសិរីល្អរបស់ទ្រង់ ក្នុងការលោះបាបមនុស្ស ហើយតួអង្គសំខាន់តែមួយគត់ គឺព្រះយេស៊ូវគ្រីស្ទដែលជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់។

## I. សញ្ញាចាស់ (៣៩កណ្ឌ)

### ក) បញ្ចកណ្ឌ (កណ្ឌទាំងប្រាំ)

លោក ម៉ូសេ បានសរសេរព្រះគម្ពីរប្រាំកណ្ឌដំបូងនៃព្រះគម្ពីរសញ្ញាចាស់ នៅអំឡុងឆ្នាំ ១៤០០ មុន គ.ស។ កណ្ឌទាំងនោះគេតែងតែហៅថា “កណ្ឌទាំងប្រាំរបស់លោក ម៉ូសេ” ឬ “បញ្ចកណ្ឌ”។

ចូរសរសេរកណ្ឌទាំងនេះឲ្យត្រូវតាមលំដាប់លំដោយ ដែលលោកអ្នកអាចរកឃើញនៅក្នុងព្រះគម្ពីរ៖

១. ____________________ កណ្ឌនៃការចាប់ផ្តើមមាន៖ ការបង្កើត មនុស្សលោក បាប ការលោះបាប និងប្រជាជាតិរបស់ព្រះជាម្ចាស់។

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

២. ____________________ ព្រះជាម្ចាស់រំដោះរាស្ត្រទ្រង់ចេញពីស្រុកអេហ្ស៊ីប។

៣. ____________________ ក្រឹត្យវិន័យនៃពួកអាចារ្យលើភាពបរិសុទ្ធ និងការថ្វាយបង្គំតាមរយៈការបូជា និងការធ្វើឲ្យខ្លួនបរិសុទ្ធ។

៤. ____________________ រាស្ត្ររបស់ទ្រង់នៅតែបន្តមិនស្តាប់បង្គាប់ ហើយវង្វេងនៅក្នុងវាលរហោស្ថានអស់រយៈពេល៤០ឆ្នាំ។

៥. ____________________ សេចក្តីថ្លែងដ៏អស្ចារ្យរបស់លោក ម៉ូសេ ក្នុងការណែនាំបណ្តាជនឲ្យរៀបចំខ្លួនចូលទៅកាន់ទឹកដីសន្យា។

**ខ) ប្រវត្តិសាស្ត្រ  (១២កណ្ឌ)**

អ្នកនិពន្ធបានសរសេរគ្រប់ទាំងកណ្ឌនៃប្រវត្តិសាស្ត្រនេះឡើងនៅក្នុងអំឡុងឆ្នាំ ១៤០០-៤៥០ មុន គ.ស ហើយពណ៌នាអំពីដំណោះស្រាយរបស់ព្រះជាម្ចាស់ជាមួយនឹងរាស្ត្ររើសតាំងរបស់ព្រះអង្គ គឺរាស្ត្រអ៊ីស្រាអែលដែលជាជនជាតិហេព្រើរ។

ចូរសរសេរកណ្ឌទាំងនេះឲ្យត្រូវតាមលំដាប់លំដោយៈ

| | | |
|---|---|---|
| ១. ____________________ | ៥. ____________________ | ៩. ____________________ |
| ២. ____________________ | ៦. ____________________ | ១០. ____________________ |
| ៣. ____________________ | ៧. ____________________ | ១១. ____________________ |
| ៤. ____________________ | ៨. ____________________ | ១២. ____________________ |

**គ) កំណាព្យ (៥កណ្ឌ)**

ប្រាំកណ្ឌបន្ទាប់ទៀត គឺជាកំណាព្យដែលពណ៌នានៅក្នុងពាក្យកាព្យ និងចម្រៀង រៀបរាប់ពីភាពអស្ចារ្យរបស់ព្រះជាម្ចាស់ និងដំណោះស្រាយរបស់ទ្រង់ជាមួយមនុស្ស។

ចូរសរសេរកណ្ឌទាំងនេះឲ្យត្រូវតាមលំដាប់លំដោយៈ

១. ____________________ ការរងទុក្ខវេទនា និងការទុកចិត្តដ៏ស្មោះត្រង់របស់មនុស្សម្នាក់ដែលស្រឡាញ់ព្រះជាម្ចាស់។

២. ____________________ ចម្រៀងសរសើរតម្កើង និងការបង្ហាត់បង្រៀន។

៣. ____________________ គតិបណ្ឌិតដ៏ប៉ិនប្រសប់របស់ព្រះជាម្ចាស់សម្រាប់ការរស់នៅប្រចាំថ្ងៃ។

៤. ____________________ ភាពសូន្យសុងនៃជីវិតក្នុងលោកីយ៍ដែលគ្មានព្រះជាម្ចាស់។

៥. ____________________ អំណរក្នុងអាពាហ៍ពិពាហ៍។

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

### ឃ) ហោរាធំ (៥កណ្ឌ)

ហោរាគឺជាមនុស្សម្នាក់ដែលព្រះជាម្ចាស់បានតែងតាំងឡើង ដើម្បីចែកចាយព្រះរាជសាររបស់ទ្រង់ទៅកាន់មនុស្សទាំងអស់។ គេហៅកណ្ឌទាំងនោះថា “ហោរាធំ” ព្រោះកណ្ឌទាំងនោះវែងជាងការសរសេររបស់ “ហោរាតូច”។ កណ្ឌទាំងនោះសរសេរឡើងប្រហែលពីឆ្នាំ ៧៥០-៥៥០ មុន គ.ស។

ចូរសរសេរកណ្ឌទាំងនេះឲ្យត្រូវតាមលំដាប់លំដោយ៖

១. ________________ ៣. ________________ ៥. ________________

២. ________________ ៤. ________________

### ង) ហោរាតូច (១២កណ្ឌ)

អ្នកនិពន្ធបានសរសេរកណ្ឌទាំងនេះឡើងប្រហែលជាចន្លោះពីឆ្នាំ ៨៤០-៤០០ មុន គ.ស។

ចូរសរសេរកណ្ឌទាំងនេះឲ្យត្រូវតាមលំដាប់លំដោយ៖

១. ________________ ៥. ________________ ៩. ________________

២. ________________ ៦. ________________ ១០. ________________

៣. ________________ ៧. ________________ ១១. ________________

៤. ________________ ៨. ________________ ១២. ________________

## II. សញ្ញាថ្មី (២៧កណ្ឌ)

សញ្ញាថ្មី ឬសម្ព័ន្ធមេត្រីថ្មីបានបង្ហាញពីព្រះគ្រីស្ទថា ជាព្រះប្រោសលោះបាបមនុស្សលោក។ នៅក្នុងកណ្ឌសញ្ញាថ្មីនេះ យើងអាចរកឃើញពី៖

- ជីវិតរបស់ព្រះគ្រីស្ទ
- ផ្លូវនៃសេចក្ដីសង្គ្រោះ
- ដើមកំណើតរបស់គ្រីស្ទបរិស័ទ
- សេចក្ដីបង្រៀនសម្រាប់ការរស់នៅជាគ្រីស្ទបរិស័ទ
- គម្រោងការណ៍របស់ព្រះជាម្ចាស់សម្រាប់ពេលអនាគត

**ក) ប្រវត្តិសាស្ត្រ (៥កណ្ឌ)**

១. ដំណឹងល្អ (៤កណ្ឌដំបូង)

ក) ____________________ គេបានចងក្រងពីជីវិតរបស់ព្រះគ្រីស្ទជាពិសេសទុកសម្រាប់ពួកសាសន៍យូដា ដើម្បីបង្ហាញឲ្យពួកគេដឹងថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះមេស្ស៊ី ដែលពួកគេទន្ទឹងរង់ចាំអស់រយៈពេលជាយូរមកហើយនោះ។

ខ) ____________________ គេបានចងក្រងពីជីវិតរបស់ព្រះគ្រីស្ទ ជាពិសេសទុកសម្រាប់ជនជាតិរ៉ូមសម័យដើម ដើម្បីបង្ហាញឲ្យពួកគេដឹងថា ទ្រង់គឺជាអ្នកបម្រើដែលស្ដាប់បង្គាប់ព្រះជាម្ចាស់។

គ) ____________________ លោក លូកាដែលជាជនជាតិក្រិកបានចងក្រងពីជីវិតរបស់ព្រះគ្រីស្ទ ជាពិសេសទៅកាន់ពួកក្រិកលើពិភពលោក ដើម្បីបង្ហាញពីព្រះគ្រីស្ទថា ទ្រង់គឺជាមនុស្សដ៏គ្រប់លក្ខណ៍ សំដៅទៅលើភាពជាមនុស្សរបស់ព្រះអង្គ។

ឃ) ____________________ ជីវិតរបស់ព្រះគ្រីស្ទ បង្ហាញឲ្យដឹងថា ទ្រង់គឺជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់ ដែលបញ្ជាក់ពីភាពជាព្រះរបស់ព្រះអង្គ។ កណ្ឌនេះសាវ័ក យ៉ូហាន បានសរសេរផ្ញើទៅកាន់មនុស្សទាំងអស់។

តើហេតុផលពីរយ៉ាងដែលនាំឲ្យមានការសរសេរកណ្ឌដំណឹងល្អយ៉ូហានឡើងនោះគឺជាអ្វី (យ៉ូហាន ២០:៣១)?

១. ____________________________________________

២. ____________________________________________

២. ប្រវត្តិរបស់ក្រុមជំនុំដើមដំបូង (១កណ្ឌ)

____________________ ដើមដំបូង និងការរាលដាលនៃក្រុមជំនុំគ្រីស្ទបរិស័ទ។ គេអាចហៅកណ្ឌនោះថា «កិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធ» ហើយគេសរសេរកណ្ឌនេះឡើងទុកជាឧបករណ៍សម្រាប់ផ្សាយដំណឹងល្អ។

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

**ខ) សំបុត្រ ឬសារ (២១កណ្ឌ)**

អ្នកនិពន្ធបានចងក្រងសំបុត្រនេះឡើង ដើម្បីផ្ញើទៅកាន់បុគ្គលម្នាក់ៗ ទៅកាន់ក្រុមជំនុំ និងអស់អ្នកជឿទូទៅទាំងអស់។ សំបុត្រទាំងនេះដោះស្រាយនូវរាល់ទិដ្ឋភាពស្តីពីជំនឿ និងការទទួលខុសត្រូវរបស់គ្រីស្ទបរិស័ទ។

ចូរសរសេរកណ្ឌទាំងនេះឲ្យត្រូវតាមលំដាប់លំដោយះ

១. សំបុត្ររបស់សាវ័ក ប៉ុល (១៣កណ្ឌ)

ក) ________________ ជ) ________________

ខ) ________________ ឈ) ________________

គ) ________________ ញ) ________________

ឃ) ________________ ដ) ________________

ង) ________________ ឋ) ________________

ច) ________________ ឌ) ________________

ឆ) ________________

២. សំបុត្រទូទៅ (៨កណ្ឌ)

ក) ________________ ង) ________________

ខ) ________________ ច) ________________

គ) ________________ ឆ) ________________

ឃ) ________________ ជ) ________________

**គ) ទំនាយ (១កណ្ឌ)**

កណ្ឌចុងក្រោយនៃគម្ពីរសញ្ញាថ្មី ប្រាប់ពីព្រឹត្តិការណ៍ផ្សេងៗនាពេលអនាគតះ

- ការយាងមកវិញរបស់ព្រះយេស៊ូវគ្រីស្ទ
- រាជរបស់ព្រះយេស៊ូវគ្រីស្ទ
- សិរីល្អរបស់ព្រះយេស៊ូវគ្រីស្ទ
- សេចក្តីថ្លែងបញ្ជាក់ពីអនាគតរបស់ពួកអ្នកជឿ និងអ្នកមិនជឿ

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

គេហៅកណ្ឌគម្ពីរនេះថា ______________________________។

## III. ព្រះគ្រីស្ទក្នុងព្រះគម្ពីរ

**ក) គេបានមើលគម្ពីរសញ្ញាចាស់ និងសញ្ញាថ្មីជាមួយគ្នា ហើយពណ៌នាពីព្រះយេស៊ូវគ្រីស្ទទុកជាតួអង្គដ៏សំខាន់បំផុត។**

ចូរអានខគម្ពីរខាងក្រោមទាំងនេះ ហើយបំពេញឃ្លាដូចតទៅៈ

១. លូកា ២៤:២៧ គេបានឃើញព្រះគ្រីស្ទនៅក្នុង ______________________________។

២. យ៉ូហាន ៥:៣៩ ព្រះយេស៊ូវមានបន្ទូលថា «គឺជាគម្ពីរនោះឯង ដែលធ្វើបន្ទាល់ពី ___»។

**ខ) គន្លឹះសំខាន់គឺព្រះយេស៊ូវ**

<table>
<tr><th>៥កណ្ឌ<br>ជាក្រឹត្យវិន័យ</th><th>១២កណ្ឌ<br>ជាប្រវត្តិសាស្ត្រ</th><th>៥កណ្ឌ<br>ជាកំណាព្យ</th><th>១៧កណ្ឌ<br>ជាទំនាយ</th><th>៤កណ្ឌ<br>ជាដំណឹងល្អ</th><th>១កណ្ឌ<br>ជាប្រវត្តិសាស្ត្រ</th><th>២១កណ្ឌ<br>ជាសំបុត្រ</th><th>១កណ្ឌ<br>ជាទំនាយ</th></tr>
<tr><td>សេចក្តីសន្យា<br>របស់ព្រះគ្រីស្ទ</td><td colspan="3">ការទន្ទឹងរង់ចាំព្រះគ្រីស្ទ គំរូ<br>បទពិសោធន៍ និងទំនាយ</td><td>ការលេចមក<br>របស់ព្រះគ្រីស្ទ</td><td colspan="2">ក្រុមជំនុំ<br>របស់ព្រះគ្រីស្ទ</td><td>ពិធីរាជាភិសេក<br>របស់ព្រះគ្រីស្ទ</td></tr>
</table>

## IV. ហេតុអ្វីព្រះគម្ពីរមានសារៈសំខាន់?

នៅពេលដែលអារក្សបានមកល្បួងព្រះយេស៊ូវ ពេលនោះទ្រង់បានលើកបទគម្ពីរ ចោទិយកថា ៨:៣ ដោយមានបន្ទូលថា «មនុស្សមិនមែនរស់ ដោយសារតែនំបុ័ងប៉ុណ្ណោះទេ គឺរស់ដោយសារគ្រប់ទាំងព្រះបន្ទូល ដែលចេញពីព្រះឱស្ឋព្រះមកដែរ» (ម៉ាថាយ ៤:៤)។

**ក) តើកណ្ឌគម្ពីរ ២ធីម៉ូថេ ៣:១៦ មានចែងយ៉ាងដូចម្តេចពីព្រះគម្ពីរ?**
**(ចូរគូសសញ្ញាគ្រីស ✓ នៅលើចម្លើយដែលត្រឹមត្រូវ)**

☐ ផ្នែកមួយចំនួននៃព្រះគម្ពីរគឺព្រះជាម្ចាស់បណ្តាលឲ្យតែង។

☐ មានផ្នែកខ្លះព្រះជាម្ចាស់មិនបានបណ្តាលឲ្យតែងទេ។

☐ គ្រប់ទាំងបទគម្ពីរគឺព្រះជាម្ចាស់បណ្តាលឲ្យតែង។

☐ មានតែផ្នែកដែលនិយាយមកកាន់យើងផ្ទាល់ប៉ុណ្ណោះដែលព្រះជាម្ចាស់បណ្តាលឲ្យតែង។

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

**ខ) តើខគម្ពីរទាំងអស់ខាងក្រោមនេះ បង្ហាញពីសារៈសំខាន់នៃព្រះបន្ទូលរបស់ព្រះជាម្ចាស់យ៉ាងដូចម្ដេចខ្លះ?**

១. ២ធីម៉ូថេ ៣:១៥ ________________________________________

________________________________________

________________________________________

២. ហេព្រើរ ៤:១២ ________________________________________

________________________________________

________________________________________

________________________________________

**គ) តើកិច្ចការបួនយ៉ាងដែលព្រះបន្ទូលរបស់ព្រះជាម្ចាស់ធ្វើនោះមានអ្វីខ្លះ?**

១. ទំនុកដំកើង ១៩:៧ក[១] ________________________________________

២. ទំនុកដំកើង ១៩:៧ខ[២] ________________________________________

៣. ទំនុកដំកើង ១៩:៨ក ________________________________________

៤. ទំនុកដំកើង ១៩:៨ខ ________________________________________

## V. ការអនុវត្ត

យោងតាមអ្វីដែលលោកអ្នកបានរៀនមកពីព្រះគម្ពីរ តើលោកអ្នកគួរឆ្លើយតបយ៉ាងដូចម្ដេច?

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

# ការមើលព្រះគម្ពីរគ្រួសៗ (៦៦កណ្ឌ)

## សញ្ញាចាស់ (៣៩កណ្ឌ)

### ប្រវត្តិសាស្ត្រ (១៧កណ្ឌ)

**ក្រឹត្យវិន័យ**

១. លោកុប្បត្តិ
២. និក្ខមនំ
៣. លេវីវិន័យ
៤. ជនគណនា
៥. ចោទិយកថា

**ប្រវត្តិសាស្ត្រ និង ការតាំងសញ្ញា**

១. យ៉ូស្វេ
២. ពួកចៅហ្វាយ
៣. នាងរស់
៤. ១សាំយ៉ូអែល
៥. ២សាំយ៉ូអែល
៦. ១ពង្សាវតារក្សត្រ
៧. ២ពង្សាវតារក្សត្រ
៨. ១របាក្សត្រ
៩. ២របាក្សត្រ
១០. អែសរ៉ា
១១. នេហេមា
១២. នាងអេសធើរ

### កំណាព្យ (៥កណ្ឌ)

១. យ៉ូប
២. ទំនុកដំកើង
៣. សុភាសិត
៤. សាស្តា
៥. បទចំរៀងសាឡូម៉ូន

### ពាក្យទំនាយ (១៧កណ្ឌ)

**ហោរាធំ**

១. អេសាយ
២. យេរេមា
៣. បរិទេវ
៤. អេសេគាល
៥. ដានីយ៉ែល

**ហោរាតូច**

១. ហូសេ
២. យ៉ូអែល
៣. អេម៉ុស
៤. អូបាឌា
៥. យ៉ូណាស
៦. មីកា
៧. ណាហ៊ុម
៨. ហាបាគុក
៩. សេផានា
១០. ហាកាយ
១១. សាការី
១២. ម៉ាឡាគី

ប្រហែល៤០០ឆ្នាំ
រវាងសេចក្ដីសញ្ញា
ទាំងពីរ

សញ្ញាថ្មីលាក់ទុកនៅក្នុងសញ្ញាចាស់
ឯសញ្ញាចាស់គឺស្ថិតនៅក្នុងការបើកសម្ដែងខាងសញ្ញាថ្មី

## សញ្ញាថ្មី (២៧កណ្ឌ)

### ប្រវត្តិសាស្ត្រ (៥កណ្ឌ)

**ដំណឹងល្អ**

១. ម៉ាថាយ
២. ម៉ាកុស
៣. លូកា
៤. យ៉ូហាន

**ប្រវត្តិនៃក្រុមជំនុំដំបូង**

១. កិច្ចការ

### សំបុត្រ (២១កណ្ឌ)

**សំបុត្ររបស់សាវ័ក ប៉ុល**

១. រ៉ូម
២. ១កូរិនថូស
៣. ២កូរិនថូស
៤. កាឡាទី
៥. អេភេសូរ
៦. ភីលីព
៧. កូល៉ុស
៨. ១ថែស្សាឡូនីច
៩. ២ថែស្សាឡូនីច
១០. ១ធីម៉ូថេ
១១. ២ធីម៉ូថេ
១២. ទីតុស
១៣. ភីលេម៉ូន

**សំបុត្រទូទៅ**

១. ហេព្រើរ
២. យ៉ាកុប
៣. ១ពេត្រុស
៤. ២ពេត្រុស
៥. ១យ៉ូហាន
៦. ២យ៉ូហាន
៧. ៣យ៉ូហាន
៨. យូដាស

### ពាក្យទំនាយ (១កណ្ឌ)

១. វិវរណៈ

ព្រះជាម្ចាស់ប្រើមនុស្សជាង៤០នាក់ផ្សេងគ្នា លើរយៈពេល១៥០០ឆ្នាំ (គឺពីឆ្នាំ ១៤០០ មុន គ.ស-៩០ នៃគ.ស) ក្នុងការសរសេរព្រះគម្ពីរ — ២ពេត្រុស ១:២០-២១

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

១. "ក" ជាគំនិតទី១នៃប្រយោគ។
២. "ខ" ជាគំនិតទី២នៃប្រយោគ។

# របៀបដែលព្រះគម្ពីរបានក្លាយមកជារបស់យើង

**អក្សរដៃដើម**

ច្បាប់ដើមជាអក្សរដៃ ចាប់ពីអំឡុងឆ្នាំ ១៥០០ មុន គ.ស ដល់ឆ្នាំ ១០០ នៃគ.ស
មានកិច្ចការ៦៦ដាច់ដោយឡែកពីគ្នា។ អ្នកនិពន្ធខ្លះគេមិនស្គាល់។

↙ ↘

**អក្សរដៃជាភាសាដើម** **ការបកប្រែជាភាសាដទៃផ្សេងៗ និងសម្រង់ពាក្យសម្ដី**

↙ ↘

១៣២ មុន គ.ស៖ ព្រះគម្ពីរសញ្ញាចាស់មានគេបកប្រែពីភាសា ហេព្រើរ
ទៅជាភាសា ក្រិក ដែលមានឈ្មោះថា សាប់ទូអាចែនថ៍ (Septuagint)។

↓

១០០-២០០ នៃគ.ស៖ ព្រះគម្ពីរមានគេបកប្រែជាភាសា ស៊ីរី ដែលមានឈ្មោះថា ភីហ្ស៊ីតា (The Peshitta)។

↓

៣៨៥-៤០៤ នៃគ.ស៖ ព្រះគម្ពីរ វ៉ាលហ្គេត (The Vulgate) ជាការបកប្រែរបស់លោក យេរ៉ូម (Jerome)
ជាភាសាឡាតាំង។

↓

៤១១, ៤៣៤ នៃគ.ស៖ ព្រះគម្ពីរបកប្រែដោយលោក ម៉ូសេ ដែលមកពីទីក្រុង ខ័រូណេ (Moses of Chorene)
ជាភាសា អារមេនី គាត់បានបញ្ចប់នៅអំឡុងឆ្នាំ ៤១១។ បន្ទាប់មកលោក ចន ដែលមកពីទីក្រុង អេហ្គេហ្គាថស៍
(John of Egheghiatz) និង លោក យ៉ូសែប ដែលមកពីទីក្រុង ប៉ែកហ្គីន (Joseph of Baghin) គឺជាអ្នកកែសម្រួលឡើងវិញ
ហើយបញ្ចប់នៅអំឡុងឆ្នាំ ៤៣៤។

↓

១៣៨២ នៃគ.ស៖ បកប្រែចប់សព្វគ្រប់ដោយលោក ចន វីខ្លីហ្វ (John Wycliffe) និងអ្នកដើរតាម។

↓

១៨១៩ នៃគ.ស៖ លោក រ៉ូប៊ឺត មោរីស័ន (Robert Morrison) ជាអ្នកបកប្រែព្រះគម្ពីរភាសា ចិន។

↓

១៨១៩ នៃគ.ស៖ លោក វីលាម ខារី (William Carey) ជាអ្នកបកប្រែព្រះគម្ពីរទៅជាភាសា បេន្គាលី, អូរីយ៉ា, ម៉ារាធី, ហិណ្ឌូ,
អសាម និង ភាសាសំស្ក្រឹត។ ហើយគាត់ក៏បានបកប្រែ ផ្នែកខ្លះនៃព្រះគម្ពីរជា២៩ភាសាផ្សេងទៀតផងដែរ។

↓

១៨៩៩ នៃគ.ស៖ សមាគមន៍ព្រះគម្ពីរជនជាតិអង់គ្លេស អន្តរជាតិ (British & Foreign Bible Society)
ជាអ្នកបកប្រែកណ្ឌគម្ពីរ លូកាជាភាសាខ្មែរ។

↓

**ការរកឃើញជាច្រើនថែមទៀត** ➔ ១៩៤៧ នៃគ.ស៖ គេបានរកឃើញ ក្រាំងសមុទ្រស្លាប់ (Dead Sea Scrolls)

↓

១៩៥៤ នៃគ.ស៖ លោក អាធ័រ ហែមមិណ (Arthur Hammond) ជាអ្នកបកប្រែព្រះគម្ពីរជាភាសាខ្មែរទាំងមូល។

↓

១៩៩៧ នៃគ.ស៖ សមាគមន៍ព្រះគម្ពីរកម្ពុជា ជាអ្នកបកប្រែព្រះគម្ពីរជាភាសាខ្មែរសម្រាយ។

↓

២០០៥ នៃគ.ស៖ សមាគមន៍ព្រះគម្ពីរកម្ពុជា ជាអ្នកបកប្រែព្រះគម្ពីរដ៏វិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន។

↓

២០១២ នៃគ.ស៖ អង្គការព្រះបន្ទូលនៃជីវិត ជាអ្នកបកប្រែព្រះគម្ពីរគ្រីស្ទបរិស័ទខ្មែរសញ្ញាថ្មី។

* នៅត្រង់ទំព័រនេះយើងបានបញ្ចូលឈ្មោះព្រះគម្ពីរដែលបកប្រែជាភាសាខ្មែរ និងភាសាផ្សេងៗដែលនៅក្បែរប្រទេសកម្ពុជា។

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

## មេរៀនទី២

# វិធីយល់ដឹងដើម្បីស្គាល់ព្រះគម្ពីរ

**ខគម្ពីរចងចាំ៖ ២ធីម៉ូថេ ២:១៥**
ចូរខំប្រឹងនឹងថ្វាយខ្លួនដល់ព្រះ ទុកជាមនុស្សដែលបានល្បងលជាប់ហើយ ជាអ្នកធ្វើការដែលមិនត្រូវខ្មាសឡើយ ដោយកាត់ស្រាយព្រះបន្ទូលនៃសេចក្តីពិតយ៉ាងត្រឹមត្រូវ។

"មធ្យោបាយ" នៃការរៀន និងការអនុវត្តព្រះបន្ទូលនៅក្នុងជីវិតគឺជាការមួយដែលគ្រប់ទាំងគ្រីស្ទបរិស័ទគួរដឹង។ នៅក្នុងមេរៀននេះមានវិធីប្រាំយ៉ាងដែលអាចធ្វើឲ្យចិត្តគំនិតលោកអ្នកនៅជាប់នឹងព្រះបន្ទូលដែលជាព្រះគម្ពីរ៖ ការឮ ការអាន ការសិក្សា ការទន្ទេញចាំមាត់ និងការសញ្ជឹងគិត។ សូមប្រៀបធៀបវិធីប្រាំយ៉ាងទាំងនេះ ស្តីពីការរៀនព្រះបន្ទូលទៅនឹងម្រាមដៃនៅលើដៃរបស់លោកអ្នក។ ប្រសិនបើលោកអ្នកកាន់ព្រះគម្ពីរដោយប្រើម្រាមតែពីរ នោះវាងាយនឹងរបូតចេញពីដៃរបស់លោកអ្នកណាស់។ ប៉ុន្តែប្រសិនបើលោកអ្នកប្រើម្រាមច្រើនជាងនោះ នោះកម្លាំងនៃការចាប់កាន់ព្រះគម្ពីរកាន់តែខ្លាំងជាងមុន។

ចំណែកខាងឯវិញ្ញាណវិញក៏ដូច្នោះដែរ ប្រសិនបើមនុស្សម្នាក់គាត់ស្តាប់ អាន សិក្សាស្វែងយល់ ទន្ទេញចាំមាត់ ហើយនិងសញ្ជឹងគិតលើព្រះបន្ទូល នោះការចាប់កាន់សេចក្តីពិតពីព្រះបន្ទូលក៏កាន់តែរឹងមាំដែរ ចំណុចទាំងនោះគឺជាផ្នែកនៃជីវិតរបស់គាត់ហើយ។ ដូចជាមេដៃដែលត្រូវការសហប្រតិបត្តិការជាមួយនឹងម្រាមផ្សេងៗទៀតផងដែរ ដើម្បីកាន់ឲ្យបានជាប់ល្អ។ ដូចគ្នាផងដែរ ការសញ្ជឹងគិតលើព្រះបន្ទូលរួមផ្សំជាមួយនឹងការទន្ទេញចាំមាត់ គឺជាចំណុចដ៏សំខាន់ក្នុងការចាប់កាន់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ឲ្យបានណែន។

**វិធីសាស្ត្រប្រាំយ៉ាងក្នុងការយល់ដឹងពីព្រះគម្ពីរ៖**

១. **ឮ** ព្រះគម្ពីរ (រ៉ូម ១០:១៧)
២. **អាន** ព្រះគម្ពីរ (វិវរណៈ ១:៣)
៣. **សិក្សា** ព្រះគម្ពីរ (កិច្ចការ ១៧:១១)
៤. **ទន្ទេញចាំមាត់** ព្រះគម្ពីរ (ទំនុកដំកើង ១១៩:៩-១១)
៥. **សញ្ជឹងគិត** ព្រះគម្ពីរ (ទំនុកដំកើង ១:២-៣)

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

## I. ហេតុផលនៃការយល់ដឹងពីព្រះគម្ពីរ

ចូរសរសេរហេតុផលប្រាំយ៉ាងពីប្រយោជន៍នៃការយល់ដឹងព្រះបន្ទូល៖

ក) ២ធីម៉ូថេ ២:១៥ ____________________

ខ) ១ពេត្រុស ២:២ ____________________

គ) ទំនុកដំកើង ១១៩:១១ ____________________

ឃ) ទំនុកដំកើង ១១៩:៣៨ ____________________

ង) ទំនុកដំកើង ១១៩:១០៥ ____________________

---

មូលហេតុដែលយើងសិក្សាព្រះបន្ទូល ពីព្រោះព្រះបន្ទូលផ្តល់ផលប្រយោជន៍គ្រប់គ្រាន់សម្រាប់ជីវិតយើង។

*«គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្តាលឲ្យតែងទេ ក៏មានប្រយោជន៍សំរាប់ការបង្រៀន ការរំឭកឲ្យដឹងខ្លួន ការប្រដៅដំរង់ និងការបង្ហាត់ខាងឯសេចក្តីសុចរិត»* (២ធីម៉ូថេ ៣:១៦)។

---

## II. វិធីយល់ដឹងពីព្រះគម្ពីរ

### ក) ស្តាប់ព្រះបន្ទូល

«ដូច្នេះ សេចក្តីជំនឿកើតឡើងដោយឮ ហើយដែលឮនោះ គឺដោយសារព្រះបន្ទូលនៃព្រះ» (រ៉ូម ១០:១៧)។

១. តើព្រះយេស៊ូវបានមានបន្ទូលថា នរណាស័ក្តិសមនឹងទទួលបានព្រះពរ (លូកា ១១:២៨)?

____________________

២. តើក្នុងការប្រកាសព្រះបន្ទូល គ្រូគង្វាល និងគ្រូបង្រៀនគួរធ្វើអ្វីខ្លះ (នេហេមា ៨:៧-៨)?

____________________

### ខ) អានព្រះបន្ទូល

«មានពរហើយ អ្នកណាដែលមើល និងអស់អ្នកដែលស្តាប់ពាក្យទំនាយទាំងនេះ ហើយប្រព្រឹត្តតាមសេចក្តីទាំងប៉ុន្មាន ដែលកត់ទុកនេះដែរ ដ្បិតឯពេលវេលា នោះជិតដល់ហើយ» (វិវរណៈ ១:៣)។

១. ចូរសរសេរកណ្ឌគម្ពីរ វិវរណៈ ១:៣ តាមគំនិតផ្ទាល់របស់លោកអ្នក៖

____________________

____________________

____________________

២. តើសាវ័ក ប៉ុល បានប្រាប់លោក ធីម៉ូថេ ឲ្យយកចិត្តទុកដាក់ទៅលើអ្វី (១ធីម៉ូថេ ៤:១៣)?

---

ប្រសិនបើលោកអ្នកមិនទាន់មានផែនការអានព្រះបន្ទូលជាប្រចាំថ្ងៃទេ លោកអ្នកអាច ចាប់ផ្តើមអានជាមួយគម្ពីរដំណឹងល្អ ម៉ាកុស ឬ យ៉ូហានសិន។ ការអានពីរជំពូកជា រៀងរាល់ថ្ងៃ នោះលោកអ្នកនឹងបញ្ចប់គម្ពីរសញ្ញាថ្មីទាំងមូលក្នុងរយៈពេល តែក្នុង១៩សប្តាហ៍ប៉ុណ្ណោះ!

---

## គ) សិក្សាព្រះបន្ទូល

នៅពេលដែលសាវ័ក ប៉ុល បានចាកចេញពីទីក្រុងថែស្សាឡូនីច គាត់ក៏បានធ្វើដំណើរទៅទីក្រុងបេរា ហើយបានចែកចាយដំណឹងល្អដល់ពួកអ្នកមិនជឿដែលជាសាសន៍យូដា។ អ្វីដែលគាត់បានជួបប្រទះគឺថា ពួកគេ «...មានចិត្តល្អជាងពួកអ្នកនៅថែស្សាឡូនីច គេប្រុងប្រៀបសព្វគ្រប់នឹងទទួលព្រះបន្ទូល ក៏ពិចារណាមើលគម្ពីររាល់តែថ្ងៃ ឲ្យបានដឹងជាសេចក្តីទាំងនោះត្រូវឬមិនត្រូវ» (កិច្ចការ ១៧:១១)។

អាកប្បកិរិយាក្នុងការសិក្សាព្រះគម្ពីរ៖

១. យោងតាមកណ្ឌគម្ពីរ កិច្ចការ ១៧:១១ តើលក្ខណៈពីរយ៉ាងដែលពួកអ្នកក្រុងបេរាបានបើកបង្ហាញនៅពេលដែលពួកគេបានទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់មានអ្វីខ្លះ?

២. តើយើងគួរស្វែងរកដើម្បីឲ្យបានប្រាជ្ញា ឬក៏ការយល់ដឹងយ៉ាងដូចម្តេច (សុភាសិត ២:៤)?

---

ការសិក្សាព្រះបន្ទូលគឺមិនមែនគ្រាន់តែអានព្រះគម្ពីរតែប៉ុណ្ណោះទេ វាទាមទារឲ្យ មានការសង្កេត ការកាត់ស្រាយ និងការអនុវត្តដោយប្រុងប្រយ័ត្ន។ ការអានអាច ផ្តល់នូវទស្សនៈទូទៅដល់លោកអ្នក ប៉ុន្តែការសិក្សាអាចជួយលោកអ្នកក្នុងការគិត ការយល់ដឹង និងការអនុវត្តនូវអ្វីៗដែលលោកអ្នកអានមកក្នុងជីវិត។

---

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

**ឃ) ទន្ទេញព្រះបន្ទូល**

"មនុស្សកំឡោះនឹងសំអាតផ្លូវដែលខ្លួនប្រព្រឹត្តដោយសារអ្វី គឺដោយប្រយ័តនឹងប្រព្រឹត្តតាមព្រះបន្ទូលនៃទ្រង់...ទូលបង្គំបានកំណត់ចាំព្រះបន្ទូលទ្រង់ទុកនៅក្នុងចិត្ត ប្រយោជន៍កុំឲ្យទូលបង្គំធ្វើបាបនឹងទ្រង់ឡើយ" (ទំនុកដំកើង ១១៩:៩, ១១)។

១. តើព្រះជាម្ចាស់បានបង្គាប់ដល់ជនជាតិអ៊ីស្រាអែលឲ្យចងចាំនូវព្រះបន្ទូលរបស់ទ្រង់យ៉ាងដូចម្ដេចខ្លះ?

ក) ចោទិយកថា ១១:១៨ក ______

ខ) ចោទិយកថា ១១:១៨ខ ______

២. សូមអានកណ្ឌគម្ពីរ ម៉ាថាយ ៤:៤, ៧, ១០។

ក) នៅពេលដែលព្រះយេស៊ូវបានប្រឈមមុខនឹងសាតាំងបីដង តើទ្រង់បានធ្វើអ្វីខ្លះដើម្បីយកឈ្នះលើសេចក្ដីល្បួង?

______

______

ខ) តើលោកអ្នកអាចយកឧទាហរណ៍នេះមកអនុវត្តសម្រាប់ជីវិតផ្ទាល់ខ្លួនរបស់លោកអ្នកយ៉ាងដូចម្ដេច?

______

______

៣. សូមសរសេរកណ្ឌគម្ពីរ ទំនុកដំកើង ៤០:៨ តាមគំនិតផ្ទាល់របស់លោកអ្នក៖

______

______

______

______

---

ការទន្ទេញព្រះបន្ទូលនឹងមានភាពងាយស្រួល ប្រសិនបើលោកអ្នកមានគោលដៅជាក់លាក់។ ការយល់ពីអត្ថន័យ ឬពីការអនុវត្តតាមព្រះបន្ទូលនឹងធ្វើឲ្យការទន្ទេញរបស់លោកអ្នកកាន់តែមានភាពងាយស្រួល។

---

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

### ង) សញ្ជឹងគិតព្រះបន្ទូល

«មានពរហើយ អ្នកណាដែលមិនដើរតាមដំបូន្មានរបស់មនុស្សអាក្រក់ ក៏មិនឈរនៅក្នុងផ្លូវរបស់មនុស្សមានបាប ឬអង្គុយនៅជាមួយនឹងពួកមនុស្សដែលមើលងាយ អ្នកនោះត្រេកអរតែនឹងក្រិត្យវិន័យរបស់ព្រះយេហូវ៉ាវិញ ក៏រំពឹងគិតក្នុងក្រិត្យវិន័យទ្រង់ទាំងយប់ទាំងថ្ងៃដែរ អ្នកនោះនឹងដូចជាដើមឈើ ដែលដុះនៅក្បែរផ្លូវទឹក ដែលបង្កើតផលតាមរដូវកាល ហើយស្លឹកក៏មិនចេះស្រពោនឡើយ ឯការអ្វីដែលអ្នកនោះធ្វើ នោះនឹងចំរើនឡើងទាំងអស់»
(ទំនុកដំកើង ១:១-៣)។

ការសញ្ជឹងគិតគឺជាការឆ្លុះបញ្ចាំងទៅលើបទគម្ពីរដោយការអធិស្ឋានរួមជាមួយនឹងទស្សនៈឆ្ពោះទៅរកការយល់ដឹង និងការអនុវត្ត។ សូមផ្តល់នូវគំនិតដែលមានការអធិស្ឋាន ចំពោះព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាមួយនឹងគោលដៅនៃការប្រតិបត្តិជីវិតរបស់លោកអ្នកតាមព្រះហឫទ័យព្រះជាម្ចាស់។

១. ការសញ្ជឹងគិតលើបទគម្ពីរ អាចប្រព្រឹត្តទៅបានលុះត្រាតែលោកអ្នកៈ

ក) ឮសេចក្តីអធិប្បាយព្រះបន្ទូល

ខ) អានព្រះគម្ពីរ

គ) អធិស្ឋានពីអ្វីដែលលោកអ្នកកំពុងសិក្សា

ឃ) សញ្ជឹងគិតទៅលើខគម្ពីរដែលលោកអ្នកបានទន្ទេញចាំ

២. តើការសញ្ជឹងគិតអាចជួយលោកអ្នកបានយ៉ាងដូចម្តេច (យ៉ូស្វេ ១:៨)? ______________

________________________________________

________________________________________

៣. តើលោកអ្នកគិតថា ព្រះបន្ទូលរបស់ព្រះជាម្ចាស់អាចជះឥទ្ធិពលលើការនិយាយស្តី និងការប្រព្រឹត្តរបស់លោកអ្នកដែរឬទេ? ដោយរបៀបណា (លូកា ៦:៤៥)? ____________

________________________________________

________________________________________

________________________________________

៤. ក្រៅពីការយកចិត្តទុកដាក់ទៅលើការសិក្សាព្រះបន្ទូលរបស់ព្រះជាម្ចាស់ តើយើងគួរធ្វើអ្វីទៀត ដើម្បីស្គាល់ព្រះបន្ទូលឲ្យកាន់តែច្បាស់ (ទំនុកដំកើង ១១៩:៧៣, ១២៥)?

________________________________________

________________________________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

## III. ដំណើរការនៃការសិក្សាព្រះគម្ពីរ

### ក) ជំហានទី១៖ ការរៀបចំ

១. តើយើងគួរធ្វើអ្វីខ្លះ មុនពេលសិក្សាបទគម្ពីរ (១ពេត្រុស ២:១-២)?

______________________________

______________________________

______________________________

______________________________

២. តើលោកអ្នកគួរអធិស្ឋានពីអ្វីខ្លះ ខណៈពេលដែលកំពុងរៀបចំខ្លួនដើម្បីសិក្សាព្រះបន្ទូលរបស់ព្រះជាម្ចាស់ (កូល៉ុស ១:៩-១០)?

______________________________

______________________________

---

សូមចំណាយពេលអធិស្ឋានមុននឹងសិក្សា។ លន់តួបាប ហើយទូលសូមព្រះវិញ្ញាណបរិសុទ្ធ៖ «*សូមបំភ្លឺភ្នែកទូលបង្គំ ឲ្យបានឃើញសេចក្តីអស្ចារ្យ នៅក្នុងក្រឹត្យវិន័យរបស់ទ្រង់*» (ទំនុកដំកើង ១១៩:១៨)។

---

### ខ) ជំហានទី២៖ ការពិនិត្យសង្កេត

"តើមានអ្វីកើតឡើងនៅក្នុងវគ្គនេះ? តើខ្ញុំឃើញអ្វីខ្លះ?"

១. នៅពេលដែលលោកអ្នកអាន សូមសួរសំណួរ ហើយសរសេរវាចុះដូចជា៖ នរណា? តើអ្វី? នៅឯណា? នៅពេលណា?

២. ពេលដែលលោកអ្នកពិនិត្យមើល សូមរកមើល៖

*ចំណាំ៖ បញ្ជីខាងក្រោមនេះ គឺជាឧទាហរណ៍ខ្លះៗស្តីពីអ្វីដែលលោកអ្នកត្រូវស្វែងរក នៅពេលដែលលោកអ្នកពិនិត្យសង្កេតទៅលើបទគម្ពីរណាមួយ។ ចូរធ្វើតាមសម្រួល! មិនត្រូវឆាប់បោះបង់ចោលឡើយ!*

ក) ពាក្យគន្លឹះ

ខ) កម្មវត្ថុដែលសំខាន់ (មនុស្ស ប្រធានបទ)

គ) ពាក្យបង្គាប់បញ្ជា (កិរិយាសព្ទពិសេស)

ឃ) ការព្រមាន

ង) ពាក្យ ឬឃ្លាច្រំដែលៗ

ច) ការប្រៀបធៀប (វត្ថុដែលមានលក្ខណៈស្រដៀងគ្នា និងវត្ថុដែលមានលក្ខណៈខុសគ្នា)

ឆ) សំណួរចម្លើយដែលបានផ្តល់ជូន

ជ) អ្វីៗដែលមិនធម្មតា ឬនឹកស្មានមិនដល់

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

**គ) ជំហានទី៣៖ ការកាត់ស្រាយ**

"តើការកាត់ស្រាយមានន័យដូចម្ដេច?"

១. បទគម្ពីរអាចបញ្ជាក់បានយ៉ាងច្បាស់។ តើព្រះជាម្ចាស់បានចាត់នរណាមកបង្រៀនយើង (១យ៉ូហាន ២:២៧)? ________________________________

២. ចាប់ផ្ដើមដោយការសួរសំណួរកាត់ស្រាយ៖

ក) តើអ្វីជាសារៈសំខាន់នៃ៖

(១) ពាក្យដែលបានផ្ដល់ឲ្យ (ជាពិសេសកិរិយាសព្ទ)?

(២) ឃ្លាដែលបានផ្ដល់ឲ្យ?

(៣) ឈ្មោះ និងចំណងជើង?

(៤) កាលបរិច្ឆេទ?

(៥) ផ្សេងៗ?

ខ) តើអត្ថន័យនៃពាក្យនោះមានន័យដូចម្ដេច?

គ) ហេតុអ្វីបានជាអ្នកនិពន្ធនិយាយពាក្យនេះ?

ឃ) តើពាក្យនេះ ឃ្លានេះ និងឈ្មោះនេះមានការជាប់ទាក់ទងទៅនឹងអ្វី?

៣. ដើម្បីរកឲ្យឃើញចម្លើយទៅនឹងសំណួរកាត់ស្រាយរបស់លោកអ្នក ចូរប្រើ៖

ក) បរិបទដែលជាខគម្ពីរមុន និងក្រោយបទគម្ពីរដែលលោកអ្នកកំពុងតែសិក្សា

ខ) និយមន័យនៃពាក្យទាំងឡាយ

គ) វេយ្យាករណ៍ និងទម្រង់ប្រយោគ

ឃ) ព្រះរាជសារនៃបទគម្ពីរផ្សេងទៀត

ង) សម្ភារៈសិក្សាព្រះគម្ពីរ ដូចជាសៀវភៅ៖

(១) វចនានុក្រមព្រះគម្ពីរ (Bible dictionaries)

(២) វិជ្ជាសមោធាន (Concordances)

(៣) មគ្គុទេសក៍សិក្សាព្រះគម្ពីរ (Bible handbooks)

(៤) សព្វវចនាធិប្បាយព្រះគម្ពីរ (Bible encyclopedias)

(៥) អត្ថាធិប្បាយព្រះគម្ពីរ (Bible commentaries)

៤. ពេលកាត់ស្រាយព្រះបន្ទូល ចូរចាំថា៖

ក) គ្រប់ទាំងបទគម្ពីរនឹងទៅស្របជាមួយគ្នា ហើយក៏មិនមានការប្រឆាំងនឹងគ្នាដែរ។

ខ) ដើម្បីឲ្យអត្ថបទកាត់ស្រាយពីបរិបទផ្ទាល់ នោះត្រូវឲ្យអត្ថបទគម្ពីរកាត់ស្រាយហើយសរុបដោយផ្ទាល់ តែសូមលោកអ្នកកុំសរុបសេចក្ដីដែលមិនមែនជាគោលគំនិតរបស់អ្នកនិពន្ធឡើយ។

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

រាល់អត្ថបទនៃបទគម្ពីរនីមួយៗគឺមានការកាត់ស្រាយដ៏ត្រឹមត្រូវតែមួយគត់ដែលជាគោលបំណងដើមរបស់អ្នកនិពន្ធចង់មានន័យ។

**ឃ) ជំហានទី៤៖ ការអនុវត្ត**

"តើការនេះនឹងមានឥទ្ធិពលអ្វីមកលើជីវិតរបស់ខ្ញុំ?"

ដំណើរឆ្ពោះទៅមុខនៃការសិក្សាព្រះគម្ពីរផ្នែកនេះដកយកនូវសេចក្តីពិតដែលបានអង្កេតរួច និងស្វែងរកដើម្បីផ្សារភ្ជាប់សេចក្តីពិតទាំងនោះទៅនឹងជីវិត និងការប្រព្រឹត្តប្រចាំថ្ងៃ។

១. នៅពេលដែលយើងបានឮព្រះបន្ទូលរបស់ព្រះជាម្ចាស់ម្តងហើយ តើយើងគួរតែឆ្លើយតបវិញយ៉ាងដូចម្តេច (យ៉ាកុប ១:២២)?

________________________________________

________________________________________

២. ចូរចងចាំសំណួរទាំងប្រាំខាងក្រោមនេះ ដើម្បីអនុវត្តនូវអ្វីៗដែលលោកអ្នកបានរៀនចេញពីព្រះគម្ពីរ៖

**មានបាប**ដែលខ្ញុំត្រូវបោះចោលទេ?

**មានសេចក្តីសន្យា**ដែលខ្ញុំត្រូវឆក់យកមកទុកទេ?

**មានគំរូ**ដែលខ្ញុំត្រូវដើរតាមទេ?

**មានបញ្ញត្តិ**ដែលខ្ញុំត្រូវស្តាប់តាមទេ?

**មានការដែលនាំឲ្យជំពប់ដួល**ដែលខ្ញុំត្រូវចៀសវាងទេ?

បទគម្ពីរនីមួយៗមាន**ការកាត់ស្រាយ**ដ៏ត្រឹមត្រូវតែមួយ ប៉ុន្តែមាន**ការអនុវត្ត**ជាច្រើន។

**ង) ជំហានទី៥៖ ការរៀនហើយរៀនទៀត**

ការសិក្សាព្រះគម្ពីរគឺជាការសិក្សាម្តងហើយម្តងទៀត។ នៅពេលដែលលោកអ្នកសិក្សាទៅលើខគម្ពីរណាមួយ លោកអ្នកនឹងប្រើជំហានទី២ ទី៣ និងទី៤ជាច្រើនដងច្រើនសារ។ លោកអ្នកត្រូវ**ពិនិត្យសង្កេត**ឲ្យបានល្អិតល្អន់ បន្ទាប់មកត្រូវ**កាត់ស្រាយ** ហើយត្រូវ**យកទៅអនុវត្ត**។ លោកអ្នកអាចប្រើជំហានទាំងនេះជាមួយ ពាក្យ ឃ្លា និងគំនិតនីមួយៗក្នុងការកាត់ស្រាយព្រះគម្ពីរបាន។ កាលណាលោកអ្នកកាន់តែធ្វើតាមរបៀបនេះពីមួយខទៅមួយខ នោះអត្ថន័យដ៏ជ្រាលជ្រៅនៃខគម្ពីរនោះក៏កាន់តែបង្ហាញឲ្យលោកអ្នកយល់កាន់តែច្បាស់ឡើងៗ។

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

## IV. លំហាត់

“ចូរស្វែងរកនគរ និងសេចក្ដីសុចរិតនៃព្រះជាមុនសិន ទើបគ្រប់របស់ទាំងនោះ នឹងបានប្រទានមកអ្នករាល់គ្នាថែមទៀតផង” (ម៉ាថាយ ៦:៣៣)។

### សូមអនុវត្តជាមួយនឹងកណ្ឌគម្ពីរ ម៉ាថាយ ៦:៣៣ និងតារាងលំហាត់នៅទំព័រ២៨៖

ក) ចូរសង្កេតឲ្យបានច្រើនដងតាមដែលអាចធ្វើបាន ហើយសរសេរការសង្កេតទាំងអស់របស់លោកអ្នកក្នុងក្រឡោន “ការពិនិត្យសង្កេត” នៅទំព័រ២៨-២៩។

ខ) សូមសរសេរពី “សំណួរកាត់ស្រាយ” ស្ដីពីការពិនិត្យសង្កេតរបស់លោកអ្នក។

គ) សូមសរសេរពីអត្ថន័យនៃការពិនិត្យសង្កេត និងការកាត់ស្រាយរបស់លោកអ្នកនៅក្នុងក្រឡោន “ការកាត់ស្រាយ” នៅទំព័រ២៨-២៩។

ឃ) ពេលលោកអ្នកបានបញ្ចប់ការពិនិត្យសង្កេត និងការកាត់ស្រាយចប់សព្វគ្រប់ហើយ សូមបំពេញនៅក្នុងវគ្គ “ការអនុវត្ត” នៅទំព័រ២៩។

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

**“ចូរស្វែងរកនគរ និងសេចក្តីសុចរិតនៃព្រះជាមុនសិន ទើបគ្រប់របស់ទាំងនោះ នឹងបានប្រទានមកអ្នករាល់គ្នាថែមទៀតផង” (ម៉ាថាយ ៦:៣៣)។**

*ចំណាំ៖ ចំណុចទាំងប្រាំមួយដំបូងដែលបានបំពេញរួចខាងក្រោមនេះគឺជាឧទាហរណ៍។*

| ការពិនិត្យសង្កេត | សំណួរកាត់ស្រាយ | ការកាត់ស្រាយ |
|---|---|---|
| ១. ខចាប់ផ្តើមជាមួយនឹងកិរិយានុគ្រោះ “ចូរ”។ | ១. តើកិរិយានុគ្រោះ “ចូរ” មានន័យដូចម្តេច? | ១. ជាពាក្យសម្រាប់ប្រើនាំមុខ ឬជាជំនួយកិរិយាសព្ទ ដើម្បីបញ្ជាក់ថា ឃ្លានោះជាឃ្លាបញ្ជា។ |
| ២. ពាក្យគន្លឹះ “ស្វែងរក” | ២. តើពាក្យ “ស្វែងរក” មានន័យដូចម្តេច? ហើយតើពាក្យនេះតម្រូវឲ្យមានសកម្មភាពបែបណា? | ២. មានន័យថា ដេញតាម ឬស្រាវជ្រាវ។ វាគឺជាពាក្យបង្គាប់។ |
| ៣. កិរិយាសព្ទ “ស្វែងរក” គឺស្ថិតក្នុងប្រយោគបច្ចុប្បន្នកាល។ | ៣. តើប្រយោគបច្ចុប្បន្នកាលចង្អុលបង្ហាញពីអ្វី? | ៣. ខ្ញុំដាច់ខាតត្រូវតែស្វែងរកឥឡូវនេះ។ |
| ៤. ពាក្យគន្លឹះបន្ទាប់គឺ “នគរ”។ | ៤. តើពាក្យថា “នគរ” ចង់និយាយពីអ្វី? | ៤. គឺជាការគ្រប់គ្រងដ៏មហិមា ឬអាណាចក្រលើតំបន់ដ៏ជាក់លាក់ណាមួយ។ |
| ៥. សព្វនាមកម្មសិទ្ធិ “នៃព្រះ” គឺបាននាំមុខពាក្យថា “នគរ”។ | ៥. តើជានគររបស់អ្នកណា? តើពាក្យថា “នៃព្រះ” ចង់សំដៅលើអ្នកណា? | ៥. សូមមើលខ៣២ ពាក្យថា “នៃព្រះ” សំដៅលើ “ព្រះវរបិតា”។ នគរនោះគឺជានគររបស់ព្រះវរបិតា។ |
| ៦. សូមកត់សម្គាល់ទៅលើការប្រើពាក្យថា “ជាមុនសិន” បន្ទាប់ពីពាក្យ “ស្វែងរក”។ | ៦. តើសារៈសំខាន់របស់ពាក្យ “ជាមុនសិន” នោះគឺជាអ្វី? | ៦. កំណត់យកជាអាទិភាព។ ដាច់ខាតត្រូវតែស្វែងរកជាអាទិភាពដំបូងបំផុត។ |
| ៧. | ៧. | ៧. |
| ៨. | ៨. | ៨. |

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

| ការពិនិត្យសង្កេត | សំណួរកាត់ស្រាយ | ការកាត់ស្រាយ |
|---|---|---|
| ៩. | ៩. | ៩. |
| ១០. | ១០. | ១០. |
| ១១. | ១១. | ១១. |
| ១២. | ១២. | ១២. |

**ការអនុវត្ត**

សូមសរសេរការអនុវត្តមួយដោយយោងតាមការពិនិត្យសង្កេត និងការកាត់ស្រាយរបស់លោកអ្នក (ដោយយោងតាម សំណួរទាំងប្រាំនៅត្រង់ ឃ) ជំហានទី៤៖ ការអនុវត្តចំណុចទី២)។

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

## V. ការអនុវត្ត

តើលោកអ្នកបានចំណាយពេល ១៦៨ម៉ោងក្នុងមួយសប្តាហ៍របស់លោកអ្នកបានល្អដែរឬទេ?

តើលោកអ្នកគួរផ្លាស់ប្តូរអ្វីខ្លះទេ? តារាងខាងក្រោមនេះនឹងជួយលោកអ្នកឲ្យចេះវិភាគលើទម្លាប់របស់ខ្លួនដើម្បីឲ្យចិត្តគំនិតលោកអ្នកនៅជាប់នឹងព្រះបន្ទូលដែលជាព្រះគម្ពីរ។ ហើយនៅពេលដែលលោកអ្នកបំពេញចំនួនម៉ោងដែលត្រូវចំណាយក្នុងមួយសប្តាហ៍រួចហើយ នោះសូមអធិស្ឋានពីការរៀបចំគោលដៅថ្មីរបស់លោកអ្នកផង។

| **ពេលជាមួយព្រះបន្ទូល** | *កាលវិភាគបច្ចុប្បន្ន* | *គោលដៅ និង គម្រោងថ្មី* |
|---|---|---|
| ការឮព្រះបន្ទូល | | |
| ការអានព្រះបន្ទូល | | |
| ការសិក្សាព្រះបន្ទូល | | |
| ការទន្ទេញព្រះបន្ទូល | | |

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

មេរៀនទី៣

# ព្រះជាម្ចាស់៖ ចរិតលក្ខណៈ និងលក្ខណសម្បត្តិរបស់ទ្រង់

**ខគម្ពីរចងចាំ៖ ១របាក្សត្រ ២៩:១១**
ឱព្រះយេហូវ៉ាអើយ ភាពដ៏ធំនឹងព្រះចេស្តា សិរីល្អ ជ័យជំនះ និងតេជានុភាព នោះសុទ្ធតែជារបស់ផងទ្រង់ ដ្បិតគ្រប់ទាំងអស់ដែលនៅលើមេឃ និងនៅផែនដី ជារបស់ផងទ្រង់ ឱព្រះយេហូវ៉ាអើយ រាជ្យនេះក៏ជារបស់ផងទ្រង់ដែរ ហើយទ្រង់បានដំកើងឡើង ជាប្រធានលើទាំងអស់។

## I. សេចក្តីផ្តើម

សាសន៍ជាច្រើននៅលើសកលលោកយើងសព្វថ្ងៃនេះ គេនិយាយថាមានព្រះច្រើន ហើយក៏មានមតិច្រើនផ្សេងៗគ្នាអំពីលក្ខណៈរបស់ព្រះជាម្ចាស់ (ឬក៏ព្រះផ្សេងៗ) ផងដែរ។ តែផ្ទុយទៅវិញ ព្រះគម្ពីរបានបើកសម្តែងថា ព្រះពិតគឺមានតែមួយ។ ព្រះគម្ពីរក៏មិនដែលព្យាយាមបង្ហាញភស្តុតាងពីព្រះនោះទេ គឺគ្រាន់តែមានជាសេចក្តីបញ្ជាក់មួយយ៉ាងសាមញ្ញថា “កាលដើមដំបូងឡើយ ព្រះ...” (លោកុប្បត្តិ ១:១)។

*“នៅពេលដែលយើងសញ្ជឹងគិតអំពីភាពជាព្រះរបស់ព្រះជាម្ចាស់ នោះប្រៀបបានទៅនឹងការដែលយើងមុជចូលទៅក្នុងសមុទ្រដ៏ធំល្វឹងល្វើយ។ ចូរឲ្យយើងសញ្ជឹងគិត ហើយស្លុងអារម្មណ៍ទៅក្នុងភាពជាព្រះដ៏ធំមហិមារបស់ទ្រង់ នោះលោកអ្នកនឹងមានកម្លាំង ហើយមានភាពស្រស់ស្រាយ ដូចទើបនឹងភ្ញាក់ពីសម្រាន្តដ៏លង់លក់យ៉ាងដូច្នោះដែរ។ គ្មានអ្វីដែលអាចធ្វើឲ្យព្រលឹងរបស់មនុស្សបានសុខស្រួល គ្មានអ្វីដែលអាចនឹងធ្វើឲ្យរលកនៃសេចក្តីទុក្ខ និងភាពសោកសង្រេងរបស់ពួកគេចុះខ្សោយបាននោះឡើយ ហើយក៏គ្មានអ្វីដែលអាចនឹងធ្វើឲ្យមនុស្សមានភាពសុខសាន្តក្នុងការល្បងលយ៉ាងពេញលេញ ដូចការសញ្ជឹងគិតលើភាពជាព្រះរបស់ព្រះជាម្ចាស់ដែរ។”*

— លោក ស៊ី.អេច. ស្ពើចិន (C. H. Spurgeon)
នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៨៥៥

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

ក) តើកណ្ឌគម្ពីរ ទំនុកដំកើង ៨៩:៧-៨ ពណ៌នាពីព្រះជាម្ចាស់យ៉ាងដូចម្តេច?

______________________________

______________________________

ខ) តើមានសេចក្តីថ្លែងបែបណាដែលបានបង្ហាញពីសេចក្តីពិតថា មានព្រះតែមួយនោះ (អេសាយ ៤៣:១០)?

______________________________

______________________________

គ) តើព្រះជាម្ចាស់នឹងមិនព្រមប្រគល់អ្វីឲ្យដល់អ្នកផ្សេងទៀត (អេសាយ ៤២:៨)?

______________________________

## II. សារៈសំខាន់នៃការស្គាល់ព្រះជាម្ចាស់

ក) តើព្រះយេស៊ូវបានប្រៀបធៀបការស្គាល់ព្រះជាម្ចាស់ទៅនឹងអ្វី (យ៉ូហាន ១៧:៣)?

______________________________

ខ) តើការមួយដែលព្រះជាម្ចាស់មានបន្ទូលថា មនុស្សគួរតែអួត ជាជាងការអួតអំពីប្រាជ្ញាអនុភាព ឬការមានបាននោះគឺជាអ្វី (យេរេមា ៩:២៤)?

______________________________

______________________________

______________________________

---

*«ការយល់ដឹងដ៏ត្រឹមត្រូវពីព្រះជាម្ចាស់គឺជាមូលដ្ឋានគ្រឹះ ហើយវាមិនមែនត្រឹមតែជាមូលដ្ឋានគ្រឹះចំពោះប្រព័ន្ធទេវវិទ្យាតែប៉ុណ្ណោះនោះទេ ប៉ុន្តែក៏ជាការអនុវត្តនៃការរស់នៅរបស់គ្រីស្ទបរិស័ទផងដែរ។ ខ្ញុំជឿថាស្ទើរគ្រប់ទាំងកំហុសឆ្គងនៅក្នុងគោលលទ្ធិ ទាំងការបរាជ័យក្នុងការអនុវត្តតាមក្រមសីលធម៌របស់គ្រីស្ទបរិស័ទនោះកើតឡើងដោយសារ មានគំនិតមិនគ្រប់លក្ខណ៍ និងគំនិតមិនថ្លៃថ្នូរអំពីព្រះជាម្ចាស់។»*

— លោក អេ.ដឺបលយូ. ថូសហ្ស៊ែរ (A.W.Tozer)[១]

---

១. ដកស្រង់ចេញពីសៀវភៅ *The Knowledge of the Holy* ដោយ A.W. Tozer, © ១៩៦១ ដោយ Aidan Wilson Tozer។ រក្សាសិទ្ធិដោយ Harper-Collins Publishers Inc។

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

## III. តើមនុស្សម្នាក់អាចស្គាល់ព្រះជាម្ចាស់បានតាមវិធីណា?

ក) តើព្រះយេស៊ូវមានបន្ទូលពីអត្ថន័យនៃការស្គាល់ព្រះជាម្ចាស់យ៉ាងដូចម្ដេច (យ៉ូហាន ១៤:៩-១០)?

ខ) តើសាវ័ក ប៉ុល មានប្រសាសន៍យ៉ាងដូចម្ដេចអំពីព្រះគ្រីស្ទ នៅក្នុងកណ្ឌគម្ពីរ កូល៉ុស ២:៩?

គ) អ្នកសរសេរកណ្ឌគម្ពីរ ហេព្រើរមានប្រសាសន៍ថា ព្រះជាម្ចាស់បានមានបន្ទូលនឹងយើងរាល់គ្នាតាមរយៈព្រះរាជបុត្រារបស់ទ្រង់។ តើគាត់បានពណ៌នាពីព្រះគ្រីស្ទយ៉ាងដូចម្ដេច (ហេព្រើរ ១:៣)?

## IV. លក្ខណសម្បត្តិរបស់ព្រះជាម្ចាស់

### ក) ដូចម្ដេចដែលហៅថា លក្ខណសម្បត្តិ?

លក្ខណសម្បត្តិគឺជាគុណភាពមួយ ឬក៏ចរិតលក្ខណៈដ៏ពិតអំពីនរណាម្នាក់។ ការសិក្សាពីលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់អាចនាំឲ្យយើងមានកម្រិតមួយក្នុងការស្គាល់ពីបុគ្គលភាពរបស់ទ្រង់បាន។ ទោះបីជាមានគំនិតខ្លះហួសពីការយល់ដឹងរបស់យើងក៏ដោយ ក៏គំនិតរបស់យើងចំពោះព្រះជាម្ចាស់ត្រូវតែតាមសេចក្ដីពិត តាមដែលអាចធ្វើទៅបាន។

---

**ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ**

*ចំណាំ៖ ទាំងនេះគឺគ្រាន់តែជាលក្ខណសម្បត្តិមួយចំនួនរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ។*

១. ភាពបរិសុទ្ធ
២. សុចរិត និងយុត្តិធម៌
៣. អធិបតេយ្យភាព
៤. ភាពអស់កល្បជានិច្ច
៥. ភាពមិនប្រែប្រួល
៦. សព្វញ្ញូញាណ
៧. សព្វវត្តមាន
៨. សព្វានុភាព
៩. សេចក្ដីស្រឡាញ់
១០. សេចក្ដីពិត
១១. មេត្តាករុណា

---

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

## ខ) និយមន័យ លក្ខណសម្បត្តិរបស់ព្រះជាម្ចាស់

ទី១៖ សូមអានខគម្ពីរមួយចំនួនខាងក្រោមនេះ បន្ទាប់មកសរសេរនូវផ្នែកនៃខគម្ពីរដែលពណ៌នាបានល្អជាងគេបំផុតពីលក្ខណសម្បត្តិដែលបានផ្ដល់ជូន។

ទី២៖ ដោយសារលោកអ្នកស្គាល់លក្ខណសម្បត្តិនោះ សូមសរសេរពីរបៀបដែលលក្ខណសម្បត្តិនោះបំផ្លាស់បំប្រែជីវិតនៃការរស់នៅរបស់លោកអ្នកនៅក្នុងវគ្គការអនុវត្តផ្ទាល់ខ្លួន។

### ១. ភាពបរិសុទ្ធ

ភាពបរិសុទ្ធនៃលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់មានន័យថា មិនមានសេចក្ដីអាក្រក់ណាមួយនៅក្នុងលោកីយ៍នេះអាចពាល់ទ្រង់ ឬក៏ធ្វើឲ្យប្រឡាក់ប្រឡូសដល់ទ្រង់បាននោះឡើយ។ ទ្រង់បរិសុទ្ធ និងគ្រប់លក្ខណ៍មួយរយភាគរយ។

ក) និក្ខមនំ ១៥:១១ ______________________________

______________________________

ខ) ទំនុកដំកើង ៩៩:៩ ______________________________

______________________________

ពីព្រោះព្រះជាម្ចាស់ទ្រង់បរិសុទ្ធ បានជាទ្រង់តម្រូវឲ្យយើងបរិសុទ្ធដែរ (១ពេត្រុស ១:១៦)។ ព្រះជាម្ចាស់បានញែកយើងជាបរិសុទ្ធទុកសម្រាប់ទ្រង់ ដូច្នេះជីវិតរបស់យើងគឺត្រូវតែជះពន្លឺប្រៀបដូចជាកញ្ចក់ឆ្លុះបញ្ចាំងពីព្រះជាម្ចាស់ដល់លោកីយ៍ដ៏ទុច្ចរិតមួយនេះ។

ការអនុវត្តផ្ទាល់ខ្លួន៖ ______________________________

______________________________

______________________________

______________________________

### ២. សុចរិត និង យុត្តិធម៌

ពាក្យថា សុចរិត និងយុត្តិធម៌គឺចេញមកពីប្រភពដើមនៃពាក្យដែលមានឫសដូចគ្នាមួយនៅក្នុងភាសាដើមនៃកណ្ឌគម្ពីរសញ្ញាថ្មី។ អត្ថន័យនោះគឺ ត្រឹមត្រូវ ឬក៏ទៀងត្រង់។ សេចក្ដីសុចរិតបង្ហាញពីការចុះសម្រុងគ្នាដ៏ល្អឥតខ្ចោះរវាងលក្ខណៈ និងសកម្មភាពរបស់ព្រះជាម្ចាស់។ សេចក្ដីយុត្តិធម៌គឺជារបៀបដែលព្រះជាម្ចាស់បង្កើតជាច្បាប់ដ៏សុចរិតរបស់ទ្រង់។ មិនមានសកម្មភាពណាមួយដែលព្រះជាម្ចាស់ធ្វើក្នុងទំនាក់ទំនងជាមួយមនុស្សដោយល្មើសនឹងច្បាប់មាត្រានៃក្រមសីលធម៌ និងយុត្តិធម៌នោះទេ។

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

មិនមានបញ្ញត្តិច្បាប់ណានៅ**លើ**ព្រះជាម្ចាស់នោះទេ
ប៉ុន្តែមានច្បាប់**នៅក្នុង**ព្រះជាម្ចាស់។[២]

ក) យោងតាមកណ្ឌគម្ពីរ ទំនុកដំកើង ១១៩:១៣៧ សេចក្ដីសុចរិតរបស់ព្រះជាម្ចាស់សម្ដែងឲ្យឃើញនៅក្នុង ______

ខ) យោងតាមកណ្ឌគម្ពីរ ទំនុកដំកើង ៨៩:១៤ សេចក្ដីសុចរិត និងសេចក្ដីយុត្តិធម៌របស់ព្រះជាម្ចាស់គឺជា ______

______

តើខ្នាតនៃភាពត្រឹមត្រូវ និងភាពទៀងត្រង់**របស់លោកអ្នក**ប្រៀបធៀបជាមួយនឹងខ្នាត**របស់ព្រះជាម្ចាស់**មើលទៅដូចម្ដេចដែរ?

ការអនុវត្តផ្ទាល់ខ្លួន៖ ______

______

______

______

______

______

**៣. អធិបតេយ្យភាព**

ពាក្យថា *អធិបតេយ្យភាព* មានន័យថា ចៅហ្វាយ ឬ ខ្ពស់លើសទាំងអស់ អំណាចគ្មានប្រៀប ឬ ឋានៈឧត្ដុង្គឧត្ដមខ្ពស់ជាងគេបំផុតក្នុងចំណោមមុខតំណែងផ្សេងៗទាំងអស់។

ក) អេសាយ ៤៦:៩-១០

______

______

ខ) អេសាយ ៤៥:២៣

______

______

______

២. ដកស្រង់ចេញពីសៀវភៅ *The Zondervan Pictorial Encyclopedia of the Bible*, លេខ៥, កែសម្រួលដោយ Merrill C. Tenny, © ១៩៧៥, ១៩៧៦ ដោយ The Zondervan Corporation។

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

គំនិតនៃអធិបតេយ្យភាពគឺធ្វើឲ្យមានកម្លាំងចិត្ត ដ្បិតគំនិតនោះធានាអះអាងចំពោះគ្រីស្ទបរិស័ទថា មិនមានអ្វីដែលស្ថិតនៅក្រៅការគ្រប់គ្រងរបស់ព្រះជាម្ចាស់ ហើយផែនការរបស់ទ្រង់ក៏មិនដែលថា មិនបានសម្រេចនោះឡើយ (រ៉ូម ៨:២៨)។

ការអនុវត្តផ្ទាល់ខ្លួនៈ

**៤. ភាពអស់កល្បជានិច្ច**

ដោយព្រោះព្រះជាម្ចាស់គឺជាព្រះដ៏គង់នៅអស់កល្បជានិច្ច នោះក៏មិនដែលមានពេលណាមួយដែលទ្រង់មិនគង់នៅនោះឡើយ។ ទ្រង់គ្មានដើម ហើយក៏គ្មានទីបញ្ចប់ដែរ។

ក) អេសាយ ៤៤:៦

ខ) អេសាយ ៤៣:១៣

ពេលវេលាមិនអាចរាប់ជាព្រះជន្មព្រះជាម្ចាស់ឡើយ ដោយសារទ្រង់គង់នៅអស់កល្បជានិច្ច។ ដោយហេតុតែទ្រង់គង់នៅអស់កល្បជានិច្ច ហេតុដូច្នេះហើយ បានជាទ្រង់ជ្រាបពីអតីតកាល និងអនាគតកាលយ៉ាងច្បាស់ដូចបច្ចុប្បន្ននេះផងដែរ។ យោងតាមឃ្លាខាងលើនេះ យើងដឹងយ៉ាងច្បាស់ថា ទ្រង់មានសេចក្តីជ្រួតជ្រាបដ៏ល្អឥតខ្ចោះនូវអ្វីដែលល្អបំផុតសម្រាប់ជីវិតរបស់ពួកយើង។ ដូច្នេះបានជាយើងគ្រប់គ្នាគួរតែជឿទុកចិត្តលើព្រះជាម្ចាស់នូវគ្រប់ទាំងផ្នែកនៃជីវិតរបស់យើង។

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

ការអនុវត្តផ្ទាល់ខ្លួន៖

### ៥. ភាពមិនប្រែប្រួល

ព្រះជាម្ចាស់មិនដែលប្រែប្រួលពីភាពជាព្រះ ឬក៏ពីបំណងព្រះហឫទ័យរបស់ទ្រង់នោះឡើយ។

ក) ម៉ាឡាគី ៣:៦

ខ) ហេព្រើរ ៦:១៧-១៨

ព្រះគម្ពីរមានកត់ទុកពីសេចក្តីសន្យារបស់ព្រះជាម្ចាស់ជាច្រើនសម្រាប់អស់អ្នកដែលជាកម្មសិទ្ធិរបស់ទ្រង់។ ហេតុដូច្នេះហើយ យើងអាចជឿទុកចិត្តថា ទ្រង់ពិតជារក្សាព្រះបន្ទូលសន្យារបស់ទ្រង់យ៉ាងពិតប្រាកដ។

ការអនុវត្តផ្ទាល់ខ្លួន៖

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

**៦. សព្វញ្ញូញ្ញាណ**

ព្រះជាម្ចាស់ជ្រាបគ្រប់ការទាំងអស់មិនថា បច្ចុប្បន្ន និងអនាគតកាលឡើយ។ ហើយមិនមានអ្វីមួយដែលអាចធ្វើឲ្យទ្រង់ភាន់ភាំងបានឡើយ។

ក) យ៉ូប ៣៤:២១

______________________________

______________________________

ខ) ទំនុកដំកើង ១៣៩:១-៦

______________________________

______________________________

______________________________

ដោយព្រោះតែព្រះជាម្ចាស់សព្វញ្ញូញ្ញាណ ទ្រង់ជ្រាបគ្រប់ទាំងបាបរបស់យើងមិនថា អតីតកាល បច្ចុប្បន្ន និងអនាគតទ្រង់ជ្រាបទាំងអស់។ ទោះបើព្រះជាម្ចាស់ជ្រាបគ្រប់ទាំងបាបរបស់យើង ក៏ទ្រង់នៅតែសង្គ្រោះ អត់ទោស ហើយទទួលយកយើងឲ្យរស់នៅក្នុងគ្រួសាររបស់ទ្រង់ជារៀងរហូត។ តើសេចក្ដីនោះរៀបរាប់ពីសុវត្ថិភាពនៃសេចក្ដីសង្គ្រោះរបស់យើងយ៉ាងដូចម្ដេច?

ការអនុវត្តផ្ទាល់ខ្លួន៖

______________________________

______________________________

______________________________

______________________________

______________________________

**៧. សព្វវត្តមាន**

ព្រះជាម្ចាស់មានវត្តមានគង់នៅគ្រប់ទីកន្លែង។

ក) សុភាសិត ១៥:៣

______________________________

______________________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

ខ) ទំនុកដំកើង ១៣៩:៧-១២

ដោយព្រោះតែព្រះជាម្ចាស់គង់នៅគ្រប់ទីកន្លែង ដូច្នេះការដែលយើងគិតថា យើងអាចលាក់បាំងពីព្រះជាម្ចាស់បាននោះគឺជាការល្ងង់ខ្លៅណាស់។ នេះក៏មានន័យថា អ្នកជឿអាចពិសោធពីព្រះវត្តមានរបស់ព្រះជាម្ចាស់គ្រប់ពេលវេលា ថែមទាំងស្គាល់ពីព្រះពរនៃការដើរជាមួយទ្រង់ដែរ។

ការអនុវត្តផ្ទាល់ខ្លួន៖

**៨. សព្វានុភាព**

ព្រះជាម្ចាស់មានអំណាចគ្រប់យ៉ាង ហើយទ្រង់មានកម្លាំងគ្រប់គ្រាន់ដើម្បីធ្វើអ្វីទាំងអស់។

ក) យេរេមា ៣២:១៧

ខ) វិវរណៈ ១៩:៦

សព្វានុភាពរបស់ព្រះជាម្ចាស់ឃើញមាននៅក្នុង៖

១. អំណាចក្នុងការបង្កើតរបស់ទ្រង់ (លោកុប្បត្តិ ១:១)

២. ការការពារលើគ្រប់អ្វីៗទាំងអស់របស់ទ្រង់ (ហេព្រើរ ១:៣)

៣. ការយកចិត្តទុកដាក់ក្នុងការផ្គត់ផ្គង់របស់ទ្រង់ចំពោះយើង (ទំនុកដំកើង ៣៧:២៣-២៤)

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

«កុំឲ្យភ័យខ្លាចឡើយ ដ្បិតអញនៅជាមួយនឹងឯង កុំឲ្យស្រយុតចិត្តឲ្យសោះ ពីព្រោះអញជាព្រះនៃឯង អញនឹងចំរើនកំឡាំងដល់ឯង អើ អញនឹងជួយឯង អើ អញនឹងទ្រឯងដោយដៃស្តាំដ៏សុចរិតរបស់អញ» (អេសាយ ៤១:១០)។ តើលោកអ្នកអាចរៀនបានអ្វីខ្លះចេញពីកណ្ឌគម្ពីរ អេសាយ ៤១:១០ ស្តីពីសព្វានុភាពរបស់ព្រះជាម្ចាស់?

ការអនុវត្តផ្ទាល់ខ្លួន៖

______________________________

______________________________

______________________________

______________________________

### ៩. សេចក្តីស្រឡាញ់

ព្រះជាម្ចាស់គឺជាសេចក្តីស្រឡាញ់។ សេចក្តីស្រឡាញ់របស់ទ្រង់គ្មានលក្ខខណ្ឌឡើយ ហើយក៏មិនមែនផ្អែកលើភាពដ៏គួរឲ្យស្រឡាញ់ ឬក៏ការតបស្នងសងគុណនៃការណាមួយរបស់យើងឡើយ។

ក) យ៉ូហាន ៣:១៦

______________________________

______________________________

ខ) រ៉ូម ៥:៨

______________________________

______________________________

សេចក្តីស្រឡាញ់បង្ហាញឲ្យឃើញតាមរយៈការប្រព្រឹត្ត។ ព្រះជាម្ចាស់ជាគំរូស្រាប់។ ទ្រង់បានសម្តែងសេចក្តីស្រឡាញ់របស់ទ្រង់ចំពោះយើង ដោយការចាត់បញ្ជូនព្រះយេស៊ូវមកសុគតជំនួសយើងរាល់គ្នា (២កូរិនថូស ៥:២១)។

ការអនុវត្តផ្ទាល់ខ្លួន៖

______________________________

______________________________

______________________________

______________________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

**១០. សេចក្ដីពិត**

មានតែព្រះជាម្ចាស់មួយប៉ុណ្ណោះដែលជាព្រះដ៏ពិត។

ក) ទំនុកដំកើង ៣១:៥

______

______

ខ) ទំនុកដំកើង ១១៧:២

______

______

សេចក្ដីពិតរបស់ព្រះជាម្ចាស់គឺពិតលើសអស់ទាំងអ្វីៗទាំងអស់។ ទ្រង់នៅតែពិតត្រង់ ទោះបីមនុស្សទាំងអស់ជាអ្នកភូតភរក៏ដោយ។ ហេតុដូច្នេះហើយបានជាព្រះបន្ទូល និងការជំនុំជម្រះរបស់ទ្រង់តែងតែមានជ័យជម្នះ (រ៉ូម ៣:៤)។ យោងតាមការយល់ដឹងនេះ តើលោកអ្នកគួរពណ៌នាពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងសេចក្ដីពិតដែលមាននៅក្នុងនោះយ៉ាងដូចម្ដេច?

ការអនុវត្តផ្ទាល់ខ្លួន៖

______

______

______

______

______

**១១. មេត្តាករុណា**

សេចក្ដីមេត្តាករុណាដ៏លើសលប់របស់ព្រះជាម្ចាស់ គឺជាការសម្ដែងឲ្យឃើញពីសេចក្ដីអាណិតអាសូររបស់ទ្រង់ដល់អស់អ្នកណាដែលបានប្រឆាំងនឹងព្រះហឫទ័យរបស់ទ្រង់។

ក) ទំនុកដំកើង ១៤៥:៨-៩

______

______

______

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

ខ) ទំនុកដំកើង ១៣០:៣-៤

កណ្ឌគម្ពីរអេភេសូរបានប្រៀបធៀបពីភាពផ្ទុយគ្នារវាងសេចក្ដីមេត្តាករុណាដ៏លើសលប់របស់ព្រះជាម្ចាស់ទៅនឹងបាបរបស់មនុស្ស។ សេចក្ដីសង្គ្រោះដែលយើងបានទទួលពីទ្រង់សឲ្យឃើញពីសេចក្ដីមេត្តាករុណារបស់ទ្រង់ (អេភេសូរ ២:៤-៥)។

ការអនុវត្តផ្ទាល់ខ្លួន៖

## V. ការអនុវត្ត

យោងតាមការយល់ដឹងពីលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ដែលបានរៀបរាប់នៅក្នុងមេរៀននេះ ចូរឆ្លើយសំណួរខាងក្រោម៖

**ក) តើការអធិស្ឋានរបស់លោកអ្នកនឹងមានឥទ្ធិពលយ៉ាងដូចម្ដេច?**

**ខ) តើលោកអ្នកគួរឆ្លើយតបទៅនឹងការល្បងលដ៏ធំនៅក្នុងជីវិតលោកអ្នកដូចជា៖**
ការស្លាប់របស់សាច់ញាតិជិតស្និទ្ធ (ប្ដី ឬប្រពន្ធ កូន) យ៉ាងដូចម្ដេច?

គ្រោះថ្នាក់មួយដែលបន្សល់ទុកឲ្យលោកអ្នកនូវភាពពិការយ៉ាងដូចម្ដេច?

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

មេរៀនទី៤

# បុគ្គលភាពរបស់ព្រះយេស៊ូវ

**ខគម្ពីរចងចាំ៖ យ៉ូហាន ១:១, ១៤**
កាលដើមដំបូងមានព្រះបន្ទូល ព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ ហើយព្រះបន្ទូលនោះឯងជាព្រះ...ព្រះបន្ទូលក៏ត្រឡប់ជាសាច់ឈាម ហើយបានស្នាក់នៅជាមួយនឹងយើងរាល់គ្នា យើងរាល់គ្នាបានឃើញសិរីល្អទ្រង់ គឺជាសិរីល្អនៃព្រះរាជបុត្រាតែ១ ដែលមកពីព្រះវរបិតា មានពេញជាព្រះគុណ និងសេចក្ដីពិត។

ព្រះយេស៊ូវគ្រីស្ទគឺជាតួអង្គដ៏សំខាន់ជាងគេបំផុតនៅក្នុងប្រវត្តិសាស្ត្រនៃមនុស្សទាំងអស់។ មិនដែលមាននរណាម្នាក់ដូចទ្រង់ឡើយ។ គេបានទទួលស្គាល់ថា ទ្រង់គឺជាគ្រូដ៏ឆ្នើមម្នាក់ ជាអ្នកដឹកនាំសាសនា ជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់ ហើយក៏ជាព្រះជាម្ចាស់ផងដែរ។ សេចក្ដីអះអាងដែលទ្រង់បានប្រកាសអំពីព្រះអង្គទ្រង់ ក៏ដូចជាការប្រកាសអះអាងរបស់មនុស្សផ្សេងៗទៀតបានធ្វើឲ្យទ្រង់ទៅជាប្រធានបទស្នូលនៃការទាស់ទែងខ្វែងគំនិតគ្នាដែលគ្មានទីបញ្ចប់ក្នុងប្រវត្តិសាស្ត្រ។

លោក ប៉ុនទាស-ពីឡាត់ បានរៀបប្រយោគសំណួរយ៉ាងច្បាស់ នៅខណៈពេលដែលលោកបានសួរថា “ដូច្នេះ តើឲ្យខ្ញុំធ្វើអ្វីដល់យេស៊ូវ ដែលហៅជាព្រះគ្រីស្ទនេះ?” (ម៉ាថាយ ២៧:២២)។ មុនដែលលោកអ្នកអាចនឹងឆ្លើយនឹងសំណួរនោះបាន ជាដំបូងលោកអ្នកត្រូវតែស្គាល់ថា ព្រះយេស៊ូវជានរណាជាមុនសិន។ មេរៀននេះនឹងណែនាំលោកអ្នកឲ្យស្គាល់ទ្រង់។

## I. ព្រះជាម្ចាស់ដែលមកយកកំណើតជាមនុស្ស

ព្រះយេស៊ូវគ្រីស្ទបានយាងមកលោកីយ៍នេះក្នុងលក្ខណៈជាមនុស្សខាងឯសាច់ឈាម។ ដោយទ្រង់បានញែកភាពជាម្ចាស់នៃភាពជាព្រះរបស់ព្រះអង្គទុកដោយឡែកដោយស្ម័គ្រព្រះទ័យ ហើយមកយកសណ្ឋានជាមនុស្សសាមញ្ញម្នាក់។ ទ្រង់ជាមនុស្សមួយរយភាគរយ ជាមនុស្សដូចមនុស្សទូទៅ លើកតែទ្រង់មិនមានបាបសោះ។ សេចក្ដីនេះសំដៅលើការ “យកកំណើតជាមនុស្ស”។

**ក) តើកណ្ឌគម្ពីរ ភីលីព ២:៦ ចែងអំពីព្រះយេស៊ូវមុននឹងទ្រង់ប្រសូតជាមនុស្សយ៉ាងដូចម្ដេច?**

________________________________________

________________________________________

________________________________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

**ខ) យោងតាមកណ្ឌគម្ពីរ ភីលីព ២:៧ តើព្រះយេស៊ូវបានធ្វើអ្វី?**

**គ) ព្រះយេស៊ូវគឺជាមនុស្សមួយរយភាគរយ**

១. ចូរពណ៌នាពីការលូតលាស់ខាងឯសាច់ឈាម និងការចម្រើនវ័យធំឡើងរបស់ព្រះយេស៊ូវ ទៅជាមនុស្សពេញវ័យម្នាក់ (លូកា ២:៤០, ៥២)។

២. តើមានហេតុការណ៍អ្វីកើតឡើងចំពោះព្រះយេស៊ូវ នៅពេលដែលទ្រង់អស់កម្លាំង (ម៉ាកុស ៤:៣៨)?

៣. តើមានហេតុការណ៍អ្វីកើតឡើងចំពោះព្រះយេស៊ូវ នៅពេលដែលទ្រង់មិនបានសោយអាហារ (លូកា ៤:២)?

៤. តើព្រះយេស៊ូវមានអារម្មណ៍យ៉ាងដូចម្ដេចបន្ទាប់ពីការធ្វើដំណើរម្ដងនោះ (យ៉ូហាន ៤:៦)?

៥. តើព្រះយេស៊ូវមានប្រតិកម្មយ៉ាងដូចម្ដេច នៅពេលដែលទ្រង់ព្រួយព្រះទ័យ (យ៉ូហាន ១១:៣៥)?

៦. តើព្រះយេស៊ូវបានមានបន្ទូលពីខ្លួនព្រះអង្គទ្រង់ផ្ទាល់យ៉ាងដូចម្ដេច (លូកា ២៤:៣៩)?

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

## II. មនុស្សដែលជាព្រះជាម្ចាស់

ទោះបើព្រះយេស៊ូវបានយកសណ្ឋានជាមនុស្សយ៉ាងណាក៏ដោយ ក៏ទ្រង់នៅតែជាព្រះមួយរយភាគរយដដែល។ សូមពិចារណាពីកំណត់សម្គាល់នៃភាពជាព្រះដែលបានចែងពីព្រះគ្រីស្ទដូចខាងក្រោមៈ

### ក) លក្ខណសម្បត្តិផ្សេងៗ

| ចូរពិនិត្យមើលខគម្ពីរខាងក្រោមទាំងនេះដែលពណ៌នាពីលក្ខណសម្បត្តិផ្សេងៗរបស់ព្រះគ្រីស្ទ។ |
|---|
| គ្រប់ទាំងអំណាច..................................ម៉ាថាយ ២៨:១៨ |
| អស់កល្ប........................................... ១យ៉ូហាន ១:១-២ |
| មិនចេះប្រែប្រួល.........................................ហេព្រើរ ១៣:៨ |
| សព្វញ្ញូញាណ......................................កូល៉ុស ២:២៩-៣ |
| ឥតខ្ចោះ ឬក៏គ្មានបាបសោះ ...................... ២កូរិនថូស ៥:២១ |
| បរិសុទ្ធ...............................................កិច្ចការ ៣:១៤-១៥ |
| សេចក្ដីពិត................................................ យ៉ូហាន ១៤:៦ |

ព្រះគ្រីស្ទបានបង្ហាញអំណាចរបស់ទ្រង់ (សព្វានុភាព) ក្នុងព័ន្ធកិច្ចនៅផែនដីតាមវិធីជាច្រើនដូចខាងក្រោមៈ

១. ម៉ាថាយ ៨:២៣-២៧ អំណាចលើ ______________________________

២. លូកា ៤:៤០ អំណាចលើ ____________________________________

៣. លូកា ៤:៣៣-៣៦ អំណាចលើ ________________________________

៤. យ៉ូហាន ១១:៤៣-៤៤ អំណាចលើ ______________________________

តើមានអំណាចជាច្រើនបែបណាទៀតដែលព្រះយេស៊ូវបានប្រកាស និងកំពុងតែប្រើ (ម៉ាកុស ២:៣-១២)? តម្រុយៈ សូមមើលខ១០។

_______________________________________________________

យោងតាមកណ្ឌគម្ពីរ ម៉ាកុស ២:៧ តើមានតែអ្នកណាដែលអាចអត់ទោសបាបឲ្យបាន?

_______________________________________________________

ដោយហេតុថា ព្រះយេស៊ូវមានអំណាចអត់ទោសបាប ហើយយើងដឹងថា មានតែព្រះជាម្ចាស់តែមួយប៉ុណ្ណោះដែលអាចអត់ទោសបាបបាន ដូច្នេះតើព្រះយេស៊ូវគ្រីស្ទជានរណា?

_______________________________________________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

**ខ) នាមនៃភាពជាព្រះជាម្ចាស់**

១. ម៉ាថាយ ១:២៣ ______________________ (ព្រះអង្គទ្រង់គង់ជាមួយនឹងយើងខ្ញុំ)

២. ភីលីព ២:១០-១១ __________________________ (អធិបតេយ្យភាព)

៣. យ៉ូហាន ៨:៥៨ ______________________ (ព្រះនាមមួយដែលបម្រុងទុកសម្រាប់ព្រះជាម្ចាស់ — និក្ខមនំ ៣:១៤)

**គ) សេចក្ដីថ្លែងនៃភាពជាព្រះជាម្ចាស់**

សូមសរសេរសេចក្ដីថ្លែងដែលជាគន្លឹះ៖

១. កូល៉ុស ២:៩ ______________________________________________

______________________________________________

២. ហេព្រើរ ១:១-៣ក ___________________________________________

______________________________________________

______________________________________________

៣. យ៉ូហាន ១:១, ១៤ ព្រះយេស៊ូវគ្រីស្ទ (“ព្រះបន្ទូល”) គឺជា ____________________

______________________________________________

______________________________________________

៤. ទីតុស ២:១៣ ______________________________________________

______________________________________________

## III. ព្រះគ្រីស្ទដែលជាអង្គសង្គ្រោះ

យោងតាមកណ្ឌគម្ពីរ យ៉ូហាន ៣:១៧ ព្រះយេស៊ូវគឺជាព្រះសង្គ្រោះនៃមនុស្សលោក។ សូមសរសេរពីព្រះនាមផ្សេងៗដែលពណ៌នាពីព្រះគុណរបស់ព្រះជាម្ចាស់ក្នុងការសង្គ្រោះ។

ក) យ៉ូហាន ១:២៩ ______________________________________________

______________________________________________

ខ) យ៉ូហាន ៦:៣៥ ______________________________________________

______________________________________________

គ) យ៉ូហាន ១៤:៦ ______________________________________________

______________________________________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

## IV. ព្រះមហាក្សត្រដែលយាងមកត្រួតត្រា

ព្រះយេស៊ូវមិនមែនគ្រាន់តែជាមនុស្សម្នាក់គ្រប់គ្រងលើអតីតកាលនោះទេ ទ្រង់គឺជាស្តេចលើអស់ទាំងស្តេច ហើយជាព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់ដែលនៅថ្ងៃមួយនឹង សោយរាជ្យនៅលើពិភពលោកទាំងមូល (១ធីម៉ូថេ ៦:១៤-១៥)។

**ក) យោងតាមកណ្ឌគម្ពីរ ដានីយ៉ែល ៧:១៤ តើការបីយ៉ាងដែលព្រះជាម្ចាស់បានប្រទានមកព្រះយេស៊ូវ នោះមានអ្វីខ្លះ?**

១. ____________________

២. ____________________

៣. ____________________

**ខ) តើព្រះយេស៊ូវបានមានបន្ទូលទៅកាន់អ្នកដើរតាមទ្រង់យ៉ាងដូចម្តេច (ម៉ាថាយ ២៥:៣១-៣២)?**

____________________

____________________

**គ) តើទេវតាបាននិយាយយ៉ាងដូចម្តេចខ្លះទៅកាន់ពួកសាវ័ក នៅពេលដែលព្រះយេស៊ូវយាងទៅស្ថានសួគ៌ បន្ទាប់ពី៤០ថ្ងៃនៃការមានព្រះជន្មរស់ឡើងវិញ (កិច្ចការ ១:១១)?**

____________________

____________________

**ឃ) ចូរពណ៌នាពីការយាងមកវិញរបស់ព្រះយេស៊ូវគ្រីស្ទ (២ថែស្សាឡូនីច ១:៧ខ-១០)។**

____________________

____________________

____________________

____________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

## V. ការអនុវត្ត

ព្រះគ្រីស្ទគឺជា៖

- ព្រះជាម្ចាស់
- ព្រះសង្គ្រោះ
- ស្តេច/ម្ចាស់គ្រប់គ្រង

ក) តាមរយៈការស្រាយបំភ្លឺខាងលើនេះ តើលោកអ្នកអាចរៀបចំខ្លួនឲ្យបានល្អបំផុតសម្រាប់ការយាងមកជាលើកទី២របស់ទ្រង់យ៉ាងដូចម្តេច (២ពេត្រុស ៣:១៤)?

______________________________

______________________________

______________________________

ខ) តើនៅសប្តាហ៍នេះលោកអ្នកគួរធ្វើអ្វី ដើម្បីទទួលស្គាល់ថាទ្រង់ គឺជាព្រះជាម្ចាស់ (វិវរណៈ ៥:១១-១៤)?

______________________________

______________________________

______________________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

មេរៀនទី៥

# ព័ន្ធកិច្ចរបស់ព្រះគ្រីស្ទ

**ខគម្ពីរចងចាំ៖ ១កូរិនថូស ១៥:៣-៤**
ដ្បិតមុនដំបូង ខ្ញុំបានប្រាប់មកអ្នករាល់គ្នា តាមសេចក្ដីដែលខ្ញុំបានទទួលដែរ គឺថា ព្រះគ្រីស្ទបានសុគត ដោយព្រោះបាបរបស់យើងរាល់គ្នា តាមបទគម្ពីរ ហើយថា ទ្រង់ត្រូវគេបញ្ចុះក្នុងផ្នូរ រួចដល់ថ្ងៃទី៣ នោះទ្រង់មានព្រះជន្មរស់ឡើងវិញ ក៏តាមបទគម្ពីរ។

ព្រះគម្ពីរបានប្រាប់យើងថា “ទ្រង់បានផ្ទុកអំពើបាបរបស់យើងរាល់គ្នា នៅលើរូបអង្គទ្រង់ ជាប់លើឈើឆ្កាង ដើម្បីឲ្យយើងបានរស់ខាងឯសេចក្ដីសុចរិត ដោយបានស្លាប់ខាងឯអំពើបាប” (១ពេត្រុស ២:២៤)។

## I. ព័ន្ធកិច្ចរបស់ព្រះយេស៊ូវជាតម្រូវការរបស់មនុស្ស

**ក) យោងតាមកណ្ឌគម្ពីរ រ៉ូម ៣:១០-១២ តើចំណុចទាំងប្រាំមួយយ៉ាងដែលមនុស្សគ្រប់គ្នាជាប់ទោសនោះមានអ្វីខ្លះ?**

១. ____________________

២. ____________________

៣. ____________________

៤. ____________________

៥. ____________________

៦. ____________________

*កណ្ឌគម្ពីរ រ៉ូម ៣:២៣ សង្ខេបពីបញ្ហា៖ “ពីព្រោះគ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ”។*

**ខ) តើមនុស្សជាប់ជាបាវបម្រើរបស់អ្នកណា (យ៉ូហាន ៨:៣៤)?** ____________________

**គ) តើលទ្ធផលនៃបាបគឺជាអ្វី (យ៉ាកុប ១:១៥)?** ____________________

**ឃ) ពីព្រោះពីដើមយើងរាល់គ្នាក៏ស្លាប់ក្នុងការរំលង ហើយក្នុងបាបដែរ ដូច្នេះតើយើងបានដើរតាមអ្នកណា ហើយជាកូនប្រភេទណាពីមុន (អេភេសូរ ២:១-៣)?** ____________________

____________________

**ង) តើ “មនុស្សរឹងចចេស” នឹងភ្លក់សេចក្ដីក្រោធរបស់អ្នកណា (អេភេសូរ ៥:៦)?**

____________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

**តើព្រះជាម្ចាស់នឹងគ្រាប្រណីដល់អំពើបាបឬ?**

*"ត្រូវបណ្តាសាហើយ អស់អ្នកណាដែលមិនកាន់ខ្ជាប់តាមគ្រប់ទាំងសេចក្តីដែលកត់ទុកក្នុងគម្ពីរក្រឹត្យវិន័យ ដើម្បីនឹងប្រព្រឹត្តតាម"* (កាឡាទី ៣:១០)។

ដូចដែលយើងបានសិក្សាមេរៀនទី៣រួចមកហើយថា ព្រះជាម្ចាស់ការពារភាពបរិសុទ្ធរបស់ទ្រង់ ហើយក៏ទាមទារឲ្យមានភាពដូចគ្នាទៅនឹងភាពបរិសុទ្ធនោះដែរ។ មនុស្សគ្រប់គ្នានឹងត្រូវប្រឈមមុខជាមួយនឹង៖

- បាប (រ៉ូម ៣:២៣)
- ធ្វើជាខ្មាំងសត្រូវនឹងព្រះជាម្ចាស់ (យ៉ាកុប ៤:៤ខ)
- ស្ថិតនៅក្រោមអំណាចរបស់អារក្សសាតាំង (១យ៉ូហាន ៥:១៩)
- នៅខ្សោយនៅឡើយដើម្បីនឹងជួយខ្លួនឯង (រ៉ូម ៥:៦)
- សេចក្តីស្លាប់ (រ៉ូម ៦:២៣)
- ការផ្តន្ទាទោស និងការឃ្លាតឆ្ងាយពីព្រះភក្ត្រព្រះអម្ចាស់អស់កល្បជានិច្ច (២ថែស្សាឡូនីច ១:៩)

## II. តម្លៃនៃព័ន្ធកិច្ចរបស់ព្រះគ្រីស្ទ

**ក) សូមអានកណ្ឌគម្ពីរ ភីលីព ២:៧-៨។**

១. តើការបីយ៉ាងដែលព្រះយេស៊ូវបានធ្វើកាលដែលទ្រង់បានយាងមកលោកីយ៍នោះមានអ្វីខ្លះ (ខ៧)?

ក) ____________________

ខ) ____________________

គ) ____________________

២. តើព្រះយេស៊ូវបានបន្ទាបព្រះអង្គទ្រង់តាមវិធីណា (ខ៨)?

____________________

____________________

**ខ) យោងតាមកណ្ឌគម្ពីរ អេសាយ ៥៣:៣ តើមានហេតុការណ៍អ្វីបានកើតឡើងចំពោះព្រះយេស៊ូវនៅលើលោកីយ៍?**

____________________

____________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

**គ) តើការរួចពីបាបតម្រូវឲ្យមានអ្វី (ហេព្រើរ ៩:២២)?**

______________________________

**ឃ) តើតម្លៃដែលព្រះយេស៊ូវបានបង់ថ្លៃ ដើម្បីលោះយើងនោះគឺជាអ្វី (១ពេត្រុស ១:១៨-១៩)?**

______________________________

**ង) តើព្រះយេស៊ូវបានបន្លឺសំឡេងឡើងយ៉ាងដូចម្ដេចនៅលើឈើឆ្កាង (ម៉ាថាយ ២៧:៤៦)?**

______________________________

**ច) តើព្រះជាម្ចាស់បានធ្វើអ្វីចំពោះព្រះយេស៊ូវ ខណៈពេលដែលទ្រង់នៅលើឈើឆ្កាង (អេសាយ ៥៣:៦)?**

______________________________

______________________________

## III. ការផ្ដត់ផ្គង់ពីព័ន្ធកិច្ចរបស់ព្រះគ្រីស្ទ

ព្រះយេស៊ូវបានយាងមកលើលោកីយ៍នេះ ដើម្បីសងថ្លៃបាប។ តម្លៃនោះគឺជាព្រះជន្មរបស់ទ្រង់ផ្ទាល់ ដែលទ្រង់ផ្ដល់ឲ្យយ៉ាងស្ម័គ្រពីព្រះទ័យ (យ៉ូហាន ១០:១១, ១៧-១៨)។ ការបូជាយញ្ញរបស់ទ្រង់ គឺជាផ្លូវតែមួយគត់ក្នុងការដោះបាបចេញ មិនថាបាបពីអតីតកាល ឬបច្ចុប្បន្នក្ដី គឺគ្រប់ពេលទាំងអស់ (ហេព្រើរ ៩:១២)។

ចូរពណ៌នាពីអ្វីដែលការសុគតរបស់ព្រះយេស៊ូវសម្រេចបាន៖

**ក) ១ពេត្រុស ៣:១៨** ______________________________

______________________________

**ខ) រ៉ូម ៥:១០** ______________________________

______________________________

**គ) ២កូរិនថូស ៥:២១** ______________________________

______________________________

**ឃ) កាឡាទី ១:៤** ______________________________

______________________________

**ង) អេភេសូរ ១:៧** ______________________________

______________________________

**ច) រ៉ូម ៦:៦** ______________________________

______________________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

**ព្រះយេស៊ូវគ្រីស្ទ៖ ចម្លើយចំពោះបញ្ហាទាំងអស់របស់មនុស្សដែលទាក់ទងនឹងសេចក្ដីសង្គ្រោះ**

ព័ន្ធកិច្ចរបស់ព្រះយេស៊ូវនៅលើឈើឆ្កាង និងការមានព្រះជន្មរស់ឡើងវិញ គឺជាដំណោះស្រាយតែមួយគត់ចំពោះបញ្ហាផ្សេងៗរបស់មនុស្ស។ ហេតុដូច្នេះហើយបានជាសាវ័ក ពេត្រុស អាចនឹងប្រកាសពីព្រះយេស៊ូវគ្រីស្ទថា៖

“ហើយគ្មានសេចក្ដីសង្គ្រោះ ដោយសារអ្នកណាទៀតសោះ
ដ្បិតនៅក្រោមមេឃ គ្មាននាមឈ្មោះណាទៀតបានប្រទានមកមនុស្សលោក
ឲ្យយើងរាល់គ្នាបានសង្គ្រោះនោះឡើយ” (កិច្ចការ ៤:១២)។

សូមសម្គាល់មើលពីរបៀបដែលថា ព្រះគ្រីស្ទគឺជាចម្លើយដល់បញ្ហាផ្សេងៗរបស់មនុស្សម្នាក់ៗ យោងតាមចម្លើយរបស់លោកអ្នកនៅក្នុងវគ្គព័ន្ធកិច្ចរបស់ព្រះយេស៊ូវជាតម្រូវការរបស់មនុស្សនៃមេរៀននេះ នៅទំព័រ៤៩។

| បញ្ហារបស់មនុស្ស | ដំណោះស្រាយក្នុងព្រះគ្រីស្ទ | បទគម្ពីរ |
|---|---|---|
| ក) ជាប់មានទោសនៅចំពោះព្រះជាម្ចាស់<br>១. មិនសុចរិត | “នោះមនុស្សជាច្រើន ក៏បានត្រឡប់ជាសុចរិតដោយសារម្នាក់បានស្ដាប់បង្គាប់វិញយ៉ាងនោះដែរ”។ | រ៉ូម ៥:១៩ |
| ២. មិនយល់ | “ព្រះរាជបុត្រានៃព្រះបានយាងមកហើយ ក៏បានប្រទានឲ្យយើងរាល់គ្នាមានប្រាជ្ញា”។ | ១យ៉ូហាន ៥:២០ |
| ៣. មិនស្វែងរកព្រះ | “ដ្បិតកូនមនុស្សបានមក ដើម្បីនឹងរកហើយជួយសង្គ្រោះដល់មនុស្សបាត់បង់”។ | លូកា ១៩:១០ |
| ៤. នាំគ្នាបែរចេញពីព្រះ | “ដ្បិតពីដើមអ្នករាល់គ្នាប្រៀបដូចជាចៀមដែលវង្វេង តែឥឡូវនេះបានត្រឡប់មកឯអ្នកគង្វាល”។ | ១ពេត្រុស ២:២៥ |
| ៥. គ្រប់គ្នាទៅជាឥតប្រយោជន៍ | “ដ្បិតបើមានសេចក្ដីទាំងនោះចំរើនឡើង ក្នុងចិត្តអ្នករាល់គ្នាហើយ នោះអ្នករាល់គ្នាមិននៅទំនេរ ឬឥតផលខាងឯដំណើរស្គាល់ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់នៃអ្នករាល់គ្នាឡើយ”។ | ២ពេត្រុស ១:៨ |
| ៦. មិនចេះធ្វើការល្អ | “ដ្បិតយើងរាល់គ្នាជាស្នាដៃ ដែលទ្រង់បង្កើតក្នុងព្រះគ្រីស្ទយេស៊ូវសម្រាប់ការល្អ ដែលព្រះបានរៀបចំជាមុន ឲ្យយើងរាល់គ្នាប្រព្រឹត្តតាម”។ | អេភេសូរ ២:១០ |
| ខ) បាវបម្រើរបស់អំពើបាប | “ព្រះគ្រីស្ទយេស៊ូវ នោះបានប្រោសឲ្យខ្ញុំរួចពីអំណាចរបស់អំពើបាប និងសេចក្ដីស្លាប់ហើយ”។ | រ៉ូម ៨:២ |
| គ) ប្រឈមមុខនឹងសេចក្ដីស្លាប់ | “អ្នកណាដែលស្ដាប់ពាក្យខ្ញុំ ហើយជឿដល់ព្រះអង្គ ដែលចាត់ឲ្យខ្ញុំមក អ្នកនោះមានជីវិតដ៏នៅអស់កល្បជានិច្ច”។ | យ៉ូហាន ៥:២៤ |
| ឃ) ប្រឈមមុខនឹងសេចក្ដីក្រោធរបស់ព្រះជាម្ចាស់ | “ដូច្នេះ ដែលបានរាប់ជាសុចរិត ដោយសារព្រះលោហិតទ្រង់នោះប្រាកដជាយើងនឹងបានរួចចេញពីសេចក្ដីក្រោធ ដោយសារទ្រង់ជាមិនខានលើសទៅទៀត”។ | រ៉ូម ៥:៩ |

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

## IV. ការជំរុញចិត្តដែលបណ្ដាលឲ្យព្រះគ្រីស្ទបំពេញព័ន្ធកិច្ច

ក) ហេតុអ្វីបានជាព្រះជាម្ចាស់សង្គ្រោះមនុស្សលោក (យ៉ូហាន ៣:១៦, រ៉ូម ៥:៨)?

ខ) តើការដែលព្រះជាម្ចាស់សង្គ្រោះមនុស្សលោកបានបង្ហាញឲ្យយើងឃើញពីលក្ខណសម្បត្តិមួយណារបស់ទ្រង់ (១ពេត្រុស ១:៣)?

គ) ហេតុអ្វីបានជាអ្នកនិពន្ធហៅសេចក្ដីមេត្តាករុណារបស់ព្រះអម្ចាស់ថា អស្ចារ្យ (តម្រុយះ រ៉ូម ៥:៦, ៨)?

## V. ការបញ្ចប់ និងការបន្តព័ន្ធកិច្ចរបស់ព្រះគ្រីស្ទ

ការសុគតរបស់ព្រះគ្រីស្ទនៅភ្នំកាលវ៉ារីបានបញ្ចប់ព័ន្ធកិច្ចប្រោសលោះរបស់ទ្រង់សម្រាប់មនុស្សលោក (យ៉ូហាន ១៩:៣០)។ ប៉ុន្តែរឿងរ៉ាវនៃការសង្គ្រោះមិនមែនចប់នៅត្រង់នោះទេ។ ផ្នូរមិនអាចឃុំព្រះគ្រីស្ទជាប់បាននោះឡើយ ទ្រង់មានព្រះជន្មរស់នៅ ហើយនៅបន្តព័ន្ធកិច្ចដែលទ្រង់បានចាប់ផ្ដើមធ្វើសម្រាប់យើងរាល់គ្នា។

ក) តើកណ្ឌគម្ពីរ រ៉ូម ១:៤ បានប្រកាសពីព្រះគ្រីស្ទថាជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់យ៉ាងដូចម្ដេច?

ខ) ក្រោយដែលព្រះគ្រីស្ទបានសម្អាតអំពើបាបរបស់យើងរាល់គ្នាទាំងប៉ុន្មានមក តើទ្រង់បានថ្កើងឡើងយ៉ាងដូចម្ដេច (ហេព្រើរ ១:៣)?

គ) យើងទទួលបទពិសោធន៍សេចក្ដីស្លាប់ខាងឯវិញ្ញាណមកដោយសារបាបរបស់លោក អ័ដាម។ ចុះតើគុណប្រយោជន៍ដែលយើងបានទទួលមកដោយការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ទ នោះគឺជាអ្វីទៅវិញ (១កូរិនថូស ១៥:២១-២២)?

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

ព្រះគម្ពីរសំដៅទៅលើការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ទដូចទៅនឹង «ផលដំបូង»។ នេះគឺជាពាក្យដែលមាននៅក្នុងសញ្ញាចាស់ដែលថែងអំពីផលដំបូងនៃចម្រូត ហើយផលទាំងនេះត្រូវញែកទុកដោយឡែកសម្រាប់ព្រះជាម្ចាស់។ គេបានប្រើពាក្យ «ផលដំបូង» នៅក្នុងសញ្ញាថ្មី ដើម្បីបញ្ជាក់ថា នឹងមានចម្រូតបន្ថែមទៀតនាពេលអនាគត។ ហេតុដូច្នេះហើយ ការដែលព្រះគ្រីស្ទមានព្រះជន្មរស់ឡើងវិញមុនគេ នោះគឺជាសេចក្ដីសន្យាដែលបង្ហាញថា នាពេលអនាគតនឹងមានអ្នកផ្សេងទៀតរស់ឡើងវិញដូចទ្រង់ផងដែរ (១កូរិនថូស ១៥:២០-២២, ១ពេត្រុស ១:៣)។

**ឃ) ឥឡូវ ដែលយើងបានចូលទៅឯព្រះជាម្ចាស់តាមរយៈព្រះគ្រីស្ទ ដូច្នេះ តើព្រះយេស៊ូវអាចនឹងធ្វើអ្វីបានខ្លះ (ហេព្រើរ ៧:២៥)?**

__________________________________________

__________________________________________

**ង) តើមុខតំណែងផ្ដាច់មុខដែលព្រះយេស៊ូវមាននោះគឺជាអ្វី (១ធីម៉ូថេ ២:៥)?**

__________________________________________

__________________________________________

**ច) នៅមុនពេលដែលព្រះយេស៊ូវហៀបនឹងចាកចេញទៅ តើទ្រង់សន្យាថាទ្រង់នឹងធ្វើអ្វី (យ៉ូហាន ១៤:៣)?**

__________________________________________

__________________________________________

## VI. ការអនុវត្ត

នៅពេលដែលមនុស្សមួយចំនួនចាប់ផ្ដើមដឹងពីលក្ខណៈដ៏ពិតរបស់ព្រះគ្រីស្ទ នោះពួកគេច្បាស់ជាទទួលស្គាល់ថា ពួកគេបានធ្វើឲ្យមានបញ្ហាដ៏ព្រឺព្រួចមួយទៅនឹងអ្វីដែលពួកគេបានជឿ និងពីរបៀបដែលពួកគេបានរស់នៅពីមុនមក។ ហើយពួកគេបានទទួលស្គាល់យ៉ាងច្បាស់ថា ពួកគេពិតជាបានធ្វើខុស។ ចូរពណ៌នាពីគំរូរបស់មនុស្សដែលរស់នៅក្នុងក្រុងយេរូសាឡិមដែលព្រះជាម្ចាស់បានឲ្យភ្នែកពួកគេមើលឃើញពីសេចក្ដីពិត៖

---

*«កាលគេបានឮ នោះគេមានសេចក្ដីចាក់ចុចក្នុងចិត្ត ក៏សួរពេត្រុស និងពួកសាវ័កឯទៀតថា បងប្អូនអើយ តើយើងខ្ញុំត្រូវធ្វើដូចម្ដេច» (កិច្ចការ ២:៣៧)។*

---

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

តើលោកអ្នកអាចធ្វើអ្វីបាន?

- ត្រូវទទួលស្គាល់ថា លោកអ្នកបានធ្វើបាប ហើយមិនអាចទទួលយកបាននៅចំពោះព្រះជាម្ចាស់។
- ត្រូវប្រែចិត្ត ហើយស្រែកអំពាវនាវរកព្រះនាមរបស់ព្រះយេស៊ូវ ដើម្បីឲ្យទ្រង់សង្គ្រោះលោកអ្នក។
- ត្រូវស្វែងរកនូវការអត់ទោសតាមរយៈព្រះលោហិតទ្រង់ដែលបានបង្ហូរសម្រាប់លោកអ្នក។
- ត្រូវទទួលស្គាល់ថា ទ្រង់មានសិទ្ធិគ្រប់គ្រាន់ធ្វើជាអ្នកដឹកនាំជីវិតរបស់លោកអ្នក។
- ត្រូវអរព្រះគុណព្រះជាម្ចាស់ចំពោះសេចក្តីស្រឡាញ់ និងព្រះគុណរបស់ទ្រង់។

☐ ខ្ញុំបានប្រែចិត្តចេញពីអំពើបាបរបស់ខ្ញុំទាំងអស់ ហើយបានស្រែកអំពាវនាវរកព្រះនាមរបស់ព្រះយេស៊ូវគ្រីស្ទ ហើយក៏ទទួល និងជឿលើទ្រង់ទុកជាព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះរបស់ខ្ញុំរួចហើយ។

☐ ខ្ញុំមិនទាន់បានទទួលព្រះគ្រីស្ទនៅឡើយទេ ប៉ុន្តែខ្ញុំនៅតែស្វែងរកទ្រង់យ៉ាងអស់ពីចិត្តរបស់ខ្ញុំ។

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

## មេរៀនទី៦

# សេចក្ដីសង្គ្រោះ

**ខគម្ពីរចងចាំ៖ អេភេសូរ ២:៨-១០**
ដ្បិតគឺដោយព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះដោយសារសេចក្ដីជំនឿ ហើយសេចក្ដីនោះក៏មិនមែនកើតពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ ក៏មិនមែនដោយការប្រព្រឹត្តដែរក្រែងអ្នកណាអួតខ្លួន ដ្បិតយើងរាល់គ្នាជាស្នាដៃ ដែលទ្រង់បង្កើតក្នុងព្រះគ្រីស្ទយេស៊ូវសំរាប់ការល្អ ដែលព្រះបានរៀបចំជាមុន ឲ្យយើងរាល់គ្នាប្រព្រឹត្តតាម ។

តើមនុស្សអាចទទួលការប្រោសលោះពីព្រះគ្រីស្ទបានយ៉ាងដូចម្ដេច? តើយើងអាចដឹងថា អ្នកណាមួយជាគ្រីស្ទបរិស័ទបានដោយរបៀបណា? ព្រះជាម្ចាស់បានចេញព្រះរាជក្រឹត្យ ឬអនុម័តនូវផែនការនៃការសង្គ្រោះដែលទ្រង់បានបង្ហាញមកឲ្យយើងឃើញនៅក្នុងព្រះគម្ពីរ។ នៅក្នុងមេរៀននេះ យើងនឹងសិក្សាអំពីរបៀបដែលទ្រង់សង្គ្រោះអស់អ្នកណាដែលជឿដល់ទ្រង់។

## I. អធិបតេយ្យភាពរបស់ព្រះជាម្ចាស់ក្នុងការសង្គ្រោះ

### ក) ផែនការអធិបតេយ្យភាពនៃការសង្គ្រោះរបស់ព្រះជាម្ចាស់

១. សូមអានកណ្ឌគម្ពីរ រ៉ូម ៨:២៩-៣០ បន្ទាប់មកសូមសរសេរពីជំហាននៃព័ន្ធកិច្ចរបស់ព្រះជាម្ចាស់ក្នុងការសង្គ្រោះមនុស្សលោក៖

ខ២៩ : អ្នកណាដែលទ្រង់ __________________ ទ្រង់ក៏ __________________

ខ៣០ : អ្នកណាដែលទ្រង់ __________________ ទ្រង់ក៏ __________________

ខ៣០ : អ្នកណាដែលទ្រង់ __________________ ទ្រង់ក៏ __________________

ខ៣០ : អ្នកណាដែលទ្រង់ __________________ ទ្រង់ក៏ __________________

២. សូមអានកណ្ឌគម្ពីរ អេភេសូរ ១:៤-៦ រួចឆ្លើយសំណួរខាងក្រោម៖

ក) តើអ្វីទៅជាផែនការរបស់ព្រះជាម្ចាស់ដែលទ្រង់បានមានតាំងពីមុនកំណើតលោកីយ៍មក (ខ៤)?

______________________________________________

______________________________________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

ខ) តើគោលបំណងនៃការសង្គ្រោះរបស់ទ្រង់គឺជាអ្វី (ខ៦)?

______________________________

*ព្រះគុណគឺជា «សេរីភាព និងសកម្មភាពអធិបតេយ្យអំពីសេចក្ដីស្រឡាញ់ និងសេចក្ដីមេត្តាករុណារបស់ទ្រង់ក្នុងការប្រទានសេចក្ដីសង្គ្រោះតាមរយៈការសុគត និងការរស់ឡើងវិញរបស់ព្រះយេស៊ូវ ហើយគឺដាច់ឡែកពីអ្វីៗទាំងអស់ដែលមនុស្សមាន និងអ្វីៗដែលមនុស្សអាចធ្វើបាន ព្រមទាំងជាការទ្រទ្រង់របស់ទ្រង់ចំពោះសេចក្ដីសង្គ្រោះរហូតដល់ទ្រង់តម្កើងអស់អ្នកដែលទ្រង់បានសង្គ្រោះនោះ។»*

— លោកគ្រូ ចន មែកខធ័រ (John MacArthur)[១]

**ខ) ព្រះជាម្ចាស់អនុវត្តផែនការនៃការសង្គ្រោះរបស់ទ្រង់**

**ព្រះរាជក្រឹត្យរបស់ព្រះជាម្ចាស់ដែលបង្ហាញពីផែនការរបស់ទ្រង់**

*«រីឯព្រះ ដែលអាចនឹងតាំងអ្នករាល់គ្នា ឲ្យខ្ជាប់ខ្ជួនតាមដំណឹងល្អខ្ញុំ នឹងតាមខ្លឹមនៃលទ្ធិរបស់ព្រះយេស៊ូវគ្រីស្ទ ដែលត្រូវនឹងសេចក្ដីបើកសំដែង អំពីការអាថ៌កំបាំង ដែលបានលាក់ទុកនៅអស់ទាំងកល្បរៀងមក តែឥឡូវនេះបានបើកសំដែងមក ឲ្យគ្រប់ទាំងសាសន៍ដឹង ដោយសារគម្ពីរហោរា តាមបង្គាប់នៃព្រះដ៏មានព្រះជន្មរស់អស់កល្បជានិច្ច ដើម្បីឲ្យគេបានចុះចូលជឿ ដោយសារព្រះយេស៊ូវគ្រីស្ទ»* (រ៉ូម ១៦:២៥-២៦)។

១. តើមុនដែលមនុស្សបានកើតជាថ្មី ពួកគេមានស្ថានភាពខាងឯវិញ្ញាណយ៉ាងដូចម្ដេច (អេភេសូរ ២:១)?

______________________________

២. តើព្រះជាម្ចាស់ (ព្រះវិញ្ញាណបរិសុទ្ធ) នឹងធ្វើអ្វីខ្លះចំពោះបាប (យ៉ូហាន ១៦:៨)?

______________________________

៣. តើសេចក្ដីត្រូវការចាំបាច់ មុនពេលដែលអ្នកណាម្នាក់អាចស្គាល់សេចក្ដីពិតនោះគឺជាអ្វី (២ធីម៉ូថេ ២:២៥)?

______________________________

១. ដកស្រង់ចេញពីសៀវភៅ The MacArthur New Testament Commentary series, *Galatians* (Moody), © ១៩៨៧ ដោយ John MacArthur។

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

៤. តើអ្នកណាផ្តល់ឲ្យ? ______________________________

៥. យោងតាមកណ្ឌគម្ពីរ យ៉ូហាន ១:១២-១៣ តើអ្នកណាដែលផ្តល់សិទ្ធិឲ្យយើងក្លាយជាកូនរបស់ព្រះជាម្ចាស់ (ខ១២)?

______________________________

ចូរចងចាំថា៖ យើងមាន សិទ្ធិ ឬក៏អភ័យឯកសិទ្ធិនេះដោយសារព្រះគុណរបស់ព្រះជាម្ចាស់ មិនមែនដោយសារៈ

- កំណើតរបស់យើង (“មកពីឈាម”)
- ការខំប្រឹងប្រែងរបស់យើង (“សេចក្តីប្រាថ្នាខាងសាច់ឈាម”)
- ឆន្ទៈរបស់យើង (“សេចក្តីប្រាថ្នារបស់មនុស្ស”)

៦. តើអ្នកណាធ្វើឲ្យអ្នកជឿលូតលាស់ឡើង (១កូរិនថូស ៣:៦)?

______________________________

៧. តើអ្នកណានឹងធ្វើឲ្យការរស់ឡើងវិញកើតឡើង (១កូរិនថូស ៦:១៤)?

______________________________

**គ) ព្រះជាម្ចាស់សម្រេចផែនការរបស់ទ្រង់**

១. សូមអានកណ្ឌគម្ពីរ រ៉ូម ៨:២៩ ម្តងទៀត។ តើនៅចុងបញ្ចប់ព្រះជាម្ចាស់នឹងធ្វើឲ្យយើងត្រឡប់ដូចជារូបអង្គណា?

______________________________

២. តើនឹងមានរឿងអ្វីកើតឡើងចំពោះអ្នកជឿគ្រប់រូប (ភីលីព ៣:២០-២១)?

______________________________

៣. តើព្រះគ្រីស្ទមានបំណងព្រះហឫទ័យបែបណាសម្រាប់អស់អ្នកណាដែលជារបស់ផងទ្រង់ (យ៉ូហាន ១៧:២៤)?

______________________________

______________________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

## II. ការផ្លាស់ប្រែ

កណ្ឌគម្ពីរ ជនគណនា ២១:៥-៩ បានកត់ត្រាពីរបៀបដែលកូនចៅអ៊ីស្រាអែលបានធ្វើបាបទាស់ប្រឆាំងនឹងព្រះជាម្ចាស់ ហេតុដូច្នេះហើយបានជាព្រះជាម្ចាស់បញ្ជូនពស់ពិសជាច្រើនឲ្យចឹកពួកគេ ហើយបានបង្កឲ្យមានអ្នកស្លាប់ជាច្រើន។ ពួកបណ្ដាជនទាំងនោះបានទទួលស្គាល់អំពើបាបរបស់ពួកគេ ហើយបានទូលសូមព្រះជាម្ចាស់ឲ្យជួយសង្គ្រោះពួកគេ។ ពេលនោះព្រះជាម្ចាស់បានបញ្ជាឲ្យលោក ម៉ូសេ ដាក់ពស់លង្ហិនក្រហមដូចហិមៈនៅលើបង្គោលមួយ ហើយនៅពេលណាដែលមានអ្នកណាមួយត្រូវពស់ចឹក នោះគេអាចក្រឡេកមើលទៅវា ដើម្បីឲ្យបានសង្គ្រោះ។ នៅក្នុងរបៀបមួយដែលពន្យល់ពីការផ្លាស់ប្រែ មិនថាជាយ៉ាងណានោះទេគឺយើងមានព្រះរាជបុត្រារបស់ព្រះជាម្ចាស់នៅលើឈើឆ្កាងមកដាក់ជំនួសសត្វពស់ដែលនៅលើឈើនោះវិញ។

### ក) ការបើកសម្ដែងឲ្យស្គាល់ពីបាប

១. តើព្រះជាម្ចាស់បានប្រទានអ្វីដល់មនុស្សលោក ដើម្បីសម្ដែងឲ្យពួកគេស្គាល់បាបរបស់ខ្លួន (រ៉ូម ៣:២០)? ________________________

២. តើពេលដែលបណ្ដាជនបានទទួលស្គាល់ពីកំហុសដែលពួកគេបានឆ្កាងព្រះគ្រីស្ទ នៅពេលនោះពួកគេមានអារម្មណ៍យ៉ាងណានៅក្នុងចិត្តរបស់ពួកគេ (កិច្ចការ ២:៣៦-៣៧)?

________________________

### ខ) ការប្រែចិត្តចេញពីបាប

១. ហេតុអ្វីបានជាអ្នកយកពន្ធស្រែកទ្រហោយំដាក់ព្រះជាម្ចាស់នៅក្នុងព្រះវិហារ (លូកា ១៨:១៣)?

________________________

២. យោងតាមកណ្ឌគម្ពីរ ២កូរិនថូស ៧:៩-១០ តើសេចក្ដីព្រួយដែលគាប់ព្រះហឫទ័យព្រះជាម្ចាស់ទៅលើបាបដែលយើងប្រព្រឹត្តនោះ នាំឲ្យមានអ្វីកើតឡើង (ខ១០)?

________________________

តើវានាំទៅរកអ្វី (ខ១០)?

________________________

---

ការប្រែចិត្តមានន័យថា បែរចេញពីបាប ហើយវិលទៅរកព្រះជាម្ចាស់។

---

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

**គ) ការវិលទៅរកព្រះគ្រីស្ទ**

នៅពេលដែលពួកបណ្ដាជនត្រូវពស់ពិសចឹក ហើយនាំគ្នាក្រឡេកមើលទៅលើពស់ដែលនៅលើឈើ ពេលនោះគឺពួកគេកំពុងតែហ្វឹកហាត់ពីជំនឿលើអ្វីដែលព្រះជាម្ចាស់បានមានបន្ទូល។

១. តើមានសេចក្ដីសន្យាបែបណាចំពោះអស់អ្នកដែលអំពាវនាវរកព្រះនាមព្រះអម្ចាស់ (រ៉ូម ១០:១៣)?

________________________________________

២. សូមអានកណ្ឌគម្ពីរ រ៉ូម ១០:៨-១០។ សេចក្ដីសង្គ្រោះទាមទារឲ្យមានជំនឿ។

ក) តើមាត់របស់លោកអ្នកដាច់ខាតត្រូវទទួលថ្លែងប្រាប់យ៉ាងដូចម្ដេច (ខ៩)?

________________________________________

ខ) តើលោកអ្នកដាច់ខាតត្រូវជឿថាយ៉ាងម៉េច (ខ៩)?

________________________________________

---

ជំនឿមានន័យថា ការជឿទុកចិត្តលើ ការប្រកាន់ខ្ជាប់ទៅនឹង ឬក៏ការឱបក្រសោបយកព្រះយេស៊ូវគ្រីស្ទដែលជាស្នូលនៃជំនឿរបស់យើង។

---

**ឃ) ការក្លាយទៅជាបាវបម្រើនៃសេចក្ដីសុចរិត**

១. សូមអានកណ្ឌគម្ពីរ រ៉ូម ៨:១-២។

ក) តើទោសនៃអំពើបាបរបស់អស់អ្នកជឿដែលនៅក្នុងព្រះគ្រីស្ទមានអ្វីខ្លះ (ខ១)?

________________________________________

ខ) តើអ្នកជឿបានសេរីភាពមកពីណា (ខ២)?

________________________________________

ហើយមានអ្វីទៀត ______________________________

២. នៅពេលដែលបានរួចពីបាបហើយ តើអ្នកជឿក្លាយទៅជាអ្វី (រ៉ូម ៦:១៨)?

________________________________________

៣. តើអត្ថប្រយោជន៍នៃផលនោះគឺជាអ្វី (រ៉ូម ៦:២២)?

________________________________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

ការញែកជាបរិសុទ្ធ គឺជាដំណើរនៃការចាប់ផ្ដើមត្រាប់តាម
រូបអង្គរបស់ព្រះយេស៊ូវគ្រីស្ទ។

## III. ភស្តុតាងនៃសេចក្ដីសង្គ្រោះ

ភស្តុតាងដ៏សំខាន់បីយ៉ាងរបស់អ្នកជឿដ៏ពិតប្រាកដម្នាក់គឺ៖ ជំនឿដែលមានការប្រព្រឹត្ត សេចក្ដីស្រឡាញ់ដែលធ្វើការដោយនឿយហត់ និងសេចក្ដីសង្ឃឹមយ៉ាងមាំមួន (១ថែស្សាឡូនីច ១:៣-៤)។

**ក) ជំនឿដែលមានការប្រព្រឹត្ត**

១. តើមានអ្វីដែលបង្ហាញឲ្យដឹងថាជាជំនឿដ៏ពិត?

ក) យ៉ាកុប ២:១៨

ខ) ១ពេត្រុស ១:៦-៧

២. តើព្រះជាម្ចាស់រៀបចំអ្នកជឿជាមុនដើម្បីអ្វី (អេភេសូរ ២:១០)?

៣. តើកណ្ឌគម្ពីរ ទីតុស ៣:៨ ចែងថា អស់អ្នកណាដែលបានជឿដល់ព្រះជាម្ចាស់ គួរធ្វើអ្វីខ្លះទៅ? ហេតុអ្វី?

**ខ) សេចក្ដីស្រឡាញ់ដែលធ្វើការដោយនឿយហត់**

១. ក្រៅពីជំនឿ តើមានអ្វីផ្សេងទៀតដែលព្រះជាម្ចាស់កត់ចំណាំនៅក្នុងអ្នកជឿ (ហេព្រើរ ៦:១០)?

២. តើប្រភពនៃសេចក្ដីស្រឡាញ់នៅក្នុងជីវិតរបស់អ្នកជឿគឺជាអ្វី (រ៉ូម ៥:៥)?

៣. តើបុគ្គលដែលបានកើតជាថ្មីក្នុងព្រះយេស៊ូវមានអត្តចរិតបែបណា (១យ៉ូហាន ៤:៧-៨)?

៤. តើអ្នកជឿដ៏ពិតម្នាក់បង្ហាញសេចក្ដីស្រឡាញ់ដោយរបៀបណា (១យ៉ូហាន ៣:១៨-១៩)?

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

**គ) សេចក្តីសង្ឃឹមយ៉ាងមាំមួន**

១. តើព្រះយេស៊ូវបានមានបន្ទូលថា អ្នកណានឹងបានសង្គ្រោះ (ម៉ាថាយ ១០:២២)?

________________________________________

២. តើមានអ្វីដែលជំរុញចិត្តយើងឲ្យទ្រាំទ្រ (១ធីម៉ូថេ ៤:១០)?

________________________________________

៣. ចូរពណ៌នាពីសេចក្តីសង្ឃឹមដែលគ្រីស្ទបរិស័ទមាន៖

ក) កាឡាទី ៥:៥

________________________________________

ខ) ១ថែស្សាឡូនីច ៥:៨

________________________________________

គ) ទីតុស ៣:៧

________________________________________

**ឃ) សេចក្តីបីយ៉ាងដែលស្ថិតស្ថេរ**

តើការបីយ៉ាងដែលសាវ័ក ប៉ុល បានគូសចំណាំនៅក្រុងកូល៉ុសមានអ្វីខ្លះ (កូល៉ុស ១:៤-៥)?

១. ________________________________________

២. ________________________________________

៣. ________________________________________

## IV. ការអនុវត្ត

ព្រះជាម្ចាស់មានអធិបតេយ្យភាពនៅក្នុងការសង្គ្រោះ។ ព្រះជាម្ចាស់មិនបានត្រាស់ហៅអ្នកជឿឲ្យមកឯសេចក្តីសង្គ្រោះដោយសារតែតម្លៃរបស់គេទេ ប៉ុន្តែដោយសារតែបំណងព្រះហឫទ័យ និងព្រះគុណរបស់ទ្រង់វិញ (អេភេសូរ ១:៣-១៤)។

**ក) បន្ទាប់ពីបានដឹងថា ព្រះជាម្ចាស់បានជ្រើសរើសលោកអ្នកសម្រាប់សេចក្តីសង្គ្រោះ តើលោកអ្នកគួរឆ្លើយតបទៅទ្រង់វិញយ៉ាងដូចម្តេច (អេភេសូរ ១:៤)?**

________________________________________

________________________________________

________________________________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

**ខ) តើខគម្ពីរត្រង់នេះណែនាំលោកអ្នកឲ្យរស់នៅយ៉ាងដូចម្ដេច (រ៉ូម ៦:១២-១៣)?**

អ្នកជឿដ៏ពិតនឹងភ្ញាក់ដឹងខ្លួនពីបាប ហើយបែរចេញពីវា។ ហើយអ្នកនោះនឹងមានបំណងចិត្តចុះចូលចំពោះព្រះជាម្ចាស់ ហើយនិងដើរតាមព្រះគ្រីស្ទ។ អ្នកជឿដ៏ពិតនឹងបង្ហាញពីៈ

- ជំនឿដែលមានការប្រព្រឹត្ត
- សេចក្ដីស្រឡាញ់ដែលធ្វើការដោយនឿយហត់
- សេចក្ដីសង្ឃឹមយ៉ាងមាំមួន

គុណសម្បត្តិទាំងបីខាងលើនេះគឺមានជាប់នៅជាមួយគ្រប់អ្នកជឿដ៏ពិត ហើយក៏តម្រែតម្រង់ទិសដៅនៃជីវិតរបស់អ្នកជឿដ៏ពិតនោះដែរ។ សូមអានកណ្ឌគម្ពីរ ទំនុកដំកើង ១១៦:១៦-១៧។ ចាប់ពីថ្ងៃនេះទៅ តើមានការអនុវត្តណាខ្លះដែលលោកអ្នកអាចធ្វើបាន?

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

មេរៀនទី៧

# បុគ្គលភាព និងព័ន្ធកិច្ចរបស់ព្រះវិញ្ញាណបរិសុទ្ធ

**ខគម្ពីរចងចាំ៖ យ៉ូហាន ១៤:១៦**
នោះខ្ញុំនឹងទូលសូមដល់ព្រះវរបិតា ហើយទ្រង់នឹងប្រទានព្រះដ៏ជាជំនួយ១អង្គទៀតមកអ្នករាល់គ្នាឲ្យបានគង់នៅជាមួយ នៅអស់កល្បរៀងទៅ។

ព្រះវិញ្ញាណបរិសុទ្ធគឺជាព្រះជាម្ចាស់។ ព្រះគម្ពីរបញ្ជាក់ប្រាប់ថា ទ្រង់គឺជាបុគ្គល១នៃបុគ្គលទាំង៣ដែលសម្តែងចេញមកជាព្រះ១អង្គ នោះគឺ ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ។ នៅក្នុងមេរៀននេះយើងនឹងសិក្សាឲ្យដឹងពី ព្រះវិញ្ញាណបរិសុទ្ធជាអ្នកណា ព្រមទាំងព្រះវត្តមាន និងពីព័ន្ធកិច្ចដែលទ្រង់ធ្វើនៅក្នុងជីវិតអ្នកជឿ។

## I. ព្រះវិញ្ញាណបរិសុទ្ធជាបុគ្គលមួយ

### ក) ទទួលស្គាល់ថាជាបុគ្គលមួយ

សព្វនាមបុរិសៈដូចជាពាក្យថា “ព្រះអង្គ” ឬ “ទ្រង់” បានយកមកប្រើសំដៅទៅលើព្រះវិញ្ញាណបរិសុទ្ធមិនមែនប្រើពាក្យថា “វា”។ សូមសរសេរពីចំនួនតួលេខលើពាក្យថា “ព្រះអង្គ” ឬ “ទ្រង់” ដែលបានប្រើនៅក្នុងកណ្ឌគម្ពីរ យ៉ូហាន ១៤:១៧ សំដៅទៅលើព្រះវិញ្ញាណបរិសុទ្ធ។

______________________________

### ខ) លក្ខណសម្បត្តិនៃបុគ្គលិកលក្ខណៈ

១. **បញ្ញា៖** ទ្រង់កាន់កាប់លើសមត្ថភាពក្នុងការស្គាល់ និងយល់ដឹងលើអ្វីៗដែលកើតឡើងជាក់ស្តែង។

ក) រ៉ូម ៨:២៧៖ ព្រះវិញ្ញាណបរិសុទ្ធមាន

______________________________

ខ) ១កូរិនថូស ២:១០៖ ព្រះវិញ្ញាណបរិសុទ្ធស្ទង់មើល

______________________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

គ) ១កូរិនថូស ២:១១៖ ព្រះវិញ្ញាណបរិសុទ្ធស្គាល់

________________________________

២. **អារម្មណ៍៖** ទ្រង់កាន់កាប់លើសមត្ថភាពដើម្បីទទួលយកបទពិសោធន៍ខាងអារម្មណ៍។ ចូរសរសេរលក្ខណសម្បត្តិផ្នែកអារម្មណ៍នៃព្រះវិញ្ញាណបរិសុទ្ធដែលដកស្រង់ពីកណ្ឌគម្ពីរអេភេសូរ ៤:៣០។ ________________________________

________________________________

៣. **ឆន្ទៈ៖** ទ្រង់កាន់កាប់លើសមត្ថភាពដើម្បីប្ដេជ្ញា ឬធ្វើដោយមិនរារែក។ សូមសរសេរការសម្រេចចិត្ត ឬក៏ការវិនិច្ឆ័យទោសដែលព្រះវិញ្ញាណបរិសុទ្ធបង្ហាញឲ្យឃើញក្នុងឆន្ទៈរបស់ទ្រង់។

ក) ១កូរិនថូស ១២:៧, ១១

________________________________

________________________________

ខ) កិច្ចការ ១៣:២

________________________________

## II. ព្រះវិញ្ញាណបរិសុទ្ធគឺជាព្រះជាម្ចាស់

### ក) លក្ខណសម្បត្តិផ្សេងៗ

**ព្រះវិញ្ញាណបរិសុទ្ធ៖ លក្ខណសម្បត្តិផ្សេងៗនៃភាពជាព្រះ**

| | | |
|---|---|---|
| សព្វញ្ញាណ | ជ្រាបគ្រប់ទាំងអស់ | អេសាយ ៤០:១៣-១៤ |
| សព្វវត្តមាន | គង់នៅគ្រប់ទីកន្លែង | ទំនុកដំកើង ១៣៩:៧ |
| នៅអស់កល្ប | គ្មានការចាប់ផ្ដើមនិងទីបញ្ចប់ | ហេព្រើរ ៩:១៤ |
| ការប្រកាន់ខ្ជាប់នូវសេចក្ដីពិត | ភាពស្អាតស្អំ | ១យ៉ូហាន ៥:៧, យ៉ូហាន ១៦:១៣ |

### ខ) សេចក្ដីថ្លែងផ្សេងៗនៃភាពជាព្រះ

១. ចូរសរសេរសេចក្ដីថ្លែងគន្លឹះដែលបង្ហាញថា ព្រះវិញ្ញាណបរិសុទ្ធជាព្រះជាម្ចាស់ (២កូរិនថូស ៣:១៧)៖

________________________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

២. យោងតាមកណ្ឌគម្ពីរ កិច្ចការ ៥:៣-៤ ការនិយាយកុហកព្រះវិញ្ញាណបរិសុទ្ធគឺជាការនិយាយកុហកទៅនឹង ______________________________

______________________________

## III. កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ

**ក) កណ្ឌគម្ពីរ ទំនុកដំកើង ១០៤:៣០ ចែងថា ព្រះវិញ្ញាណបរិសុទ្ធមានចំណែកនៅក្នុង ______________________________**

**ខ) កណ្ឌគម្ពីរ ២ពេត្រុស ១:២០-២១ ប្រាប់យើងថា ព្រះវិញ្ញាណបរិសុទ្ធក៏មានសកម្មភាពនៅក្នុង ______________________________**

---

**ព្រះវិញ្ញាណបរិសុទ្ធជាស្មរបន្ទាល់របស់ព្រះគ្រីស្ទ**

| | |
|---|---|
| បញ្ជាក់ថាព្រះយេស៊ូវគឺជាព្រះគ្រីស្ទ | យ៉ូហាន ១៥:២៦ |
| នឹងបើកបង្ហាញឲ្យគេដឹងពីព្រះគ្រីស្ទ | យ៉ូហាន ១៦:១៤ |
| នឹងមានបន្ទូល មិនមែនដោយអាងព្រះអង្គទ្រង់ទេ | យ៉ូហាន ១៦:១៣ |

---

## IV. ព័ន្ធកិច្ចរបស់ព្រះវិញ្ញាណបរិសុទ្ធក្នុងការសង្គ្រោះ

ផ្នែកដ៏សំខាន់ជាងគេមួយនៃព័ន្ធកិច្ចរបស់ព្រះវិញ្ញាណបរិសុទ្ធគឺរួមជាមួយនឹងការគោរពចំពោះផែនការរបស់ព្រះជាម្ចាស់ក្នុងការសង្គ្រោះ។

**ក) តើព័ន្ធកិច្ចដ៏ពិសេសដែលព្រះវិញ្ញាណបរិសុទ្ធធ្វើនោះគឺជាអ្វី (យ៉ូហាន ១៦:៧-៨)?**

______________________________

**ខ) តើអ្នកណាអាចធ្វើឲ្យមនុស្សមានបាបអាចកើតជាថ្មីក្នុងនគរព្រះបាន (យ៉ូហាន ៣:៥-៨)?**

______________________________

**គ) តើព្រះវិញ្ញាណបរិសុទ្ធធ្វើកិច្ចការអ្វី នៅពេលដែលមនុស្សម្នាក់បានសង្គ្រោះ?**

១. ទីតុស ៣:៥-៦ ______________________________

______________________________

២. ១កូរិនថូស ១២:១៣ ______________________________

______________________________

ពិធីបុណ្យជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធកើតឡើងតែមួយដងគត់ចំពោះអ្នកជឿ
គឺនៅពេលដែលគេទទួលការសង្គ្រោះពីព្រះយេស៊ូវ។

**ឃ) តើព្រះវិញ្ញាណបរិសុទ្ធធានាពីសេចក្តីសង្គ្រោះរបស់អ្នកជឿយ៉ាងដូចម្តេច (អេភេសូរ ១:១៣-១៤)?**

______________________________

______________________________

**ត្រានៃព្រះវិញ្ញាណបរិសុទ្ធ**

ត្រាគឺជាឧបករណ៍បុរាណមួយ ដែលជាធម្មតាមានរាងដូចជាចិញ្ចៀនត្រា ឬក៏មានរាងស៊ីឡាំងដែលមានឈ្មោះម្ចាស់ ឬក៏មានក្បាច់រចនាខ្លួងចូលក្នុង។ គេប្រើត្រានោះដើម្បីបោះត្រាទៅលើទំនិញដែលបញ្ជាក់ពីកម្មសិទ្ធិរបស់ម្ចាស់ ហើយបញ្ជាក់ថា ឯកសារត្រឹមត្រូវឬមិនត្រឹមត្រូវ ឬក៏ចង់បញ្ជាក់ពីអត្តសញ្ញាណនៅក្នុងមុខជំនួញនោះ។

ត្រាបង្ហាញប្រាប់ពីភាពជាម្ចាស់ និងសុវត្ថិភាព។ វាគឺជាការអះអាងពីការប្រទានពរបន្ថែមនៅថ្ងៃអនាគត។ ព្រះវត្តមានរបស់ព្រះវិញ្ញាណបរិសុទ្ធដែលគង់នៅក្នុងជីវិតរបស់យើងគឺជាសេចក្តីសន្យារបស់ព្រះជាម្ចាស់ដែលថា យើងនឹងទទួលកេរ្តិ៍មរតកនៅថ្ងៃអនាគត។ នេះគឺជាការអះអាងមួយដ៏អស្ចារ្យ![១]

## V. ព័ន្ធកិច្ចរបស់ព្រះវិញ្ញាណបរិសុទ្ធនៅក្នុងជីវិតរបស់អ្នកជឿ

**ក) តើទំនាក់ទំនងរវាងព្រះវិញ្ញាណបរិសុទ្ធ និងអ្នកជឿគឺជាអ្វី (រ៉ូម ៨:៩)?**

______________________________

______________________________

១. ដកស្រង់ចេញពីសៀវភៅ *The Zondervan Pictorial Encyclopedia of the Bible*, លេខ៥, កែសម្រួលដោយ Merrill C. Tenny, © ១៩៧៥, ១៩៧៦ ដោយ The Zondervan Corporation។

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

**ខ) តើការក្លាយជាគ្រីស្ទបរិស័ទ ហើយមិនមានព្រះវិញ្ញាណបរិសុទ្ធសណ្ឋិតនៅជាមួយនោះអាចទៅរួចដែរឬទេ?** ______________________

______________________

**គ) តើព័ន្ធកិច្ចផ្សេងទៀតរបស់ព្រះវិញ្ញាណបរិសុទ្ធនៅក្នុងជីវិតអ្នកជឿមានអ្វីទៀត (១កូរិនថូស ២:១២-១៣)?**

______________________

______________________

**ឃ) តើការដាស់តឿនសម្រាប់អ្នកជឿគ្រប់រូប ទាក់ទងនឹងព្រះវិញ្ញាណបរិសុទ្ធនោះគឺជាអ្វី?**

១. អេភេសូរ ៤:៣០ ______________________

______________________

២. ១ថែស្សាឡូនីច ៥:១៩ ______________________

៣. អេភេសូរ ៥:១៨ ______________________

______________________

---

**ការពេញដោយព្រះវិញ្ញាណបរិសុទ្ធ**

*«ដើម្បីឲ្យបានពេញដោយព្រះវិញ្ញាណបរិសុទ្ធគឺត្រូវ នៅក្រោមអំណាចគ្រប់គ្រងរបស់ទ្រង់។ ដើម្បីឲ្យបានពេញដោយព្រះវិញ្ញាណបរិសុទ្ធគឺត្រូវ លន់តួសារភាពបាប លះបង់បំណងចិត្ត បញ្ញា រូបកាយ ពេលវេលា ទេពកោសល្យ ភាពជាម្ចាស់ និងការប៉ងប្រាថ្នាផ្សេងៗចោល។ ការនេះទាមទារឲ្យសម្លាប់ភាពអាត្មានិយម និងការរកប្រយោជន៍តែខ្លួនឯងចេញ។ ដើម្បីឲ្យបានពេញដោយព្រះវិញ្ញាណបរិសុទ្ធគឺត្រូវតែពេញដោយព្រះបន្ទូលរបស់ទ្រង់។ ហើយនៅពេលណាដែលយើងបានពេញដោយព្រះបន្ទូលរបស់ទ្រង់ នោះព្រះបន្ទូលនឹងឃុំគ្រងគំនិត និងទង្វើរបស់យើងជាមិនខាន។»*

— លោកគ្រូ ចន មែកខធ័រ (John MacArthur)[២]

---

**ង) តើគ្រីស្ទបរិស័ទម្នាក់អាចគេចផុតពីការប្រព្រឹត្តបាបបានដោយរបៀបណា (កាឡាទី ៥:១៦)?**

______________________

______________________

២. ដកស្រង់ចេញពីសៀវភៅ The MacArthur New Testament Commentary series, *Ephesians* (Moody), © ១៩៨៦ ដោយ John MacArthur។

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

**ច) នៅពេលដែលអ្នកជឿម្នាក់បានពេញដោយព្រះវិញ្ញាណបរិសុទ្ធ នោះគាត់នឹងបង្ហាញឲ្យឃើញពីផលផ្លែខាងឯវិញ្ញាណរបស់គាត់។ សូមអានកណ្ឌគម្ពីរ កាឡាទី ៥:២២-២៣ រួចមកសរសេរចុះនូវលក្ខណសម្បត្តិទាំងនោះខាងក្រោមនេះ៖**

១. ____________________  ៦. ____________________

២. ____________________  ៧. ____________________

៣. ____________________  ៨. ____________________

៤. ____________________  ៩. ____________________

៥. ____________________

---

*ចំណាំ៖ តើលោកអ្នកកំពុងតែបង្ហាញពីលក្ខណសម្បត្តិទាំងនោះនៅក្នុងជីវិតលោកអ្នកឲ្យគេឃើញដែរឬទេ?*

---

## VI. ការអនុវត្ត

នៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ៦:១៩-២០ សាវ័ក ប៉ុល សរសេរថា៖ «តើមិនដឹងទេឬអីថា រូបកាយអ្នករាល់គ្នាជាវិហារនៃព្រះវិញ្ញាណបរិសុទ្ធ ដែលអ្នករាល់គ្នាបានទទួលមកពីព្រះ ហើយអ្នករាល់គ្នាមិនមែនជារបស់ផងខ្លួនទេ ដ្បិតព្រះទ្រង់បាន ចេញថ្លៃលោះអ្នករាល់គ្នាហើយ ដូច្នេះ ចូរដំកើងព្រះនៅក្នុងរូបកាយ ហើយក្នុងវិញ្ញាណនៃអ្នករាល់គ្នា ដែលជារបស់ផងទ្រង់ចុះ»។

**ក) តើបទគម្ពីរខាងលើមានសារៈសំខាន់ចំពោះលោកអ្នកបែបណា?**

________________________________________

________________________________________

________________________________________

________________________________________

**ខ) តើលោកអ្នកត្រូវធ្វើអ្វីដើម្បីតម្កើងព្រះជាម្ចាស់នៅក្នុងរូបកាយរបស់ខ្លួន?**

________________________________________

________________________________________

________________________________________

________________________________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

មេរៀនទី៨

# ការអធិស្ឋាន និងអ្នកជឿ

**ខគម្ពីរចងចាំ៖ ភីលីព ៤:៦-៧**

កុំឲ្យខ្វល់ខ្វាយអ្វីឡើយ ចូរទូលដល់ព្រះ ឲ្យជ្រាបពីសេចក្ដីសំណូមរបស់អ្នករាល់គ្នា ក្នុងគ្រប់ការទាំងអស់ ដោយសេចក្ដីអធិស្ឋាន និងពាក្យទូលអង្វរ ទាំងពោលពាក្យអរព្រះគុណផង យ៉ាងនោះ សេចក្ដីសុខសាន្តរបស់ព្រះ ដែលហួសលើសពីអស់ទាំងគំនិតនឹងជួយការពារចិត្ត ហើយនិងគំនិតរបស់អ្នករាល់គ្នា ក្នុងព្រះគ្រីស្ទយេស៊ូវ។

គោលបំណងនៃការអធិស្ឋាន គឺដើម្បីបង្ហាញនូវការចុះចូលរបស់យើងចំពោះអធិបតេយ្យភាពរបស់ព្រះជាម្ចាស់ និងការជឿទុកចិត្តរបស់យើងចំពោះភាពស្មោះត្រង់របស់ទ្រង់។ ការអធិស្ឋានគឺជាខ្លឹមសារដែលយើងបង្ហាញពីគ្រប់ទាំងអ្វីៗនៅក្នុងដួងចិត្តរបស់យើងចំពោះព្រះវរបិតាដែលគង់នៅស្ថានសួគ៌ដ៏ខ្ពស់បំផុតដែលជាទីស្រឡាញ់ ព្រមទាំងពេញដោយប្រាជ្ញាញាណ។ ការអធិស្ឋានមិនមែនជាការឲ្យដំណឹងដល់ព្រះជាម្ចាស់នោះទេ ពីព្រោះទ្រង់ជ្រាបគ្រប់អ្វីៗទាំងអស់រួចទៅហើយ។ ការអធិស្ឋាននាំយើងទាំងអស់គ្នាចូលទៅក្នុងសេចក្ដីប្រកបដ៏ខ្ពង់ខ្ពស់ជាមួយព្រះជាម្ចាស់ ថ្វាយបង្គំទ្រង់ ហើយទទួលស្គាល់ទ្រង់ថាជាព្រះដែលប្រទាននូវអ្វីៗគ្រប់យ៉ាងដល់យើង។

## I. ធាតុដ៏ពិតនៃការអធិស្ឋាន

**ក) ចំពោះអ្នកជឿ ការអធិស្ឋានគឺជាការសិក្សាពីបទពិសោធន៍មួយដែលជាដាច់ខាតអ្នកនោះត្រូវតែអភិវឌ្ឍឆ្ពោះទៅរកការដាក់វិន័យខាងឯវិញ្ញាណ។**

១. យោងតាមកណ្ឌគម្ពីរ លូកា ១១:១ តើសិស្សម្នាក់នោះបានសូមអ្វីពីព្រះយេស៊ូវ?

___

២. សូមអានកណ្ឌគម្ពីរ រ៉ូម ៨:២៦។

ក) បើយោងតាមការលើកឡើងរបស់សាវ័ក ប៉ុល តើអ្នកណាជាអ្នកជួយយើងក្នុងការអធិស្ឋាន?

___

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

ខ) បន្ទាប់ពីការបំភ្លឺនេះមក តើយើងគួរធ្វើដូចម្ដេចនៅពេលដែលយើងមិនដឹងជាគួរអធិស្ឋានពីអ្វីនោះ?

______________________________________

______________________________________

**ខ) ការអធិស្ឋានគឺជាការទាក់ទងជាមួយព្រះជាម្ចាស់។ បទគម្ពីរបានប្រាប់យើងថា ព្រះជាម្ចាស់ចាប់អារម្មណ៍គ្រប់ទាំងការតយុទ្ធផ្ទាល់ខ្លួនរបស់ពួកយើង។**

១. តើកណ្ឌគម្ពីរ ទំនុកដំកើង ៣៤:១៥ ថ្លែងយ៉ាងដូចម្ដេចអំពីព្រះជាម្ចាស់?

______________________________________

______________________________________

២. តើស្ដេច ដាវីឌ បាននាំយកអ្វីមកនៅចំពោះព្រះជាម្ចាស់ ក្នុងការអធិស្ឋាន (ទំនុកដំកើង ១៤២:២)?

______________________________________

៣. តើបទគម្ពីរនេះបានលើកទឹកចិត្តយើងឲ្យចូលទៅកាន់ព្រះជាម្ចាស់យ៉ាងដូចម្ដេច (ហេព្រើរ ៤:១៦)?

______________________________________

______________________________________

៤. ទោះបីជាយើងមានអភ័យឯកសិទ្ធិក្នុងការចូលគាល់ព្រះជាម្ចាស់មែន តើកណ្ឌគម្ពីរ សាស្ដា ៥:២ ទូន្មានយើងឲ្យចេះប្រយ័ត្ននឹងអ្វីខ្លះ? ______________

______________________________________

៥. តើកណ្ឌគម្ពីរ ១ពេត្រុស ៥:៦-៧ ផ្ដល់ការកំសាន្តចិត្តបែបណាដល់អ្នកជឿគ្រប់រូប?

______________________________________

______________________________________

**គ) ការអធិស្ឋានមានប្រសិទ្ធភាពណាស់។ ការអធិស្ឋានអាចបំផ្លាស់បំប្រែស្ថានការណ៍ផ្សេងៗព្រមទាំងមនុស្សផងដែរ។ យើងបានទទួលការលើកទឹកចិត្តឲ្យអធិស្ឋានដោយជឿថានឹងទទួលបានលទ្ធផល។**

១. តើក្រុមជំនុំបានអធិស្ឋានសម្រាប់អ្នកណានៅក្នុងកណ្ឌគម្ពីរ កិច្ចការ ១២:៥?

______________________________________

______________________________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

២. តើព្រះជាម្ចាស់បានឆ្លើយតបនឹងការអធិស្ឋានរបស់ពួកគេយ៉ាងដូចម្ដេច (កិច្ចការ ១២:៧)?

______________________________

______________________________

៣. ក្រៅពីការឆ្លើយតប តើព្រះជាម្ចាស់ប្រទានអ្វីទៀតដល់អស់អ្នកដែលអធិស្ឋានដល់ទ្រង់ (ភីលីព ៤:៦-៧)?

______________________________

______________________________

---

*"សេចក្ដីទូលអង្វរដ៏អស់ពីចិត្តរបស់មនុស្សសុចរិត នោះពូកែណាស់"*
(យ៉ាកុប ៥:១៦)។

---

## II. ការអនុវត្តលើការអធិស្ឋាន

**ក) នៅក្នុងព្រះគម្ពីរទាំងមូល ព្រះជាម្ចាស់លើកទឹកចិត្ត និងបង្គាប់បញ្ជាដល់អ្នកជឿគ្រប់រូបឲ្យចេះស៊ូទ្រាំក្នុងការអធិស្ឋាន។**

១. កណ្ឌគម្ពីរ លូកា ១៨:១ បានបង្រៀនពួកសិស្សថា ពួកគេគួរតែអធិស្ឋានជាប្រចាំ និងមិនត្រូវ ______________________________

______________________________

២. តើព្រះជាម្ចាស់មានបំណងព្រះហឫទ័យចំពោះអ្នកជឿលើព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្ដេច (១ថែស្សាឡូនីច ៥:១៧)?

______________________________

៣. តើអ្នកជឿគ្រប់រូបគួរអធិស្ឋាននៅពេលណា (អេភេសូរ ៦:១៨)?

______________________________

**ខ) លោកអ្នកនឹងឃើញពីគោលការណ៍ណែនាំជាច្រើននៅក្នុងព្រះគម្ពីរដែលអាចជួយលោកអ្នកអភិវឌ្ឍការអនុវត្តលើការអធិស្ឋាន។**

១. យោងតាមរឿងប្រៀបធៀបក្នុងកណ្ឌគម្ពីរ លូកា ជំពូក១១ តើព្រះយេស៊ូវបានបង្រៀនអ្វីដល់សិស្សរបស់ទ្រង់ក្នុងការទន្ទឹងរង់ចាំ ប្រសិនបើពួកគេបានអធិស្ឋានឥតឈប់ឈរ (លូកា ១១:៥-១០)?

______________________________

______________________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

២. តើសេចក្តីតម្រូវដែលព្រះយេស៊ូវបង្រៀន ដើម្បីទទួលបានការឆ្លើយតបពីការអធិស្ឋាននោះគឺជាអ្វី (យ៉ូហាន ១៥:៧)?

______________________________________________

______________________________________________

៣. យោងតាមកណ្ឌគម្ពីរ ១យ៉ូហាន ៥:១៤ តើអ្វីទៅជាទំនុកចិត្តរបស់យើង នៅពេលយើងអធិស្ឋាន?

______________________________________________

---

**គំរូនៃសេចក្តីអធិស្ឋានរបស់ព្រះយេស៊ូវ៖ ម៉ាថាយ ៦:៩-១៣**

| | |
|---|---|
| អធិស្ឋានទៅព្រះជាម្ចាស់ | ឱព្រះវរបិតានៃយើងខ្ញុំដែលគង់នៅស្ថានសួគ៌អើយ |
| សរសើរតម្កើងទ្រង់ និយាយ | សូមឲ្យព្រះនាមទ្រង់បានបរិសុទ្ធ |
| ចុះចូលចំពោះទ្រង់ អធិស្ឋានថា | សូមឲ្យរាជទ្រង់បានមកដល់ សូមឲ្យព្រះហឫទ័យទ្រង់បានសម្រេច |
| សម្លឹងទៅកាន់ទ្រង់ ស្វែងរក | អាហារដែលត្រូវការថ្ងៃនេះ (សារធាតុ) |
| សារភាពចំពោះទ្រង់ ព្រមទទួល | សូមអត់ទោសសេចក្តីកំហុសរបស់យើងខ្ញុំ (បាប) |
| ពឹងផ្អែកលើទ្រង់ ទូលសូម | កុំនាំយើងខ្ញុំទៅក្នុងសេចក្តីល្បួង |
| ទុកចិត្តលើទ្រង់ សំណូម | ប្រោសយើងខ្ញុំឲ្យរួចពីសេចក្តីអាក្រក់វិញ |

---

**គ) សូមអានខគម្ពីរខាងក្រោមនេះ បន្ទាប់មកសរសេរពីឧបសគ្គខ្លះៗដែលរារាំងការឆ្លើយតបចំពោះការអធិស្ឋាន៖**

១. ទំនុកដំកើង ៦៦:១៨ ______________________________

______________________________________________

២. យ៉ាកុប ៤:៣ ______________________________

______________________________________________

៣. អេសាយ ៥៩:១-២ ______________________________

______________________________________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

### ផ្នែកសំខាន់បួនយ៉ាងនៃការអធិស្ឋាន

| | |
|---|---|
| ការសរសើរតម្កើង៖ | ឆ្លុះបញ្ចាំងមកលើព្រះអង្គទ្រង់ផ្ទាល់។ សូមសរសើរតម្កើងទ្រង់ចំពោះលក្ខណសម្បត្តិ តេជានុភាព និងអំណោយរបស់ទ្រង់ដែលអំណោយនោះគឺអង្គព្រះគ្រីស្ទ។ |
| ការលន់តួ៖ | ត្រូវសារភាពចំពោះព្រះជាម្ចាស់ថា លោកអ្នកបានប្រព្រឹត្តបាប។ លោកអ្នកត្រូវស្មោះត្រង់ ហើយចេះបន្ទាបខ្លួន។ សូមចងចាំថា ទ្រង់ស្គាល់ ហើយស្រឡាញ់លោកអ្នក។ |
| ការអរព្រះគុណ៖ | ចូរអរព្រះគុណព្រះជាម្ចាស់ចំពោះអ្វីៗដែលទ្រង់បានប្រទានមកលោកអ្នក ទោះបើការនោះពិបាកនឹងទទួលក៏ដោយ។ ការពោលពាក្យអរព្រះគុណរបស់លោកអ្នកនឹងជួយឲ្យលោកអ្នកឃើញពីបំណងព្រះហឫទ័យរបស់ទ្រង់។ |
| ការទូលអង្វរ៖ | បង្កើតឲ្យមានសំណូមជាក់លាក់។ សូមអធិស្ឋានសម្រាប់អ្នកដទៃជាមុន បន្ទាប់មកសម្រាប់ខ្លួនឯង។ |

## III. ការតយុទ្ធអធិស្ឋាន

**ក) ការអធិស្ឋានអាចជាកិច្ចការដ៏ពិបាកមួយ ប៉ុន្តែការនោះមិនគួរឲ្យយើងបោះបង់ចោលការអធិស្ឋាននោះឡើយ សូម្បីតែនៅពេលដែលវាតម្រូវឲ្យមានការលះបង់ក៏ដោយ។**

១. តើព្រះយេស៊ូវបានចំណាយពេលអធិស្ឋានយូរប៉ុណ្ណា មុនដែលទ្រង់ជ្រើសរើសយកសាវ័កទាំង១២ (លូកា ៦:១២)?

______________________________

២. ចូរពណ៌នាពីការខិតខំប្រឹងប្រែងរបស់ព្រះយេស៊ូវ នៅពេលដែលទ្រង់អធិស្ឋានដោយទន្ទឹងរង់ចាំឈើឆ្កាង (លូកា ២២:៤៤)?

______________________________

______________________________

៣. តើអ្វីទៅដែលអ្នកជឿគ្រប់រូបគួរធ្វើដោយប្រុងប្រយ័ត្ន នៅពេលដែលយើងព្យាយាមអធិស្ឋាន (កូល៉ុស ៤:២)?

______________________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

**ខ) សូម្បីតែនៅពេលដែលយើងមានសេចក្ដីសោយចិត្ត ឬបាក់ទឹកចិត្តក៏ដោយ យើងនៅតែអាចបន្តចូលទៅជិតព្រះជាម្ចាស់តាមរយៈការអធិស្ឋាន។**

១. តើហេតុអ្វីបានជាស្ដេច ដាវីឌ បាក់ទឹកចិត្ត (ទំនុកដំកើង ១៣:១-២)?

___

២. តើស្ដេច ដាវីឌ បានត្អូញត្អែរយ៉ាងដូចម្ដេច (ទំនុកដំកើង ២២:២)?

___

**គ) ព្រះជាម្ចាស់គ្រប់គ្រងលើការអធិស្ឋានដោយអធិបតេយ្យភាពរបស់ទ្រង់ ហើយទ្រង់ឆ្លើយតបតាមបំណងព្រះហឫទ័យរបស់ទ្រង់។**

១. សូមអានកណ្ឌគម្ពីរ ២កូរិនថូស ១២:៧-៩។

ក) តើសាវ័ក ប៉ុល បានអធិស្ឋានអំពីអ្វី?

___

ខ) តើសាវ័ក ប៉ុល បានអធិស្ឋានសម្រាប់ការនោះប៉ុន្មានដង?

___

គ) តើសាវ័ក ប៉ុល បានទទួលនូវអ្វីដែលគាត់បានសូមដែរឬទេ? ហេតុអ្វីបាន ឬ ហេតុអ្វីមិនបាន?

___

___

២. សូមអានកណ្ឌគម្ពីរ ម៉ាកុស ១៤:៣៥-៣៦។

ក) តើព្រះយេស៊ូវបានទូលសូមអ្វីពីព្រះវរបិតាទាក់ទងនឹង «ពេលវេលា» នៃការរងទុក្ខរបស់ទ្រង់?

___

ខ) ទន្ទឹមនឹងនោះដែរ តើព្រះយេស៊ូវមានព្រះហឫទ័យយ៉ាងដូចម្ដេចវិញ?

___

___

___

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

## IV. ការអនុវត្ត

សូមនិពន្ធទំនុកអធិស្ឋានសាមញ្ញមួយ ដោយប្រើផ្នែកសំខាន់បួនយ៉ាងនៃការអធិស្ឋាននៅទំព័រ៧៥។

---

សូមផ្ទេរគ្រប់ទាំងសំណូមពររបស់លោកអ្នកទៅក្នុងផែនការដែលប្រកបដោយប្រាជ្ញា និងក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចុះ ហើយបើកចិត្តទទួលចម្លើយរបស់ទ្រង់ដោយការអរព្រះគុណ។

---

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

មេរៀនទី៩

# ក្រុមជំនុំ៖ ការប្រកបគ្នា និងការថ្វាយបង្គំ

**ខគម្ពីរចងចាំ៖ ហេព្រើរ ១០:២៤-២៥**
ហើយត្រូវឲ្យយើងពិចារណាមើលគ្នាទៅវិញទៅមកដែរ ដើម្បីនឹងបណ្ដាលឲ្យមានសេចក្ដីស្រឡាញ់ ហើយឲ្យប្រព្រឹត្តការល្អផង ឥតលែងប្រជុំគ្នា ដូចជាអ្នកខ្លះធ្លាប់នោះឡើយ ត្រូវឲ្យកំឡាចិត្តគ្នាវិញ ឲ្យកាន់តែខ្លាំងឡើងផង តាមដែលឃើញថាថ្ងៃនោះជិតមកដល់ហើយ។

## I. ក្រុមជំនុំសកល

*"ក្រុមជំនុំសកលមិនមែនជាអាគារនោះទេ ប៉ុន្តែជាក្រុមមួយនៃអ្នកជឿ វាមិនមែនជាគណៈនិកាយ ឬក៏សហគមន៍អ្វីមួយនោះទេ ប៉ុន្តែជារូបកាយខាងវិញ្ញាណ។ ហើយក្រុមជំនុំក៏មិនមែនជាអង្គការណាមួយ ប៉ុន្តែជាការរួបរួម និងការប្រកបគ្នាដែលរួមបញ្ចូលអ្នកជឿគ្រប់រូប។"*
— លោកគ្រូ ចន មែកខធ៌រ (John MacArthur)[១]

**ក) សូមអានកណ្ឌគម្ពីរ កូល៉ុស ១:១៨ និង អេភេសូរ ៥:២៣។**

១. តើព្រះគ្រីស្ទមានតួនាទីអ្វីនៅក្នុងក្រុមជំនុំ? ____________________

____________________

២. តើដូចម្ដេចដែលហៅថា ក្រុមជំនុំ? ____________________

**ខ) តើព្រះគ្រីស្ទបានទិញក្រុមជំនុំដោយតម្លៃអ្វី (កិច្ចការ ២០:២៨)?**

____________________

១. ដកស្រង់ចេញពីសៀវភៅ *Body Dynamics*, ដោយ John MacArthur © ១៩៨២ ដោយ Scripture Press។

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

**គ) តើបុគ្គលម្នាក់អាចក្លាយជាសមាជិកនៃរូបកាយរបស់ព្រះគ្រីស្ទបានយ៉ាងដូចម្ដេច?**

១. កូល៉ុស ៣:១៥ ទ្រង់ ______________________________ ឲ្យមានរូបកាយតែមួយ។

២. ១កូរិនថូស ១២:១៣ យើង _________________________ ចូលក្នុងរូបកាយតែមួយ។

## II. ក្រុមជំនុំតាមតំបន់

ព្រះគម្ពីរសញ្ញាថ្មីពណ៌នាពីរបៀបដែលអ្នកជឿមកជួបជុំគ្នាជាក្រុមតូច ដើម្បីថ្វាយបង្គំព្រះគ្រីស្ទ ទទួលសេចក្ដីបង្រៀនមកពីព្រះគម្ពីរ ជួយដល់តម្រូវការរបស់គ្នាទៅវិញទៅមក អធិស្ឋាន ហើយនិងផ្សាយដំណឹងល្អ។

**ក) ការពណ៌នាពីក្រុមជំនុំតាមតំបន់**

១. តើអ្នកជឿទាំងឡាយជួបជុំគ្នានៅឯណា មុនពេលដែលពួកគេមានព្រះវិហារ (រ៉ូម ១៦:៥, ១កូរិនថូស ១៦:១៩)?

_______________________________________________

២. តើពួកគេបានមកជួបជុំគ្នានៅថ្ងៃណាក្នុងសប្ដាហ៍នោះ (កិច្ចការ ២០:៧)?

_______________________________________________

៣. ចូរសរសេរការបួនយ៉ាងដែលក្រុមជំនុំដំបូងបានធ្វើយ៉ាងខ្ជាប់ខ្ជួន (កិច្ចការ ២:៤២)៖

ក) _____________________________________________

ខ) _____________________________________________

គ) _____________________________________________

ឃ) _____________________________________________

**ខ) ការរៀបចំរបស់ក្រុមជំនុំតាមតំបន់**

១. អំណោយទានស្របតាមកណ្ឌគម្ពីរ អេភេសូរ ៤:១១-១២ ព្រះជាម្ចាស់បានប្រទានអំណោយទាន៤ប្រភេទដល់ក្រុមជំនុំ។

ក) សូមសរសេរពីអំណោយទាននោះដាក់ខាងក្រោមនេះ៖

_____________________________________________

_____________________________________________

_____________________________________________

_____________________________________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

ខ) តើព្រះជាម្ចាស់បានប្រទានអំណោយទានទាំងនេះឲ្យទៅក្រុមជំនុំដើម្បីរៀបចំពួកបរិសុទ្ធក្នុងគោលបំណងអ្វី (ខ១២)?

________________________________

________________________________

________________________________

២. ពួកចាស់ទុំ/អ្នកត្រួតត្រា

គុណសម្បត្តិរបស់ពួកចាស់ទុំ ឬក៏អ្នកត្រួតត្រាមានចែងនៅក្នុងកណ្ឌគម្ពីរ ១ធីម៉ូថេ ៣:១-៧ និង ទីតុស ១:៦-៩។

ក) តើទំនួលខុសត្រូវចម្បងពីរយ៉ាងក្នុងនាមជាចាស់ទុំម្នាក់មានអ្វីខ្លះ (១ពេត្រុស ៥:១-២)?

១. ________________________________

២. ________________________________

ខ) តើទំនួលខុសត្រូវរបស់អ្នកជឿគ្រប់រូបចំពោះពួកចាស់ទុំគឺជាអ្វី (ហេព្រើរ ១៣:១៧)?

________________________________

ហេតុអ្វី? ________________________________

________________________________

៣. អ្នកជំនួយ

អ្នកជំនួយត្រូវជួយពីតម្រូវការរបស់ក្រុមជំនុំ ស្ថិតនៅក្រោមការដឹកនាំរបស់ពួកចាស់ទុំក្នុងក្រុមជំនុំ។ គុណសម្បត្តិរបស់អ្នកជំនួយមានចែងនៅក្នុងកណ្ឌគម្ពីរ ១ធីម៉ូថេ ៣:៨-១៣។

៤. អវយវៈរបស់រូបកាយ

ក) តើកណ្ឌគម្ពីរ ហេព្រើរ ១០:២៥ បានដាស់តឿនអ្នកជឿគ្រប់រូបមិនឲ្យធ្វេសប្រហែសនឹងរឿងអ្វី?

________________________________

ខ) កណ្ឌគម្ពីរ ហេព្រើរ ១៣:៧ ណែនាំយើងអំពីអស់អ្នកដែលបង្រៀនព្រះបន្ទូលព្រះជាម្ចាស់ដល់យើង។ តើយើងគួរឆ្លើយតបដោយរបៀបណាវិញ? សូមជ្រើសរើសយកចម្លើយដែលត្រឹមត្រូវ។

- ☐ *យើងគួរលើកទឹកចិត្តអ្នកដទៃទៀតឲ្យចូលរួម ហើយស្ដាប់ការបង្រៀនរបស់ពួកគេ។*
- ☐ *យើងមិនគួរសង្ឃឹមឲ្យមាននូវប្រភេទនៃជំនឿដែលពួកគេមាននោះឡើយ។*
- ☐ *យើងគួរសង្កេតមើលពីជីវិតរបស់ពួកគេដែលមានចរិតដូចព្រះជាម្ចាស់ ហើយយើងគួរដើរតាមគំរូនៃជំនឿរបស់ពួកគេ។*

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

គ) តើយើងគួរប្រព្រឹត្តចំពោះអវយវៈផ្សេងៗទៀតនៃរូបកាយរបស់ព្រះគ្រីស្ទយ៉ាងដូចម្ដេច (១កូរិនថូស ១២:២៥)?

______________________________________________

៥. តើអ្នកដែលព្រះជាម្ចាស់បានតាំងឲ្យធ្វើជាគ្រូអធិប្បាយ និងគ្រូបង្រៀនគួរទទួលបានការផ្គត់ផ្គង់យ៉ាងដូចម្ដេច?

ក) ១កូរិនថូស ៩:១៤ ______________________________

ខ) កាឡាទី ៦:៦ ______________________________

## III. ការប្រកបគ្នា

ព្រះគម្ពីរប្រើពាក្យក្រិក «កូយណូនៀអ័រ» ដើម្បីពណ៌នាពីការប្រកបគ្នានៅក្នុងរូបកាយរបស់ព្រះគ្រីស្ទ។ ពាក្យនេះមានន័យថា «ការរួមជាមួយអ្នកដទៃដោយមានគោលបំណងតែមួយ»។ អត្ថន័យស្រដៀងគ្នានៅក្នុងភាសាឡាតាំងគឺ «ការប្ដូរចិត្តគំនិតគ្នាទៅវិញទៅមក» ដែលចង្អុលបង្ហាញពីការរួមចំណែកជាមួយគ្នារវាងអ្នកជឿ ហើយក៏ជាមួយព្រះជាម្ចាស់ដែរ។

**ក) ការរួបរួមគ្នានៅក្នុងក្រុមជំនុំ**

១. តើព្រះជាម្ចាស់មានបំណងព្រះហឫទ័យយ៉ាងណាចំពោះក្រុមជំនុំតាមតំបន់នានា (១កូរិនថូស ១:១០)?

______________________________________________

______________________________________________

២. សូមអានកណ្ឌគម្ពីរ អេភេសូរ ៤:២-៣។
តើមានអ្វីខ្លះដែលនឹងធ្វើឲ្យមានសេចក្ដីរួបរួមគ្នាថែមទៀត (ខ២)? ______________

______________________________________________

តើយើងគួរឆ្លើយតបបែបណា (ខ៣)?

______________________________________________

៣. សូមអានកណ្ឌគម្ពីរ ភីលីព ២:១-៤។ តើគន្លឹះសំខាន់ដើម្បីរក្សាការរួបរួមគ្នាក្នុងរូបកាយរបស់ព្រះគ្រីស្ទគឺជាអ្វី (ខ៣)? ______________________________

______________________________________________

**ខ) ការប្រកបជាមួយព្រះជាម្ចាស់ និង ជាមួយអ្នកជឿផ្សេងៗទៀត**

បទគម្ពីរបានចែងយ៉ាងច្បាស់ថា អ្នកជឿរីករាយក្នុងការប្រកបជាមួយៈ

១. ព្រះវរបិតា (១យ៉ូហាន ១:៣)

២. ព្រះរាជបុត្រា (១យ៉ូហាន ១:៣)

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

៣. ព្រះវិញ្ញាណបរិសុទ្ធ (២កូរិនថូស ១៣:១៤)

៤. អ្នកជឿផ្សេងៗទៀត (១យ៉ូហាន ១:៧)

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ តើអ្នកណាទៅដែលយើងមិនអាចមានការប្រកបដ៏ពិតប្រាកដជាមួយបាន (២កូរិនថូស ៦:១៤-១៥)?

________________________________________

**គ) ការប្រកបជាប់ទាក់ទងទៅនឹងការបម្រើគ្នាទៅវិញទៅមក**

ការប្រកបគ្នានៅក្នុងរូបកាយរបស់ព្រះគ្រីស្ទមានការទាក់ទងទៅនឹងការរួមរស់ជីវិតជាមួយគ្នា។ យោងតាមខគម្ពីរនីមួយៗខាងក្រោម តើគ្រីស្ទបរិស័ទគួរបម្រើគ្នាទៅវិញទៅមកយ៉ាងដូចម្ដេច?

១. រ៉ូម ១៤:១៩ ______________________________

២. កាឡាទី ៥:១៣ ______________________________

៣. កាឡាទី ៦:២ ______________________________

៤. យ៉ាកុប ៥:១៦ ______________________________

តើព្រះជាម្ចាស់បានប្រទានអំណោយទានអ្វីខ្លះមកគ្រីស្ទបរិស័ទគ្រប់ៗរូប ដើម្បីបម្រើអ្នកជឿផ្សេងៗនៅក្នុងក្រុមជំនុំ (១ពេត្រុស ៤:១០-១១)?

________________________________________

## IV. ការថ្វាយបង្គំ

ពេលដែលយើងថ្វាយបង្គំព្រះជាម្ចាស់ គឺជាពេលដែលយើងថ្វាយកិត្តិនាមដោយការគោរព ពីព្រោះទ្រង់គឺជាព្រះជាម្ចាស់។ ការថ្វាយបង្គំ គឺជាការទទួលស្គាល់បុគ្គលភាពរបស់ព្រះជាម្ចាស់ និស្ស័យ និងលក្ខណសម្បត្តិ ព្រមទាំងស្នាព្រះហស្តរបស់ទ្រង់។ ការថ្វាយបង្គំកើតមកពីការដឹងគុណដែលចេញពីចិត្ត និងការផ្តល់នូវសេចក្តីស្រឡាញ់ ការចំណាយពេលជាមួយព្រះជាម្ចាស់ និងការចុះចូលចំពោះទ្រង់។

**ក) ព្រះជាម្ចាស់រកអ្នកថ្វាយបង្គំដ៏ពិតប្រាកដ**

យោងតាមកណ្ឌគម្ពីរ យ៉ូហាន ៤:២៣-២៤ តើយើងត្រូវតែថ្វាយបង្គំព្រះជាម្ចាស់យ៉ាងដូចម្ដេច (ខ២៤)?

________________________________________

---

ប្រសិនបើយើងត្រូវថ្វាយបង្គំព្រះជាម្ចាស់ដោយសេចក្តីពិត (មិនខុសឆ្គង) នោះយើងត្រូវស្វែងយល់ឲ្យស្គាល់ពីលក្ខណសម្បត្តិ និងសកម្មភាពផ្សេងៗរបស់ទ្រង់។

---

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

**ខ) យើងថ្វាយបង្គំព្រះជាម្ចាស់ ពីព្រោះមានតែទ្រង់មួយប៉ុណ្ណោះដែលសក្តិសមទទួលភក្តីភាពដ៏មានតម្លៃខ្ពស់បំផុតពីយើង**

សូមអានកណ្ឌគម្ពីរ វិវរណៈ ៤:១០-១១ ហើយឆ្លើយសំណួរខាងក្រោមនេះ៖

១. តើព្រះជាម្ចាស់សក្តិសមនឹងទទួលអ្វី?

________________________________________

២. ហេតុអ្វី? ________________________________________

**គ) ការថ្វាយបង្គំព្រះជាម្ចាស់ទាក់ទងនឹងការសរសើរតម្កើងទ្រង់**

តើអ្នកនិពន្ធកណ្ឌគម្ពីរទំនុកដំកើងបានចែងថា មនុស្សគួរថ្វាយបង្គំព្រះជាម្ចាស់យ៉ាងដូចម្តេច (ទំនុកដំកើង ៦៦:៤)?

________________________________________

**ឃ) ការថ្វាយបង្គំព្រះជាម្ចាស់ទាក់ទងនឹងការគោរពដ៏ជ្រាលជ្រៅ**

១. តើនៅពេលដែលលោក ម៉ូសេ ថ្វាយបង្គំព្រះជាម្ចាស់លោកបានធ្វើអ្វីខ្លះ (និក្ខមនំ ៣៤:៨)?

________________________________________

២. តើការគោរពដ៏ជ្រាលជ្រៅចំពោះព្រះជាម្ចាស់នៅក្នុងខគម្ពីរផ្សេងៗខាងក្រោមនេះបានបង្ហាញអ្វីខ្លះ?

ក) និក្ខមនំ ៣៤:៨ ________________________________________

ខ) លូកា ៧:១-៧ ________________________________________

គ) វិវរណៈ ១:១៧ ________________________________________

---

*«មកចុះ យើងនឹងច្រៀងថ្វាយព្រះយេហូវ៉ា ចូរយើងឡើងសំឡេងដោយអំណរ ដល់ថ្មដានៃសេចក្តីសង្គ្រោះរបស់យើង ចូរយើងចូលទៅចំពោះទ្រង់ ដោយអរព្រះគុណ ចូរយើងឡើងសំឡេងថ្វាយទ្រង់ ដោយទំនុកដំកើងចុះ ដ្បិតព្រះយេហូវ៉ាទ្រង់ជាព្រះយ៉ាងធំ ហើយជាមហាក្សត្រយ៉ាងខ្ពស់លើអស់ទាំងព្រះ អស់ទាំងទីជំរៅនៃផែនដីនៅក្នុងព្រះហស្តទ្រង់ ហើយកំពូលភ្នំទាំងប៉ុន្មាន សុទ្ធតែជារបស់ផងទ្រង់ដែរ សមុទ្រជារបស់ផងទ្រង់ គឺទ្រង់ដែលបានបង្កើតមក ហើយគឺព្រះហស្តទ្រង់ដែលបានសូនធ្វើដីគោក មកចុះ ចូរយើងឱនកាយថ្វាយបង្គំទាំងអស់គ្នា ចូរយើងលុតជង្គង់នៅចំពោះព្រះយេហូវ៉ា ជាព្រះដ៏បង្កើតយើងខ្ញុំ»* (ទំនុកដំកើង ៩៥:១-៦)។

---

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

## V. បញ្ញត្តិនៃក្រុមជំនុំ

### បញ្ញត្តិនៃពិធីជ្រមុជទឹក

ព្រះជាម្ចាស់នៃយើងទ្រង់បានតម្រូវឲ្យធ្វើពិធីជ្រមុជទឹក ហើយក្រុមជំនុំដំបូងក៏បានអនុវត្តតាម។ ដូចដែលបទគម្ពីរបានពន្យល់ថា ពិធីជ្រមុជទឹកគឺជាការប្រកាសពីអត្តសញ្ញាណរបស់អ្នកជឿជាមួយនឹង៖ ការសុគត ការបញ្ចុះសព និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ។ ពិតប្រាកដណាស់ក្រុមជំនុំដំបូងបានអនុវត្តពិធីជ្រមុជទឹកនេះ ហេតុដូច្នេះហើយបានជាយើងជឿថា ក្រុមជំនុំបច្ចុប្បន្ននេះគួរតែអនុវត្តតាមបញ្ញត្តិនេះដែរ។

### ហេតុអ្វីបានជាយើងត្រូវធ្វើពិធីជ្រមុជទឹក?

យើងធ្វើពិធីជ្រមុជទឹកពីព្រោះ៖

- ជាព្រះរាជបញ្ជារបស់ព្រះជាម្ចាស់ — ម៉ាថាយ ២៨:១៩។
- ក្រុមជំនុំដំបូងបានអនុវត្តពិធីជ្រមុជទឹកនេះ — កិច្ចការ ២:៤១, ៨:២៦-៣៩, ១០:៤៤-៤៨, ១៦:៣១-៣៣, ១៨:៨។

### តើអ្នកណាខ្លះគួរតែទទួលពិធីជ្រមុជទឹក?

នៅក្នុងព្រះគម្ពីរយើងបានឃើញថា សិស្សរបស់ព្រះគ្រីស្ទ អ្នកជឿ ព្រមទាំងអស់អ្នកដែលបានទទួលព្រះវិញ្ញាណបរិសុទ្ធ ពួកគេសុទ្ធតែជាអ្នកបានទទួលពិធីជ្រមុជទឹក៖

- ពួកសិស្ស (ឬអ្នកដើរតាមព្រះយេស៊ូវ) — ម៉ាថាយ ២៨:១៩។
- អ្នកជឿ — កិច្ចការ ២:៤១, កិច្ចការ ៨:៣០-៣៨, កិច្ចការ ១៦:៣៣-៣៤។
- អ្នកដែលបានទទួលព្រះវិញ្ញាណបរិសុទ្ធ — កិច្ចការ ១០:៤៤-៤៨។

ហេតុដូច្នេះហើយបានជាយើងរួមបញ្ចូលអស់អ្នកដែលព្រមសារភាពយកព្រះយេស៊ូវគ្រីស្ទទុកជាព្រះអង្គសង្គ្រោះ និងជាព្រះអម្ចាស់ដោយខ្លួនគេផ្ទាល់ (ឧ. គ្រីស្ទបរិស័ទ) ត្រូវតែទទួលពិធីជ្រមុជទឹក។

### តើពិធីជ្រមុជទឹកមានន័យដូចម្ដេច?

ការទទួលពិធីជ្រមុជទឹក គឺជាការប្រកាសពីអត្តសញ្ញាណរបស់អ្នកជឿជាមួយព្រះជាម្ចាស់៖

- អត្តសញ្ញាណរបស់យើងជាមួយនឹងការសុគតរបស់ព្រះគ្រីស្ទ — រ៉ូម ៦:៣
- អត្តសញ្ញាណរបស់យើងជាមួយនឹងការបញ្ចុះក្នុងផ្នូររបស់ព្រះគ្រីស្ទ — រ៉ូម ៦:៤ក
- អត្តសញ្ញាណរបស់យើងជាមួយនឹងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ទ — រ៉ូម ៦:៤ខ

ពិធីជ្រមុជទឹកគឺជាការទទួលស្គាល់ថា “មនុស្សចាស់របស់យើង បានត្រូវឆ្កាងជាមួយនឹងទ្រង់ហើយ” (រ៉ូម ៦:៦) ហើយជាការដឹងមួយដែលថា ចាប់ពីពេលនេះទៅយើង “បានដើរក្នុងជីវិតបែបថ្មី” (រ៉ូម ៦:៤ខ)។

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

**តើយើងគួរធ្វើពិធីជ្រមុជទឹកដោយរបៀបណា?**
យើងជឿថា បុគ្គលម្នាក់គួរតែទទួលពិធីជ្រមុជទឹកដោយការជ្រមុជលិចចូលទៅក្នុងទឹក៖

- ពាក្យថា «ពិធីជ្រមុជទឹក» បកប្រែចេញពីពាក្យ «បាពតិហ្សូ» ដែលជាភាសាក្រិក (ជាភាសាដើមនៃព្រះគម្ពីរសញ្ញាថ្មី) មានន័យថា «ជ្រមុជឲ្យលិចតែម្តង»
- ពិធីជ្រមុជទឹកធ្វើនៅកន្លែងដែលមានទឹកច្រើន (យ៉ូហាន ៣:២៣)
- អ្នកទទួលពិធីជ្រមុជទឹកត្រូវចុះទៅក្នុងទឹក (កិច្ចការ ៨:៣៨) ហើយត្រូវឡើងពីទឹកវិញ (ម៉ាថាយ ៣:១៦)

ដូចគ្នាផងដែរ នៅពេលដែលអ្នកជឿធ្វើពិធីជ្រមុជទឹក ដោយជ្រមុជចូលទៅក្នុងទឹក ហើយងើបចេញពីទឹកឡើងវិញ នោះសម្គាល់ពីអត្តសញ្ញាណរបស់អ្នកជឿជាមួយនឹងការសុគត ការបញ្ចុះក្នុងផ្នូរ និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ទ។

តើលោកអ្នកមានបានសារភាពទទួលស្គាល់ថា ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់ និងជាព្រះអង្គសង្គ្រោះហើយឬនៅ? ____________________

តើលោកអ្នកមានបានទទួលពិធីជ្រមុជទឹក ក្នុងនាមជាអ្នកជឿម្នាក់ហើយឬនៅ?

____________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

**ពិធីលៀងព្រះអម្ចាស់**

ពិធីជប់លៀងរបស់ព្រះអម្ចាស់ ឬពិធីលៀងព្រះអម្ចាស់ គឺជាពិធីមួយក្នុងចំណោមពិធីពីរដែលព្រះយេស៊ូវគ្រីស្ទបានប្រទានមកក្រុមជំនុំ (ពិធីទីពីរនោះគឺពិធីជ្រមុជទឹក)។ ពិធីលៀងព្រះអម្ចាស់ គឺជាសកម្មភាពមួយនៃការនឹកចាំពីការសុគតរបស់ព្រះគ្រីស្ទ។

សូមអានកណ្ឌគម្ពីរ ១កូរិនថូស ១១:២៣-២៦ បន្ទាប់មកសូមបំពេញឃ្លាក្នុងចន្លោះខាងក្រោមនេះ។

១. នំប៉័ងគឺជាការនឹកចាំពី ____________________

២. ពែងគឺជាការនឹកចាំពី ____________________

៣. គ្រប់ពេលដែលលោកអ្នកចូលរួមក្នុងពិធីលៀងព្រះអម្ចាស់នោះមានន័យថា លោកអ្នកប្រកាសពីការសុគតរបស់ព្រះអម្ចាស់ (១កូរិនថូស ១១:២៦)។ យោងតាមសេចក្ដីពិតខាងលើនេះ តើសេចក្ដីបម្រាមមាននៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ១១:២៧-៣០ គឺជាអ្វី?

____________________

____________________

____________________

____________________

## VI. ការអនុវត្ត

**ក) តើលោកអ្នកជាអវយវៈនៃរូបកាយរបស់ព្រះគ្រីស្ទឬទេ?**

____________________

**ខ) តើលោកអ្នកជាសមាជិកនៃក្រុមជំនុំតាមតំបន់ឬទេ?**

____________________

**គ) តើលោកអ្នកបានរៀនអ្វីខ្លះចេញពីការសិក្សានេះ ដើម្បីធ្វើឲ្យការថ្វាយបង្គំព្រះជាម្ចាស់បានល្អប្រសើរថែមទៀត?**

____________________

____________________

____________________

____________________

____________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

មេរៀនទី១០

# អំណោយទានខាងឯវិញ្ញាណ

**ខគម្ពីរចងចាំះ ១កូរិនថូស ១២:៧**
ហើយទ្រង់ប្រទានឲ្យព្រះវិញ្ញាណសំដែងមកក្នុងគ្រប់គ្នា ដើម្បីឲ្យបានកើតផល។

ព្រះជាម្ចាស់ប្រទានអំណោយទានខាងឯវិញ្ញាណដល់អ្នកជឿក្នុងគោលបំណងនៃព័ន្ធកិច្ចក្រុមជំនុំ។ ពាក្យថា អំណោយទានបកប្រែចេញពីពាក្យ “ខារិស្មាតា” ជាភាសាក្រិក។ ហើយពាក្យឫសរបស់ “ខារិស្មាតា” គឺ “ខារិស៍” ដែលមានន័យថា “ព្រះគុណ” ទាក់ទងទៅនឹងអ្វីដែលមនុស្សមិនស័ក្តិសមនឹងទទួល។ ពាក្យថា “ខាងឯវិញ្ញាណ” បកប្រែចេញពីពាក្យ “ព្នូម៉ាតិកា” ដែលទាក់ទងទៅនឹងអ្វីដែលព្រះវិញ្ញាណបានប្រទានមក។ នៅក្នុងមេរៀននេះ លោកអ្នកនឹងមើលឃើញនូវអំណោយទានខាងឯវិញ្ញាណផ្សេងៗគ្នា និងពីរបៀបដែលអំណោយទានទាំងនោះត្រូវយកមកប្រើនៅក្នុងរូបកាយរបស់ព្រះគ្រីស្ទ។

## I. លក្ខណៈនៃអំណោយទានខាងឯវិញ្ញាណ

### ក) តើនរណាជាប្រភពនៃអំណោយទានខាងឯវិញ្ញាណ?

១. ១កូរិនថូស ១២:១១ ____________________

២. ១កូរិនថូស ១២:២៨ ____________________

### ខ) តើនរណាមានអំណោយទានខាងឯវិញ្ញាណ (១ពេត្រុស ៤:១០)?

____________________

____________________

### គ) តើគោលបំណងនៃអំណោយទានខាងឯវិញ្ញាណគឺជាអ្វី?

១. ១កូរិនថូស ១២:៤-៧ ____________________

____________________

២. ១កូរិនថូស ១៤:១២ ____________________

____________________

៣. ១ពេត្រុស ៤:១០-១១ ____________________

____________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

## II. ការប្រទានអំណោយទានខាងឯវិញ្ញាណ

### ក) អំណោយទានខាងឯវិញ្ញាណមានបញ្ជាក់នៅក្នុងបទគម្ពីរ

ចូរសរសេរអំណោយទានទាំងនោះនៅខាងក្រោមនេះ៖

១. រ៉ូម ១២:៦-៨

______________________________

______________________________

២. ១កូរិនថូស ១២:៨-១០

______________________________

______________________________

៣. ១កូរិនថូស ១២:២៨ខ (ពាក់កណ្ដាលបន្ទាប់នៃខគម្ពីរ)

______________________________

______________________________

### ខ) ការយល់ដឹងពីអំណោយទាន៖ អំណោយទានជាបណ្ដោះអាសន្ន

ដើម្បីឲ្យមានការយល់ដឹងកាន់តែប្រសើរឡើងពីមុខងារនៃអំណោយទានខាងឯវិញ្ញាណ គឺយើងបានបែងចែកអំណោយទាននោះជាពីរផ្នែក៖ បណ្ដោះអាសន្ន (ពិសេស) និងអចិន្ត្រៃយ៍។ ព្រះវិញ្ញាណបរិសុទ្ធបានប្រទានអំណោយទានបណ្ដោះអាសន្នមក ដើម្បីបញ្ជាក់បន្ថែមពីទីបន្ទាល់របស់ពួកសាវ័ក និងពួកហោរា។ អំណោយទានទាំងនេះជាទូទៅមាននៅក្នុងក្រុមជំនុំដំបូង ប៉ុន្តែលែងឃើញមានទៀតនៅពេលដែលក្រុមជំនុំកើតមានឡើង។

**១. ការអស្ចារ្យ**

អំណោយទាននេះ គឺជាសមត្ថភាពក្នុងការធ្វើ “ការអស្ចារ្យ” និង “ទីសម្គាល់”។ ព្រះគ្រីស្ទបានធ្វើការអស្ចារ្យជាច្រើន ដូចដែលបានកត់ទុកនៅក្នុងបទគម្ពីរ។ សាវ័ក ប៉ុល បានប្រើអំណោយទាននេះដើម្បីបញ្ជាក់ពីភាពជាសាវ័ករបស់គាត់ ដូចដែលបានពណ៌នានៅក្នុងកណ្ឌគម្ពីរ ២កូរិនថូស ១២:១២។

**២. ការប្រោសឲ្យជា**

សាវ័ក ពេត្រុស មានអំណោយទាននេះ ហើយនេះបញ្ជាក់ថា សាររបស់គាត់គឺពិតជាមកពីព្រះជាម្ចាស់ ព្រមទាំងបានជួយស្ថាបនាមូលដ្ឋានគ្រឹះសម្រាប់ក្រុមជំនុំ (សូមមើលកណ្ឌគម្ពីរ កិច្ចការ ៣:៦-៨, ៥:១៥-១៦)។

**៣. ភាសាដទៃនិងការបកប្រែភាសាដទៃ**

អំណោយទាននេះគឺសម្ដែងឲ្យឃើញដោយការនិយាយដែលអ្នកនិយាយនោះមិនចេះពីមុនមក (សូមមើលកណ្ឌគម្ពីរ កិច្ចការ ២:១-១១)។ អំណោយទាននេះត្រូវមកជាមួយអំណោយទានខាងការបកប្រែ (១កូរិនថូស ១៤:២៧-២៨)។

**គ) ការយល់ដឹងពីអំណោយទានៈ អំណោយទានដែលនៅស្ថិតស្ថេរ**

ព្រះវិញ្ញាណបរិសុទ្ធបានប្រទានអំណោយទានទាំងនេះដើម្បីនឹងស្អាងក្រុមជំនុំឡើង។ អំណោយទានទាំងនោះមានជាទូទៅក្នុងក្រុមជំនុំដំបូង ហើយវាក៏មាននៅក្នុងក្រុមជំនុំសព្វថ្ងៃនេះដែរ។

**១. ទំនាយ**

ទំនាយ គឺជាការអធិប្បាយ ឬការប្រាប់ជាមុន ឬក៏ការប្រកាសអំពីបទគម្ពីរ។ ទំនាយមិនចាំបាច់ត្រូវតែមានន័យថា ជាការប្រាប់ទុកជាមុនពីអនាគតនោះទេ។

**២. ការបង្រៀន**

អ្នកមានអំណោយទាននេះមានសមត្ថភាពក្នុងការបង្រៀនព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយអាចជួយអ្នកស្ដាប់ឲ្យយល់ពីបទគម្ពីរដូចព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យគេយល់។

**៣. ជំនឿ**

អំណោយទាននេះ គឺជាជំនឿដែលមិនផ្លាស់ប្ដូរ ជាជំនឿដែលបណ្ដាលឲ្យជឿលើព្រះជាម្ចាស់យ៉ាងពិតប្រាកដ ទោះបីជាជួបឧបសគ្គច្រើនលើសលុបហើយមើលទៅហួសពីសមត្ថភាពរបស់មនុស្ស ឬក៏កិច្ចការដ៏អស្ចារ្យយ៉ាងណាក៏ដោយ។ លោកគ្រូ ចន ម៉ែកខធ័រ (John MacArthur) ហៅអំណោយទាននេះថា "អំណោយទាននៃការអធិស្ឋាន" ពីព្រោះអំណោយទាននេះជាទូទៅគឺបានសម្ដែងឆ្ពោះទៅរកព្រះជាម្ចាស់តាមរយៈការអធិស្ឋាន។

**៤. ប្រាជ្ញា**

ប្រាជ្ញា គឺជាសមត្ថភាពដើម្បីអនុវត្តតាមប្រាជ្ញាដែលបានចម្រើនឡើងតាមរយៈការទទួលបានពីខាងឯវិញ្ញាណ ដើម្បីឲ្យអ្នកជឿគ្រប់គ្នាដឹងខុសដឹងត្រូវពេលដែលបានអនុវត្តតាមចំណេះដឹង។

**៥. ចំណេះដឹង**

ចំណេះដឹង គឺជាការយល់ដឹងមួយពីសេចក្ដីពិតនៃបទគម្ពីរ។ បើតាមទស្សនៈរបស់មនុស្ស ចំណេះដឹងគឺជាការសិក្សាដ៏ជ្រៅជ្រះ ឬក៏ជាសមត្ថភាពក្នុងការស្គាល់សេចក្ដីពិតនៃបទគម្ពីរ នៅក្នុងភាពយ៉ាងទូលំទូលាយ និងយ៉ាងជ្រាលជ្រៅ។

**៦. ការស្គាល់ខុសស្គាល់ត្រូវ**

ការស្គាល់ខុសស្គាល់ត្រូវ គឺជាសមត្ថភាពក្នុងការនិយាយប្រាប់ពីសេចក្ដីណាមួយដែលមកពីព្រះវិញ្ញាណ និងសេចក្ដីណាមួយដែលមិនមែនមកពីព្រះវិញ្ញាណ អាចវែកញែកសេចក្ដីពិតចេញពីសេចក្ដីមិនពិត។ ប្រើប្រាស់អំណោយទាននេះ ដើម្បីការពារក្រុមជំនុំ។

**៧. មេត្តាករុណា**

នេះគឺជាសមត្ថភាពដើម្បីបង្ហាញពីចិត្តអាណិតអាសូរចំពោះអស់អ្នកណាដែលមានតម្រូវការខាងឯវិញ្ញាណ ខាងឯសាច់ឈាម និងខាងឯផ្លូវចិត្ត។

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

**៨. ការទូន្មាន**

ការទូន្មាន គឺជាសមត្ថភាពក្នុងការលើកទឹកចិត្ត និងការជំរុញចិត្តនរណាម្នាក់។ បុគ្គលណា ដែលមានអំណោយទាននេះអាចអែបមកជិតអ្នកផ្សេងៗទៀត ដើម្បីសម្រាលទុក្ខគេដោយ ក្តីស្រឡាញ់ និងដើម្បីលើកទឹកចិត្តគេឲ្យប្តេជ្ញាក្នុងការលូតលាស់ខាងវិញ្ញាណឲ្យកាន់តែ ជ្រាលជ្រៅទៀត ឬក៏ដាស់តឿនគេឲ្យអនុវត្ត។

**៩. ការផ្តល់ឲ្យ**

អំណោយទាននេះ គឺសំដៅផ្ទាល់ទៅលើព័ន្ធកិច្ចនៃការផ្តល់ឲ្យដូចជា ម្ហូបអាហារ សម្លៀកបំពាក់ ប្រាក់កាក់ និងផ្ទះសម្បែង។ល។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ក្រុមជំនុំ។

**១០. ការគ្រប់គ្រង**

អំណោយទាននេះ គឺជាសមត្ថភាពក្នុងការមើលថែហ្វូងចៀម។ អំណោយទាននេះអាច មើលឃើញនៅក្នុងចំណោម គ្រូគង្វាល ចាស់ទុំ ក៏ដូចជាអ្នកដឹកនាំសហគមន៍បេសកជន បេសកកម្មយុវជន និងសមាគមន៍ផ្សាយដំណឹងល្អ។ល។

**១១. ជំនួយ**

អំណោយទាននេះ គឺជាសមត្ថភាពក្នុងការជួយឧបត្ថម្ភនៅពេលដែលមានតម្រូវការ ឬក៏ជួយ សម្រាលបន្ទុកគ្នាទៅវិញទៅមកតាមស្ថានការណ៍ដែលកើតមានឡើង។

**១២. ការបម្រើ**

អំណោយទាននៃការបម្រើ ធ្វើការសម្រាប់រូបកាយរបស់ព្រះគ្រីស្ទនៅក្នុងផ្នែកនៃព័ន្ធកិច្ចខាង ពលកម្ម ដូចជា ការបម្រើផ្នែកម្ហូបអាហារ ឬក៏ការថែទាំ។

## III. ការអនុវត្តអំណោយទានខាងវិញ្ញាណ

**ក) ចូរសរសេរពីគោលការណ៍ខ្លះៗដែលបានដាក់បង្ហាញនៅក្នុងកណ្ឌគម្ពីរ រ៉ូម ១២:៦-៨។**

______________________________

______________________________

**ខ) សូមអានកណ្ឌគម្ពីរ ១កូរិនថូស ១៣:១-៧ រួចឆ្លើយនឹងសំណួរខាងក្រោម៖**

១. តើអំណោយទានរបស់លោកអ្នកអាចនឹងប្រើខុស ឬគ្មានផលដោយរបៀបណា (ខ១-៣)?

______________________________

______________________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

២. ចាប់តាំងពីលោកអ្នកបានអនុវត្តអំណោយទានខាងឯវិញ្ញាណដោយក្តីស្រឡាញ់មក តើមានគោលការណ៍ណែនាំណាខ្លះដែលនឹងធានានូវគុណប្រយោជន៍នៃអំណោយទានរបស់លោកអ្នកបាន?

ចូរសរសេរគោលការណ៍ណែនាំចំនួន ១៥ ចំណុច (ខ៤-៧)៖

ក) ______________________________

ខ) ______________________________

គ) ______________________________

ឃ) ______________________________

ង) ______________________________

ច) ______________________________

ឆ) ______________________________

ជ) ______________________________

ឈ) ______________________________

ញ) ______________________________

ដ) ______________________________

ឋ) ______________________________

ឌ) ______________________________

ឍ) ______________________________

ណ) ______________________________

**គ) កណ្ឌគម្ពីរ ១កូរិនថូស ១២ បង្ហាញអំពីសារៈសំខាន់នៃអំណោយទានខាងឯវិញ្ញាណនីមួយៗនៅក្នុងរូបកាយរបស់ព្រះគ្រីស្ទ។**

យោងតាមកណ្ឌគម្ពីរ ១កូរិនថូស ១២:២៥ ក្នុងការប្រើប្រាស់អំណោយទានខាងឯវិញ្ញាណ តើលោកអ្នកគួរមានអាកប្បកិរិយាយ៉ាងដូចម្តេច?

______________________________

______________________________

**ឃ) យោងតាមកណ្ឌគម្ពីរ អេភេសូរ ៤:១១-១៦ តើមានអ្វីដែលធ្វើឲ្យរូបកាយរបស់ព្រះគ្រីស្ទរីកចម្រើនឡើង (ខ១៦)?**

______________________________

______________________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

## IV. ការអនុវត្ត

**ការរុករកអំណោយទានរបស់លោកអ្នក**

ព្រះជាម្ចាស់បានបញ្ជាអវយវៈនៃរូបកាយនីមួយៗឲ្យបម្រើគ្នាទៅវិញទៅមកក្នុងគ្រប់ផ្នែកដោយប្រើប្រាស់អំណោយទានផ្សេងៗ ទោះបីជាពួកគេមានឬមិនមានអំណោយទាននោះក៏ដោយ។ ឧទាហរណ៍៖ គ្រីស្ទបរិស័ទគ្រប់រូបត្រូវបំពេញមុខងារដូចតទៅ៖

ជំនឿ ............................................................ ២កូរិនថូស ៥:៧

ប្រាជ្ញា ............................................................ យ៉ាកុប ១:៥

ចំណេះដឹង ...................................................... ២ធីម៉ូថេ ២:១៥

ការទូន្មាន ...................................................... ហេព្រើរ ១០:២៥

ការផ្ដល់ឲ្យ ...................................................... ២កូរិនថូស ៩:៧

ការជួយគាំពារគ្នាទៅវិញទៅមក ......................... ១កូរិនថូស ១២:២៥

ព្រះគម្ពីរមិនបានពន្យល់ប្រាប់ពីការដែលមនុស្សម្នាក់ៗអាចកំណត់យកអំណោយទានខាងឯវិញ្ញាណរបស់ពួកគេយ៉ាងជាក់លាក់ដោយរបៀបណានោះទេ ប៉ុន្តែលោកអ្នកអាចចាប់ផ្ដើមដោយការស្ដាប់បង្គាប់ជាមុនដំបូង ដូចដែលបានលើកឡើងនៅក្នុងតារាងខាងលើ។ ចូរស្វែងរកឱកាស ហើយអធិស្ឋានសូមឲ្យមានឱកាសក្នុងការបម្រើ។ ចូរស្វែងរកការប្រឹក្សាពីអ្នកជឿផ្សេងទៀត ពីព្រោះពួកគេអាចស្គាល់ច្បាស់ពីអំណោយទានរបស់លោកអ្នកជាងលោកអ្នកស្គាល់ទៅទៀត។

ការចាប់ផ្ដើមបម្រើក្រុមជំនុំរបស់លោកអ្នកដោយចុះចូលចំពោះចាស់ទុំ គឺជាជំហានមួយដែលអាចនាំឲ្យលោកអ្នករកឃើញអំណោយទានរបស់លោកអ្នកបាន។

តើលោកអ្នកចាប់អារម្មណ៍នឹងបម្រើក្រុមជំនុំរបស់លោកអ្នកត្រង់ផ្នែកណាខ្លះ?

១. ______________________________

២. ______________________________

៣. ______________________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

យើងម្នាក់ៗត្រូវហ្វឹកហ្វឺនអំណោយទានរបស់ខ្លួនមិនថាប្រុស ឬស្រីនៅក្នុងព័ន្ធកិច្ចទុកសម្រាប់ជាការល្អដល់ក្រុមជំនុំ។

---

*«គឺដោយខំបំរើគ្នាទៅវិញទៅមក តាមអំណោយទានដែលគ្រប់គ្នាបានទទួលមក ទុកដូចជាអ្នកចែកចាយយ៉ាងល្អ នៃព្រះគុណដ៏បែកជាច្រើនផ្លូវវិញ»* (១ពេត្រុស ៤:១០)។

---

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

មេរៀនទី១១

# ការផ្សាយដំណឹងល្អ និងអ្នកជឿ

**ខគម្ពីរចងចាំ ១ពេត្រុស ៣:១៥**
ចូរឲ្យតាំងព្រះគ្រីស្ទឡើង ជាបរិសុទ្ធ នៅក្នុងចិត្តអ្នករាល់គ្នា ទុកជាព្រះអម្ចាស់ចុះ ហើយឲ្យប្រុងប្រៀបជានិច្ច ដោយសុភាព ហើយកោតខ្លាច ដើម្បីនឹងតបឆ្លើយដល់អ្នកណាដែលសួរពីហេតុនៃសេចក្ដីសង្ឃឹមរបស់អ្នករាល់គ្នា។

ពាក្យថា **ការផ្សាយដំណឹងល្អ** នាំមកនូវការយល់ឃើញជាច្រើនចូលទៅក្នុងគំនិត។ មានមនុស្សមួយចំនួនបានគិតថា ជាការបោះតង់ ដែលមានអ្នកចែកចាយដ៏ល្បីល្បាញជាច្រើននៅក្នុងនោះ ហើយអ្នកខ្លះទៀតគិតដល់ពី «ការចុះសួរសុខទុក្ខ» រៀងរាល់សប្ដាហ៍ ហើយខ្លះទៀតគិតពីការភ័យខ្លាចក្នុងការ «ធ្វើបន្ទាល់»។ មេរៀននេះនឹងផ្ដល់ការណែនាំឲ្យស្គាល់នូវគោលគំនិតតាមបែបព្រះគម្ពីរក្នុងការផ្សាយដំណឹងល្អ និងតួនាទីដែលអ្នកជឿត្រូវធ្វើ។

## I. ការត្រាស់ហៅឲ្យផ្សាយដំណឹងល្អ

**ក) យោងតាមកណ្ឌគម្ពីរ ម៉ាកុស ១៦:១៥ តើព្រះយេស៊ូវបានប្រាប់ឲ្យពួកសិស្សធ្វើអី?**

______________________________

______________________________

**ខ) យោងតាមកណ្ឌគម្ពីរ ម៉ាថាយ ២៨:១៩-២០ តើរបៀបបីយ៉ាងក្នុងការបង្កើតសិស្សនោះមានអ្វីខ្លះ?**

______________________________

______________________________

**គ) តើសេចក្ដីប្រកាសដែលព្រះយេស៊ូវបានឲ្យពួកសិស្សប្រកាសដល់មនុស្សគ្រប់ជាតិសាសន៍នោះគឺជាអ្វី (លូកា ២៤:៤៦-៤៧)?**

______________________________

______________________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

ឃ) តើសេចក្តីដែលសាវ័ក ប៉ុល ឲ្យលោកអ្នកប្រាប់ដល់មនុស្សទាំងអស់នោះគឺជាអ្វី (កិច្ចការ ២២:១៥)?

______________________________

______________________________

## II. សារនៃដំណឹងល្អ

ក) យោងតាមកណ្ឌគម្ពីរ ១កូរិនថូស ១៥:៣-៤ តើដំណឹងល្អដែលសាវ័ក ប៉ុល ចែកចាយនោះគឺជាអ្វី?

១. ______________________________

២. ______________________________

៣. ______________________________

ខ) តើសាវ័ក ប៉ុល បានមានប្រសាសន៍ថា គាត់មិនត្រូវមានសេចក្តីខ្មាសអៀនចំពោះអ្វី (រ៉ូម ១:១៦)?

______________________________

ហេតុអ្វី? ______________________________

## III. អត្ថប្រយោជន៍នៃការផ្សាយដំណឹងល្អ

ក) ដើម្បីទទួលសេចក្តីសង្គ្រោះ តើមនុស្សត្រូវជឿអ្វីខ្លះអំពីព្រះយេស៊ូវ?

យ៉ូហាន ១:១ ______________________________

យ៉ូហាន ១៤:៦ ______________________________

កិច្ចការ ៤:១២ ______________________________

ខ) ខាងក្រោមនេះគឺជាខគម្ពីរគន្លឹះក្នុងការចែកចាយដំណឹងល្អ។ សូមពិនិត្យមើលខគម្ពីរនីមួយៗ រួចសង្ខេបចំណុចចម្បងឲ្យបានខ្លី។

រ៉ូម ៦:២៣ ______________________________

រ៉ូម ៥:៨ ______________________________

១ពេត្រុស ២:២៤ ______________________________

______________________________

រ៉ូម ១០:៩ ______________________________

______________________________

យ៉ូហាន ១:១២ ______________________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

**មនុស្សភាគច្រើនមិនយល់ពីសេចក្តីពិតទាំងនេះទេ៖**

| | |
|---|---|
| មនុស្សមិនអាចសង្គ្រោះខ្លួនឯងបាន | ម៉ាកុស ១០:២៦-២៧ |
| ព្រះគឺបរិសុទ្ធ សុចរិត ហើយស្អប់បាប | ទំនុកដំកើង ៥:៤-៥ |
| ព្រះយេស៊ូវគ្រីស្ទគឺជាព្រះ | កូល៉ុស ២:៩ |
| ការសុគតរបស់ព្រះគ្រីស្ទនៅលើឈើឆ្កាងដោយព្រោះបាបយើង | ១ពេត្រុស ៣:១៨ |
| ការទៅស្ថានសួគ៌ គឺជាអំណោយឥតគិតថ្លៃរបស់ព្រះជាម្ចាស់ | រ៉ូម ៦:២៣ |

## IV. យុទ្ធសាស្ត្រសម្រាប់ផ្សាយដំណឹងល្អ

### ក) ធ្វើបន្ទាល់តាមរយៈជីវិត

១. តើយើងគួររស់នៅបែបណា ហើយគួរឲ្យលោកីយ៍មើលឃើញពីជីវិតនៃការរស់នៅរបស់យើងមានលក្ខណៈបែបណា (ភីលីព ២:១៤-១៥)?

________________________________

________________________________

________________________________

________________________________

អ្នកឯទៀតនឹងឃើញព្រះអង្គសង្គ្រោះរបស់លោកអ្នកតាមរយៈជីវិតរបស់លោកអ្នក ដែលទ្រង់បានប្រោសលោះនោះ។

២. សូមអានកណ្ឌគម្ពីរ ម៉ាថាយ ៥:១៦។

ក) តើមនុស្សឃើញពន្លឺនៃជីវិតរបស់គ្រីស្ទបរិស័ទត្រង់ចំណុចណា?

________________________________

ខ) តើនឹងបានលទ្ធផលអ្វី?

________________________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

**គ) យោងតាមកណ្ឌគម្ពីរ កូល៉ុស ៤:៦ តើលោកអ្នកគួរមានពាក្យសម្ដីបែបណាទៅកាន់អ្នកដទៃ?**

**ខ) ការអធិស្ឋាន**

១. នៅពេលដែលសាវ័ក ប៉ុល អធិស្ឋានសម្រាប់អ្នកដទៃ តើគាត់មានអ្វីនៅក្នុងចិត្ត (រ៉ូម ១០:១)?

២. តើសាវ័ក ប៉ុល សំណូមពរឲ្យក្រុមជំនុំកូល៉ុសអធិស្ឋានអំពីអ្វីខ្លះ (កូល៉ុស ៤:៣-៤)?

៣. នៅពេលដែលយើងចែកចាយព្រះបន្ទូលរបស់ព្រះជាម្ចាស់ចំពោះអ្នកផ្សេងៗ ជាពិសេសក្នុងកាលៈទេសៈដែលគេគំរាមកំហែងយើង តើយើងគួរសូមព្រះជាម្ចាស់ឲ្យប្រទានអ្វីដល់យើង (កិច្ចការ ៤:២៩)?

---

*«ដូច្នេះ ខ្ញុំទូន្មានសេចក្ដីនេះជាមុនដំបូងថា ចូរពោលពាក្យអរព្រះគុណ ពាក្យទូលសូម ពាក្យអធិស្ឋាន និងពាក្យទូលអង្វរឲ្យមនុស្សទាំងអស់...ដ្បិតយ៉ាងនោះ ទើបបានល្អ ហើយគាប់ព្រះហឫទ័យ ដល់ព្រះដ៏ជាព្រះអង្គសង្គ្រោះនៃយើង ដែលទ្រង់សព្វព្រះហឫទ័យ ឲ្យមនុស្សទាំងអស់បានសង្គ្រោះ ហើយឲ្យបានស្គាល់សេចក្ដីពិត»* (១ធីម៉ូថេ ២:១, ៣-៤)។

---

**គ) ការប្រើព្រះបន្ទូលរបស់ព្រះជាម្ចាស់**

១. តើព្រះបន្ទូលរបស់ព្រះជាម្ចាស់នឹងធ្វើអ្វី (ហេព្រើរ ៤:១២)?

២. តើសាវ័ក ប៉ុល បានប្រើបទគម្ពីរក្នុងការធ្វើបន្ទាល់យ៉ាងដូចម្ដេច (កិច្ចការ ១៧:២-៣)?

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

៣. តើបទគម្ពីរអាចនាំឲ្យមានអ្វីកើតឡើងខ្លះ (២ធីម៉ូថេ ៣:១៥)?

_______________________________________________

_______________________________________________

_______________________________________________

---

យើងត្រូវប្រុងប្រៀបជានិច្ចក្នុងការចែកចាយពីព្រះគ្រីស្ទក្នុងគ្រប់
កាលៈទេសៈទាំងអស់។ យើងត្រូវតែដឹងពីសារៈសំខាន់នៃដំណឹងល្អ។
យើងត្រូវមានទំនុកចិត្តលើព្រះជាម្ចាស់ និងព្រះបន្ទូលរបស់ទ្រង់។
*«ចូរឲ្យតាំងព្រះគ្រីស្ទឡើង ជាបរិសុទ្ធ នៅក្នុងចិត្តអ្នករាល់គ្នា ទុកជាព្រះអម្ចាស់ចុះ
ហើយឲ្យប្រុងប្រៀបជានិច្ច ដោយសុភាព ហើយកោតខ្លាច ដើម្បីនឹងតបឆ្លើយដល់
អ្នកណាដែលសួរពីហេតុនៃសេចក្តីសង្ឃឹមរបស់អ្នករាល់គ្នា»* (១ពេត្រុស ៣:១៥)។
**បន្ទាប់មកសូមអធិស្ឋាន ហើយស្វែងរកឱកាសក្នុងការចែកចាយដំណឹងល្អ!**

---

## V. ការអនុវត្ត

សូមសរសេរឈ្មោះមនុស្សមួយចំនួនដែលលោកអ្នកចង់ឈោងចាប់ថ្វាយព្រះគ្រីស្ទ។ សូមអធិស្ឋានឲ្យបានទៀងទាត់សម្រាប់ពួកគេ បន្ទាប់មករៀបចំឆក់យកឱកាសក្នុងការចែកចាយព្រះបន្ទូលរបស់ព្រះជាម្ចាស់ចំពោះពួកគេ។ សូមអនុញ្ញាតឲ្យព្រះជាម្ចាស់បង្ហាញឲ្យគេឃើញថា គេត្រូវការព្រះយេស៊ូវគ្រីស្ទ ហើយលោកអ្នកត្រូវទុកចិត្តលើទ្រង់ថាទ្រង់កំពុងតែធ្វើការ។

១. _______________________________________________

២. _______________________________________________

៣. _______________________________________________

៤. _______________________________________________

៥. _______________________________________________

---

**សូមចងចាំថា លោកអ្នកត្រូវតែបង្ហាញពីភាពដូចព្រះគ្រីស្ទ
នៅក្នុងជីវិតរបស់លោកអ្នក។**
ប្រសិនបើលោកអ្នកធ្វើបន្ទាល់ទៅកាន់មនុស្សទាំងឡាយតាមរយៈការរស់នៅ នោះគេ
នឹងយល់ពីអ្វីៗដែលលោកអ្នកបានចែកចាយកាន់តែច្បាស់ថែមទៀត!

---

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

មេរៀនទី១២

# ការស្តាប់បង្គាប់

**ខគម្ពីរចងចាំ៖ ១យ៉ូហាន ២:៣-៤**
យើងរាល់គ្នាដឹងថា យើងស្គាល់ទ្រង់ ដោយសារសេចក្តីនេះ គឺដោយយើងកាន់តាមបញ្ញត្តរបស់ទ្រង់អ្នកណាដែលថា បានស្គាល់ទ្រង់ តែមិនកាន់តាមបញ្ញត្តទ្រង់ទេ អ្នកនោះឈ្មោះថាជាអ្នកកុហក ហើយសេចក្តីពិតមិននៅក្នុងអ្នកនោះឡើយ។

ការឆ្លើយតបដ៏គួរសមរបស់គ្រីស្ទបរិស័ទចំពោះព្រះជាម្ចាស់ នោះគឺជាការស្តាប់បង្គាប់។ ប៉ុន្តែការស្តាប់បង្គាប់ គឺលើសជាងការធ្វើតាមច្បាប់ទៅទៀត។ នៅក្នុងមេរៀននេះ យើងនឹងសិក្សាលើអត្ថន័យនៃការស្តាប់បង្គាប់ ផ្នែកខ្លះៗនៃការស្តាប់បង្គាប់ និងលទ្ធផលខ្លះៗនៃការស្តាប់បង្គាប់។

## I. ការត្រាស់ហៅឲ្យស្តាប់បង្គាប់

*"ឲ្យដូចជាពួកកូនដែលស្តាប់បង្គាប់...តែចូរឲ្យអ្នករាល់គ្នាបានបរិសុទ្ធក្នុងគ្រប់កិរិយាទាំងអស់ដូចជាព្រះដែលហៅអ្នករាល់គ្នាទ្រង់បរិសុទ្ធដែរ"* (១ពេត្រុស ១:១៤-១៥)។

### ក) ការត្រាស់ហៅឲ្យធ្វើតាមបញ្ញត្តិរបស់ព្រះជាម្ចាស់

១. យោងតាមកណ្ឌគម្ពីរ យ៉ូហាន ១៤:១៥ ព្រះយេស៊ូវបានមានបន្ទូលថា "បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ អ្នកនឹង ____________________

២. តើអស់អ្នកដែលបានឮព្រះបន្ទូលរបស់ទ្រង់គួរនឹងធ្វើអ្វី (យ៉ាកុប ១:២២)?

____________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

### ខ) ការត្រាស់ហៅឲ្យដើរតាមព្រះគ្រីស្ទ

១. តើព្រះយេស៊ូវបានតម្រូវឲ្យអ្នកដើរតាមទ្រង់ធ្វើអ្វីខ្លះ (លូកា ៩:២៣)?

ក) ______________________________

ខ) ______________________________

គ) ______________________________

២. តើព្រះយេស៊ូវបានទុកគំរូដល់យើងយ៉ាងដូចម្ដេច នៅពេលដែលទ្រង់រងទុក្ខដោយសារការស្ដាប់បង្គាប់ព្រះជាម្ចាស់ (១ពេត្រុស ២:២០-២៣)?

______________________________

______________________________

### គ) ការត្រាស់ហៅឲ្យចុះចូល

---

*«តើអ្នករាល់គ្នាដឹងទេឬអី ថាអ្នករាល់គ្នាប្រគល់ខ្លួនទៅធ្វើជាបាវបំរើ និងស្ដាប់តាមចៅហ្វាយណា នោះអ្នកជាបាវបំរើរបស់ចៅហ្វាយនោះឯងដែលអ្នកស្ដាប់តាម ទោះជារបស់ផងអំពើបាប ឲ្យបានសេចក្ដីស្លាប់ ឬជារបស់ផងសេចក្ដីស្ដាប់បង្គាប់ឲ្យបានសុចរិតក្ដី» (រ៉ូម ៦:១៦)។*

---

តើយើងគួរថ្វាយខ្លួនរបស់យើងដល់ព្រះជាម្ចាស់យ៉ាងដូចម្ដេច (រ៉ូម ១២:១)?

______________________________

______________________________

## II. ការស្ដាប់បង្គាប់សម្គាល់ពីអ្នកជឿដ៏ពិតប្រាកដ

### ក) សូមអានកណ្ឌគម្ពីរ ១យ៉ូហាន ២:៣-៤ (ខគម្ពីរចងចាំ)។

១. តើនៅពេលដែលលោកអ្នកស្ដាប់បង្គាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ នោះសម្ដែងពីអ្វី?

______________________________

______________________________

២. បើលោកអ្នកបន្តមិនស្ដាប់បង្គាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ នោះបង្ហាញប្រាប់ពីអ្វី?

______________________________

______________________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

**ខ) តើមនុស្សដែលនឹងចូលទៅក្នុងស្ថានសួគ៌មានចរិតលក្ខណៈបែបណា (ម៉ាថាយ ៧:២១)?**

______________________________________________

*«តែអ្នកណាដែលកាន់តាមព្រះបន្ទូលទ្រង់វិញ នោះប្រាកដជាសេចក្ដីស្រឡាញ់នៃព្រះបានពេញខ្នាត នៅក្នុងអ្នកនោះហើយ គឺដោយសេចក្ដីនោះឯង ដែលយើងដឹងថា យើងនៅក្នុងទ្រង់»* (១យ៉ូហាន ២:៥)។

## III. ឧទាហរណ៍ខ្លះៗនៃការមិនស្ដាប់បង្គាប់

**ក) សូមអាន ១សាំយ៉ូអែល ១៥:១៦-២៣។ ផ្ទុយពីការធ្វើតាមបញ្ញត្តិរបស់ព្រះជាម្ចាស់ទាំងស្រុង ស្ដេច សូល បានយកវិធីថ្វាយបង្គំផ្ទាល់ខ្លួនរបស់ទ្រង់មកដាក់ជំនួសវិញ ហើយបានដោះសា ចំពោះការមិនព្រមស្ដាប់បង្គាប់របស់ខ្លួន។**

១. តើហោរា សាំយ៉ូអែល បានឆ្លើយតបទៅស្ដេច សូល យ៉ាងដូចម្ដេច? តើគាត់បានប្រៀបធៀបការស្ដាប់បង្គាប់ទៅនឹងយញ្ញបូជាយ៉ាងដូចម្ដេច (ខ២២)? ______________________

______________________________________________

២. តើហោរា សាំយ៉ូអែល បានប្រៀបធៀប «សេចក្ដីរឹងទទឹង និងសេចក្ដីចចេស» ទៅនឹងអ្វី (ខ២៣)?

______________________________________________

៣. តើការមិនស្ដាប់បង្គាប់របស់ស្ដេច សូល បានបណ្ដាលឲ្យទ្រង់បាត់បង់អ្វីខ្លះ (ខ២៣)?

______________________________________________

**ខ) សូមមើលកណ្ឌគម្ពីរ សាការី ៧:៨-១៤។**

១. តើមនុស្សបានមានប្រតិកម្មយ៉ាងណា ចំពោះសេចក្ដីបង្គាត់បង្រៀនរបស់ព្រះជាម្ចាស់ (ខ១១-១២)?

______________________________________________

២. តើការនោះបានប៉ះពាល់ដល់សេចក្ដីអធិស្ឋានរបស់ពួកគេដូចម្ដេចខ្លះ (ខ១៣)?

______________________________________________

៣. តើអ្វីជាលទ្ធផល (ខ១៤)?

______________________________________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

## IV. ឧទាហរណ៍ខ្លះៗនៃការស្តាប់បង្គាប់

នៅក្នុងព្រះគម្ពីរសញ្ញាចាស់មានឧទាហរណ៍ជាច្រើនអំពីការស្តាប់បង្គាប់។ ចូរកត់សម្គាល់ពីវីរជននៃជំនឿ និងការស្តាប់បង្គាប់នៅព្រះគម្ពីរសញ្ញាចាស់ ដែលបានកត់ត្រានៅក្នុងកណ្ឌគម្ពីរ ហេព្រើរ ១១។

**ក) ការស្តាប់បង្គាប់របស់លោក អ័ប្រាហាំ**

១. តើការស្តាប់បង្គាប់ពីរយ៉ាងដ៏សំខាន់របស់លោក អ័ប្រាហាំមានអ្វីខ្លះ?

ក) លោកុប្បត្តិ ១២:១-៤, ហេព្រើរ ១១:៨ ____________________

____________________

ខ) លោកុប្បត្តិ ២២:១-១២ ____________________

____________________

២. ដោយសារតែលោក អ័ប្រាហាំ បានស្តាប់បង្គាប់ព្រះជាម្ចាស់ តើសេចក្តីបីយ៉ាងដែលព្រះជាម្ចាស់បានសន្យាចំពោះកូនប្រុសរបស់គាត់ មានអ្វីខ្លះ (លោកុប្បត្តិ ២៦:២-៥)?

ក) ____________________

ខ) ____________________

គ) ____________________

**ខ) គំរូរបស់ព្រះគ្រីស្ទក្នុងការស្តាប់បង្គាប់**

១. តើព្រះហឫទ័យចម្បងរបស់ព្រះយេស៊ូវ នៅពេលដែលទ្រង់គង់នៅលើផែនដីនេះគឺជាអ្វី (យ៉ូហាន ៤:៣៤)?

____________________

២. មុនពេលដែលព្រះគ្រីស្ទត្រូវជាប់ឆ្កាង តើទ្រង់មានអាកប្បកិរិយាយ៉ាងដូចម្តេច (លូកា ២២:៤២)?

____________________

៣. តើព្រះយេស៊ូវមានព្រះទ័យស្តាប់បង្គាប់ដល់កម្រិតណា (ភីលីព ២:៨)?

____________________

## V. សេចក្តីសន្យា និងព្រះពរនៃការស្តាប់បង្គាប់

**ក) ចូរសរសេរពីព្រះពរខ្លះៗដែលព្រះជាម្ចាស់បានសន្យាដល់យើង ពេលយើងរាល់គ្នាស្តាប់តាមបញ្ញត្តិរបស់ទ្រង់ ។**

១. យ៉ូហាន ១៥:១០ ____________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

២. យ៉ូហាន ១៥:១៤ ____________________

៣. ១យ៉ូហាន ៣:២២ ____________________

**ខ) តើព្រះយេស៊ូវប្រៀបធៀបជីវិតរបស់អ្នកដែលឮហើយធ្វើតាមព្រះបន្ទូលទ្រង់ទៅនឹងអ្វី (ម៉ាថាយ ៧:២៤-២៧)?**

____________________

## VI. ផ្នែកនៃការស្តាប់បង្គាប់

**ក) តើព្រះគ្រីស្ទបានបង្គាប់សិស្សរបស់ទ្រង់ឲ្យបង្រៀនគ្រីស្ទបរិស័ទផ្សេងៗឲ្យធ្វើអ្វីជាមួយនឹងបញ្ញត្តិរបស់ទ្រង់ (ម៉ាថាយ ២៨:២០)?**

____________________

____________________

**ខ) ចូរអានខគម្ពីរនីមួយៗខាងក្រោមនេះ បន្ទាប់មកបំពេញឈ្មោះអ្នកដែលស្តាប់បង្គាប់ និងឈ្មោះអ្នកដែលគេត្រូវស្តាប់បង្គាប់ ទាំងបញ្ជាក់ពីមូលហេតុផងដែរ។**

១. កូល៉ុស ៣:២០

ក) តើអ្នកណា? ____________________

ដល់អ្នកណា? ____________________

ខ) ហេតុអ្វី? ____________________

២. អេភេសូរ ៥:២២-២៤

ក) តើអ្នកណា? ____________________

ដល់អ្នកណា? ____________________

ខ) ហេតុអ្វី? ____________________

____________________ *(ខគម្ពីរជំនួយៈ អេភេសូរ ៥:២៥-៣២)*

៣. អេភេសូរ ៦:៥-៨

ក) តើអ្នកណា? ____________________

ដល់អ្នកណា? ____________________

ខ) ហេតុអ្វី? ____________________

៤. ហេព្រើរ ១៣:១៧

ក) តើអ្នកណា? ____________________

ដល់អ្នកណា? ____________________

ខ) ហេតុអ្វី? ____________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

៥. រ៉ូម ១៣:១

ក) តើអ្នកណា? ____________________

ដល់អ្នកណា? ____________________

ខ) ហេតុអ្វី? ____________________

**គ) តើប្រពន្ធគួរតែធ្វើយ៉ាងម៉េច បើប្ដីរបស់នាងមិនមែនជាអ្នកជឿ (១ពេត្រុស ៣:១)?**

____________________

____________________

**ឃ) តើមានអ្វីកើតឡើង បើអ្នកបម្រើ (បុគ្គលិក) ម្នាក់មានចៅហ្វាយដែលមិនអាចទ្រាំទ្របាននោះ តើគេគួរតែធ្វើអ្វី (១ពេត្រុស ២:១៨-១៩)?**

____________________

____________________

## VII. អាកប្បកិរិយារបស់យើងក្នុងការស្ដាប់បង្គាប់

យើងត្រូវតែចងចាំថា រាល់អំពើល្អរបស់យើងដាច់ដោយឡែកពីជំនឿគឺដូចជាអាវកខ្វក់មួយ (អេសាយ ៤:៦)។ ការស្ដាប់បង្គាប់ដោយគ្មានជំនឿដ៏ពិតប្រាកដ នោះគ្មានប្រយោជន៍អ្វីទាំងអស់។ ការស្ដាប់បង្គាប់របស់យើងត្រូវតែចេញមកពីចិត្តដែលមានជំនឿដ៏ស្មោះត្រង់ចំពោះព្រះជាម្ចាស់ ។

**ក) តើអ្វីទៅជាមូលដ្ឋានគ្រឹះនៃការស្ដាប់បង្គាប់ទាំងស្រុងរបស់លោក អ័ប្រាហាំ (ហេព្រើរ ១១:៨)?**

____________________

**ខ) សូមអានពីប្រស្នាអំពីកូនប្រុស២នាក់ក្នុងកណ្ឌគម្ពីរ ម៉ាថាយ ២១:២៨-៣២។ តើកូនមួយណាមានអាកប្បកិរិយាល្អជាង? ហេតុអ្វី?**

____________________

**គ) តើយើងគួរឆ្លើយតបយ៉ាងដូចម្ដេច នៅពេលដែលព្រះបន្ទូលព្រះជាម្ចាស់ ហាក់បីដូចជាផ្ទុយពីការយល់ឃើញរបស់យើង ដោយយកសាវ័ក ពេត្រុស ជាឧទាហរណ៍ (លូកា ៥:៤-៧)?**

____________________

**ឃ) សូមអានកណ្ឌគម្ពីរ អេភេសូរ ៦:៦។**

១. យោងតាមគំរូរបស់ព្រះយេស៊ូវ តើយើងគួរបម្រើយ៉ាងដូចម្ដេច?

____________________

២. តើយើងគួរមានអាកប្បកិរិយាបែបណា នៅក្នុងការធ្វើតាមបំណងព្រះហឫទ័យព្រះជាម្ចាស់គ្រប់ជំពូក?

____________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

*«ឯអ្នករាល់គ្នា ក៏ដូច្នោះដែរ កាលណាអ្នករាល់គ្នាបានធ្វើតាមបង្គាប់គ្រប់ជំពូកហើយ នោះត្រូវរាប់ថា យើងជាបាវបំរើឥតកំរៃដល់ម្ចាស់ទេ ដ្បិតយើងបានធ្វើត្រឹមតែការដែលយើងត្រូវធ្វើប៉ុណ្ណោះ»* (លូកា ១៧:១០)។

## VIII. ការអនុវត្ត

ក) តើឃ្លា «...ថ្វាយរូបកាយទុកជាយញ្ញបូជារស់ ហើយបរិសុទ្ធ ដែលគាប់ព្រះហឫទ័យដល់ព្រះ...» មានន័យយ៉ាងដូចម្ដេចចំពោះលោកអ្នក (រ៉ូម ១២:១)?

___

___

___

ខ) តើលោកអ្នកបានរៀនអ្វីខ្លះចេញពីផលវិបាកនៃការមិនស្ដាប់បង្គាប់?

___

___

___

គ) តើព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យលោកអ្នកស្ដាប់បង្គាប់ទ្រង់ជាងមុននៅត្រង់ផ្នែកណាខ្លះនៃជីវិត?

___

___

___

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

មេរៀនទី១៣

# ព្រះហឫទ័យ និងការដឹកនាំរបស់ព្រះជាម្ចាស់

**ខគម្ពីរចងចាំ អេភេសូរ ៥:១៧**
ដូច្នេះ កុំឲ្យខ្លៅល្ងង់ឡើយ ត្រូវខំឲ្យយល់បំណងព្រះហឫទ័យរបស់ព្រះអម្ចាស់វិញ។

ព្រះជាម្ចាស់មានអធិតេយ្យភាព ហើយទ្រង់មានគោលបំណងសម្រាប់គ្រប់ទាំងរបស់ដែលទ្រង់បានបង្កើតមក។ ទ្រង់មានផែនការ ឬ «បំណងព្រះហឫទ័យ» សម្រាប់យើងម្នាក់ៗ ប៉ុន្តែយើងតែងតែគិតថា ការស្វែងរកព្រះហឫទ័យរបស់ទ្រង់ពិបាកខ្លាំងណាស់ ទោះបីជាព្រះហឫទ័យរបស់ទ្រង់ងាយស្រួលស្វែងរកក៏ដោយ។ នៅក្នុងមេរៀននេះ យើងនឹងស្វែងរកព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងរបៀបដែលទ្រង់ដឹកនាំយើង។

## I. ព្រះហឫទ័យរបស់ព្រះជាម្ចាស់

ព្រះហឫទ័យពីរយ៉ាងរបស់ព្រះជាម្ចាស់នៅក្នុងព្រះគម្ពីរគឺ៖ ទី១ ព្រះហឫទ័យដែលមានអធិបតេយ្យភាព និងទី២ ព្រះហឫទ័យដែលបង្គាប់បញ្ជា។ នៅក្នុងអធិបតេយ្យភាពរបស់ព្រះជាម្ចាស់ ទ្រង់មានផែនការលើអ្វីៗដែលទ្រង់បានបង្កើតមក និងលើពេលវេលាផងដែរ។ ទ្រង់ក៏មានព្រះហឫទ័យដែលបង្គាប់បញ្ជាដែរ ហើយព្រះហឫទ័យនេះបង្គាប់បញ្ជារាស្ត្ររបស់ទ្រង់។

### ក) អត្ថន័យនៃព្រះហឫទ័យរបស់ព្រះជាម្ចាស់

១. ព្រះហឫទ័យដែលមានអធិបតេយ្យភាព

ព្រះហឫទ័យដែលមានអធិបតេយ្យភាពរបស់ព្រះជាម្ចាស់ទាក់ទងទៅនឹងការត្រួតត្រាយ៉ាងពេញលេញទៅលើគ្រប់អ្វីៗទាំងអស់។ គ្មានអ្វីកើតឡើងដែលគ្មាននៅក្នុងផែនការរបស់ទ្រង់នោះឡើយ។ ប្រវត្តិសាស្ត្រគឺជាការលាតត្រដាងដ៏ច្បាស់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដែលបានកើតឡើងដូចដែលទ្រង់បានគ្រោងទុក។ ចូរអានខគម្ពីរខាងក្រោមនេះ បន្ទាប់មកសរសេរគំនិតគន្លឹះស្ដីពីព្រះហឫទ័យដែលមានអធិបតេយ្យភាពរបស់ព្រះជាម្ចាស់៖

ក) អេសាយ ១៤:២៤ ____________________

____________________

____________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

ខ) អេភេសូរ ១:១១ ____________________________________________

______________________________________________________

______________________________________________________

---

*«...ដ្បិតអញនេះហើយជាព្រះ ឥតមានណាទៀតឡើយ អញជាព្រះ ហើយគ្មានអ្នកណាដូចអញសោះ...ដោយពាក្យថាគំនិតសំរេចរបស់អញនឹងស្ថិតស្ថេរនៅ អញនឹងធ្វើតាមបំណងចិត្តអញគ្រប់ប្រការ»* (អេសាយ ៤៦:៩-១០)។

---

២. ព្រះហឫទ័យបង្គាប់បញ្ជារបស់ព្រះជាម្ចាស់

ព្រះគម្ពីរបានសម្ដែងពីព្រះហឫទ័យបង្គាប់បញ្ជារបស់ព្រះជាម្ចាស់ថាជាច្បាប់ ឬជាគោលការណ៍ផ្សេងៗ។ នេះហើយគឺជាទិដ្ឋភាពនៃព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែលទ្រង់នឹងកាត់ទោសមនុស្សទាំងអស់។

ក) យោងតាមមហាបេសកកម្មនៅក្នុងកណ្ឌគម្ពីរ ម៉ាថាយ ២៨:២០ តើសិស្សរបស់ព្រះយេស៊ូវត្រូវបង្រៀនអ្នកទើបជឿថ្មីៗពីអ្វីខ្លះ? ______________________

______________________________________________________

______________________________________________________

ខ) ព្រះជាម្ចាស់បានប្រទានបញ្ញត្តិដ៏សំខាន់ពីរមកយើងរាល់គ្នា។ ចូរសរសេរបញ្ញត្តិទាំងនោះខាងក្រោមនេះ៖

ម៉ាថាយ ២២:៣៧ ________________________________________

ម៉ាថាយ ២២:៣៩ ________________________________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

**ខ) លក្ខណៈនៃព្រះហឫទ័យរបស់ព្រះជាម្ចាស់**

ប្រសិនបើយើងយល់ពីព្រះហឫទ័យដែលមានអធិបតេយ្យភាព នោះយើងនឹងយល់ពីព្រះហឫទ័យបង្គាប់បញ្ជារបស់ព្រះជាម្ចាស់យ៉ាងច្បាស់ជាមិនខាន។

| ព្រះហឫទ័យដែលមានអធិបតេយ្យភាព | ព្រះហឫទ័យបង្គាប់បញ្ជា |
|---|---|
| ១. អាថ៌កំបាំងៈ មានតែព្រះជាម្ចាស់ទេទើបដឹង លើកលែងតែនៅពេលដែលបង្ហាញឲ្យឃើញតាមរយៈប្រវត្តិសាស្ត្រ ឬការបើកសម្តែង | ១. បានសម្តែងឲ្យឃើញនៅក្នុងព្រះគម្ពីរ |
| ២. មិនអាចមានអ្នកណាជំទាស់ ឬធ្វើឲ្យខកខានបានឡើយ | ២. អាចមានអ្នកជំទាស់ ឬមិនស្តាប់បង្គាប់ |
| ៣. ហ៊ុមព័ទ្ធទាំងការល្អ និងការអាក្រក់ (បាប) | ៣. ទាក់ទងទៅនឹងអ្វីដែលល្អ ហើយបរិសុទ្ធតែប៉ុណ្ណោះ |
| ៤. ទូលំទូលាយៈ ត្រួតត្រាគ្រប់ទិដ្ឋភាពនៃជីវិត ពេលវេលា និងប្រវត្តិសាស្ត្រ | ៤. ជាក់លាក់ៈ ប្រទានគោលការណ៍សម្រាប់ការរស់នៅ |
| ៥. ព្រះជាម្ចាស់មិនបានបង្គាប់ឲ្យអ្នកជឿត្រូវដឹង ឬក៏ស្វែងយល់អ្វីៗដែលទ្រង់មិនបានសម្តែងឲ្យឃើញនោះទេ | ៥. ព្រះជាម្ចាស់បានទូន្មានអ្នកជឿឲ្យស្គាល់ យល់ ហើយស្តាប់បង្គាប់រាល់អ្វីៗដែលទ្រង់បានសម្តែង។ |

សូមសិក្សាលើតារាងខាងលើ។ ចូរសាកល្បងចំណេះដឹងរបស់លោកអ្នកស្តីពីព្រះហឫទ័យដែលមានអធិបតេយ្យភាព និងព្រះហឫទ័យបង្គាប់បញ្ជារបស់ព្រះជាម្ចាស់។

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

ចូរសរសេរផ្នែកខ្លះនៃខគម្ពីរដែលបង្ហាញឲ្យឃើញពីព្រះហឫទ័យរបស់ព្រះជាម្ចាស់។
សូមគូសសញ្ញាគ្រីស (✓) នៅក្នុងប្រអប់ដែលលោកអ្នកយល់ឃើញថាត្រឹមត្រូវ៖

| | ព្រះហឫទ័យដែលមានអធិបតេយ្យភាព | ព្រះហឫទ័យបង្គាប់បញ្ជា |
|---|---|---|
| ១. ភីលីព ២:១៣ | ☐ | ☐ |
| ២. ១ថែស្សាឡូនីច ៤:៣ | ☐ | ☐ |
| ៣. ២កូរិនថូស ៦:១៤ | ☐ | ☐ |
| ៤. ម៉ាថាយ ៧:២១ | ☐ | ☐ |
| ៥. ភីលីព ១:៦ | ☐ | ☐ |
| ៦. យេរេមា ២៩:១១ | ☐ | ☐ |

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

**គ) ការឆ្លើយតបទៅនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់**

១. តើយើងគួរឆ្លើយតបទៅនឹងព្រះហឫទ័យដែលមានអធិបតេយ្យភាពរបស់ព្រះជាម្ចាស់យ៉ាងដូចម្ដេច?

ក) សុភាសិត ៣:៥-៦ ______________________________

______________________________

ខ) ១ពេត្រុស ៤:១៩ ______________________________

______________________________

គ) យ៉ាកុប ៤:១៣-១៥ ______________________________

______________________________

២. តើយើងគួរឆ្លើយតបទៅនឹងព្រះហឫទ័យបង្គាប់បញ្ជារបស់ព្រះជាម្ចាស់យ៉ាងដូចម្ដេច?

ក) អេភេសូរ ៥:១៧ ______________________________

______________________________

ខ) ចោទិយកថា ២៩:២៩ ______________________________

______________________________

គ) ចោទិយកថា ១១:១ ______________________________

______________________________

---

**ព្រះជាម្ចាស់បង្រៀន ហើយយើងស្ដាប់បង្គាប់**

*“ព្រះយេហូវ៉ាទ្រង់ល្អ ហើយទៀងត្រង់ ដូច្នេះទ្រង់នឹងបង្ហាត់មនុស្សមានបាបឲ្យតាមផ្លូវទ្រង់វិញ ទ្រង់នឹងនាំមនុស្សសុភាពក្នុងសេចក្ដីយុត្តិធម៌ ហើយនឹងបង្រៀនមនុស្សរាបទាប ឲ្យស្គាល់ផ្លូវទ្រង់ អស់ទាំងផ្លូវនៃព្រះយេហូវ៉ា សុទ្ធតែប្រកបដោយសេចក្ដីសប្បុរស និងសេចក្ដីពិត ចំពោះអស់អ្នកណាដែលកាន់តាមសេចក្ដីសញ្ញា និងសេចក្ដីបន្ទាល់របស់ទ្រង់”* (ទំនុកដំកើង ២៥:៨-១០)។

---

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

## II. ការដឹកនាំ

ដោយសារតែសេចក្តីស្រឡាញ់ដ៏វិសេសវិសាលរបស់ព្រះជាម្ចាស់ ទ្រង់បាន តម្រូវទុក ត្រាស់ហៅ រាប់ទុកជាសុចរិត ព្រមទាំងនឹងលើកតម្កើងអ្នកជឿទាំងអស់។ ព្រះអង្គក៏ដឹកនាំយើងផងដែរ ។

### ក) អត្ថន័យនៃការដឹកនាំ

ការដឹកនាំ គឺជាតួនាទីដ៏សកម្មរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់យើង និងជាការធ្វើឲ្យសម្រេចតាមបំណងព្រះហឫទ័យរបស់ទ្រង់ ។

ចូរកត់សម្គាល់លើពាក្យដែលមាននៅក្នុងព្រះគម្ពីរ ដើម្បីយកមកពណ៌នាពីការដឹកនាំដូចខាងក្រោម។ បន្ទាប់មកសរសេរពីរបៀបដែលខគម្ពីរពន្យល់អត្ថន័យនៃពាក្យនីមួយៗនោះ៖

១. កៀងនាំ (ឃ្វាល សែង ឬ លី)

ក) ទំនុកដំកើង ៧៨:៥២ ____________________________________________

____________________________________________

ខ) ទំនុកដំកើង ១៣៩:២៤ ____________________________________________

____________________________________________

២. ដឹកនាំ (បង្ហាញ ជួយឲ្យយល់)

ក) ទំនុកដំកើង ២៣:៣ ____________________________________________

____________________________________________

ខ) ទំនុកដំកើង ៧៣:២៤ ____________________________________________

____________________________________________

៣. តម្រង់ផ្លូវ (តាំង ឬរៀបចំ ធ្វើឲ្យត្រង់)

ក) សុភាសិត ១៦:៩ ____________________________________________

____________________________________________

ខ) ២ថែស្សាឡូនីច ៣:៥ ____________________________________________

____________________________________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

**ខ) លក្ខណៈនៃការដឹកនាំ**

តារាងខាងក្រោមនេះស្តីពីរបៀបដែលព្រះជាម្ចាស់ដឹកនាំមនុស្សដោយផ្ទាល់ និងដោយប្រយោល។

| ការដឹកនាំដោយផ្ទាល់ | ការដឹកនាំដោយប្រយោល |
|---|---|
| ១. ការបើកសម្តែង ដែលមានបន្ទូលចេញមកពីព្រះជាម្ចាស់ផ្ទាល់ | ១. ព្រះបន្ទូលរបស់ព្រះជាម្ចាស់ |
| ២. ការជាក់ស្តែង | ២. បញ្ញាចិត្ត ឬការបណ្តាលឲ្យដឹង |
| ៣. សុបិន្ត | ៣. ទិព្វវិញ្ញាណ (កាលៈទេសៈ ដែលត្រួតត្រាដោយព្រះជាម្ចាស់) |
| ៤. ហោរា/សាវ័ក ដែលនិយាយជំនួសព្រះជាម្ចាស់ | ៤. ប្រាជ្ញា និងយោបល់ |

ព្រះជាម្ចាស់បានដឹកនាំដោយផ្ទាល់នៅក្នុងសម័យសញ្ញាចាស់ និងនៅដើមនៃការចាប់ផ្តើមសញ្ញាថ្មី។ សព្វថ្ងៃនេះយើងឃើញថា ព្រះជាម្ចាស់ដឹកនាំដោយប្រយោល។ ព្រះវិញ្ញាណបរិសុទ្ធដើរតួនាទីនៅក្នុងគ្រប់ទាំងផ្នែកនៃការដឹកនាំដោយប្រយោលដែលជាព័ន្ធកិច្ចរបស់ទ្រង់ចំពោះអ្នកជឿ។

១. ការដឹកនាំតាមរយៈព្រះបន្ទូលរបស់ព្រះជាម្ចាស់

តើអ្នកនិពន្ធកណ្ឌគម្ពីរទំនុកដំកើងពណ៌នាពីព្រះបន្ទូលរបស់ព្រះជាម្ចាស់យ៉ាងដូចម្តេច (ទំនុកដំកើង១១៩:១០៥)?

___________________________________

២. ការដឹកនាំតាមរយៈការបណ្តាលឲ្យដឹង

តើមានអ្វីដែលបណ្តាលឲ្យសាវ័ក ប៉ុល រំជួលចិត្តចង់ប្រកាសដំណឹងល្អនៅក្រុងអាថែន (កិច្ចការ ១៧:១៦)?

___________________________________

៣. ការដឹកនាំតាមរយៈទិព្វវិញ្ញាណរបស់ព្រះជាម្ចាស់

តើអ្នកជឿអាចដឹងច្បាស់ថា ព្រះជាម្ចាស់កំពុងតែធ្វើអ្វីសម្រាប់ពួកគេ ទោះបើពួកគេស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ (រ៉ូម ៨:២៨)?

___________________________________

___________________________________

Copyright © 2014 by Grace Community Church | v1.2 | Get your FREE digital copy at www.cambodianchristianresources.com/fof

៤. ការដឹកនាំតាមរយៈប្រាជ្ញាដែលព្រះជាម្ចាស់បានប្រទានមក

យោងតាមកណ្ឌគម្ពីរ សុភាសិត ២:១-១១ តើសេចក្តីបួនយ៉ាងដែលប្រាជ្ញានឹងអនុញ្ញាតឲ្យលោកអ្នកដឹងមានអ្វីខ្លះ (ខ៩)?

(១) ____________________

(២) ____________________

(៣) ____________________

(៤) ____________________

តើលទ្ធផលនៃការស្វែងរកសេចក្តីទូន្មានគឺជាអ្វី (សុភាសិត ១៣:១០)? ____________

## III. ការអនុវត្ត

**ក) ចូរសរសេរចំណុចមួយដែលលោកអ្នកកំពុងមានការលំបាកក្នុងការសម្រេច។**

____________________

____________________

____________________

**ខ) តើការនេះទាក់ទងនឹងៈ**

- ☐ ព្រះហឫទ័យដែលមានអធិបតេយ្យភាពរបស់ព្រះជាម្ចាស់?
- ☐ ព្រះហឫទ័យបង្គាប់បញ្ជារបស់ព្រះជាម្ចាស់?
- ☐ ខ្ញុំមិនដឹងថាមួយណាទេ។

**គ) តើលោកអ្នកគួរឆ្លើយតបបែបណា ប្រសិនបើការនេះទាក់ទងនឹងៈ**

១. ព្រះហឫទ័យដែលមានអធិបតេយ្យភាពរបស់ព្រះជាម្ចាស់ (សុភាសិត ៣:៥-៦)។

២. ព្រះហឫទ័យបង្គាប់បញ្ជារបស់ព្រះជាម្ចាស់ (យ៉ូហាន ១៥:១០)។

៣. លោកអ្នកមិនប្រាកដ (យ៉ាកុប ១:៥)។

ឥឡូវនេះ តើលោកអ្នកគួរសម្រេចចិត្តធ្វើយ៉ាងដូចម្តេចវិញ?

____________________

____________________

____________________

បើលោកអ្នកចង់ដឹងព័ត៌មានពីសៀវភៅគ្រីស្ទបរិស័ទជាភាសាខ្មែរផ្សេងៗទៀត
សូមចូលទៅកាន់គេហទំព័រ៖

Looking for more Christian resources in the Khmer language? Visit:

http://www.cambodianchristianresources.com